សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ តាមបែបវិមជ្ឈការ

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ឌី ឧត្តម**
កញ្ញា **ថា ចាន់ឆាន**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ឈុន ណារ៉េត**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១៣

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ជាបឋម យើងខ្ញុំឈ្មោះ **ជី ឧត្តម** និង **ថា ចាន់ធាន** ជានិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែក រដ្ឋបាលសាធារណៈ ឆ្នាំទី៤ ឆមាសទី២ ជំនាន់ទី១៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្ត សេដ្ឋកិច្ច សូមសម្តែងនូវការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះលោកឪពុក និងអ្នកម្តាយដែលបានផ្តល់ កំណើត ចិញ្ចឹមបីបាច់ ថែរក្សា អប់រំណែនាំ និងការឧបត្ថម្ភគ្រប់បែបយ៉ាងទាំងធនធាន (ថវិកា និងសម្ភារៈ) និង ស្មារតីដល់ខ្ញុំគ្រប់បែបយ៉ាង រហូតដល់កូនមានឱកាសបានសិក្សារៀនសូត្រដល់ថ្ងៃ បញ្ចប់ថ្នាក់មហាវិទ្យាល័យ ដោយលោកទាំងពីរខិតខំ ជំនះរាល់ឧបសគ្គ មិនខ្លាចនឿយហត់ ពុះពារអោយកូនបានរៀនសូត្រ មានចំណេះដឹង ខ្ពង់ខ្ពស់ ដើម្បីរួមរស់នៅក្នុងសង្គមប្រកបដោយសុភវិនិច្ឆ័យ។ ហើយយើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ បណ្ឌិតទាំងអស់ដែលបានខិតខំផ្ទេរចំណេះដឹង និងចំពោះការ ស្វាគមន៍ដ៏រាក់ទាក់ កក់ក្តៅបំផុតក្នុងការជួយសម្រួលផ្នែកឯកសារ ទិន្នន័យ ស្មារតី និងសម្ភារៈផ្សេងៗ ដើម្បីបាន ផ្តល់លទ្ធភាពដល់យើងខ្ញុំក្នុងការបន្តការសិក្សា និងឈានដល់សរសេរសារណាប្រកបដោយជោគជ័យពី សំណាក់៖

- ឯកឧត្តម **លុយ ចន្ណា** ជាសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង គណៈ-គ្រប់គ្រងទាំងអស់ដែលបានខិតខំដឹកនាំសាកលវិទ្យាល័យ និងសម្របសម្រួលរាល់តម្រូវការ នៃការ សិក្សារបស់និស្សិត
- លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ណារ៉េត** ជាសាស្ត្រាចារ្យណែនាំដែលបានចំណាយពេលវេលាដ៏ មានតម្លៃក្នុងការបង្ហាត់បង្រៀន អប់រំ ណែនាំ ផ្តល់មតិយោបល់ ផ្តល់ឯកសារ និងត្រួតពិនិត្យសារណា ស្រាវជ្រាវនេះយ៉ាងយកចិត្តទុកដាក់ និងទឹកចិត្តរីករាយ
- លោក **ចក់ សារិន** ប្រធានក្រុមប្រឹក្សាឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ អាណត្តិទី៤ សហការី ដែលបានអនុញ្ញាត និងសហការផ្តល់បទសម្ភាស ទិន្នន័យ ព័ត៌មាន និងឯកសារពាក់ព័ន្ធ
- លោកឪពុក និងអ្នកម្តាយ ដែលបានជួយឧបត្ថម្ភគាំទ្រទាំងកម្លាំងកាយចិត្ត និងជួយសម្របសម្រួល ដំណើរការសរសេរសារណាគ្រប់បែបយ៉ាង
- មិត្តរួមថ្នាក់ និងរួមជំនាន់ទាំងអស់គ្នា ដែលបានជំរុញលើកទឹកចិត្ត ផ្តល់ព័ត៌មាន ពិភាក្សាផ្លាស់ប្តូរ យោបល់ ចំណេះដឹង រួមទាំងបទពិសោធន៍ល្អៗ ក្នុងការស្វែងរកដំណោះស្រាយក្នុងការស្រាវជ្រាវ

យើងខ្ញុំសូមថ្លែងអំណរគុណ ជូនពរដល់លោកអ្នកទាំងអស់គ្នា សូមជួបតែពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិធាន កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បច្ចុប្បន្ននេះ ប្រទេសកម្ពុជា ជាប្រទេសដែលកំពុងអភិវឌ្ឍន៍ដែលគ្រប់វិស័យនៅពុំទាន់មានការអភិវឌ្ឍបានរីកចម្រើនធំធាត់ខ្លាំងនៅឡើយ។ ជាក់ស្តែងប្រទេសកម្ពុជាបានធ្វើកំណែទម្រង់ស៊ីជម្រៅលើការគ្រប់គ្រងរដ្ឋ-បាលសាធារណៈរបស់ខ្លួនតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ ដោយហេតុថា រដ្ឋបាលសាធារ-ណៈនៃព្រះរាជាណាចក្រកម្ពុជាបានឆ្លងកាត់កំណែទម្រង់ជាច្រើនលើកច្រើនសាររហូតមកដល់ ពេលបច្ចុប្បន្ននេះហើយក្តីក៏រមែងនៅតែមានចំណុចខ្វះខាតមិនទាន់មានភាពល្អប្រសើរនូវឡើយទេ។ ដូច្នេះកម្ពុជា គ្មានជម្រើសណាល្អប្រសើក្រៅពីការខិតខំប្រឹងប្រែងធ្វើការកំណែទម្រង់ប្រព័ន្ធរដ្ឋបាល ឱ្យក្លាយទៅជារដ្ឋបាលសាធារណៈមួយមានលក្ខណៈបែបទំនើប និងនវានុវត្តន៍ ដោយផ្តោតលើប្រជាជនជាស្នូលនោះទេ។

រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខណ្ឌគោលនយោបាយបែបវិមជ្ឈការសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដូចជា រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ មូលដ្ឋានគ្រឹះនៃការអភិវឌ្ឍជាតិ គឺចាប់ផ្តើមពីការធ្វើកំណែទម្រង់វិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ ដែលនៅកៀកប្រជាពលរដ្ឋ។ ដូច្នេះហើយ ការធ្វើកំណែទម្រង់តាមបែបវិមជ្ឈការឃុំ សង្កាត់មានសារៈសំខាន់ណាស់ដែលជារឿងមិនអាចមើលរំលងបានឡើយ ហើយត្រូវយកចិត្តទុកដាក់ខ្ពស់បំផុត អនុវត្តន៍បានត្រឹមត្រូវតាមបច្ចេកទេស ដើម្បីទទួលបានចីរភាពលើការគ្រប់គ្រងរដ្ឋបាល និងការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន។ រដ្ឋបាលឃុំ សង្កាត់បានទទួលបាននូវ តួនាទី មុខងារ សិទ្ធិអំណាច ភាពជាម្ចាស់ ការទទួលខុសត្រូវ និងធនធាន (មនុស្ស ថវិកា និងទ្រព្យសម្បត្តិ) ពីរាជរដ្ឋាភិបាលក្នុងការបំពេញតម្រូវការជូនប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រនៅក្នុងមូលដ្ឋានរបស់ខ្លួន។

ការសិក្សាស្រាវជ្រាវលើប្រធានបទ ការគ្រប់គ្រងរដ្ឋបាលឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ តាមបែបវិមជ្ឈការនេះ ដើម្បីធ្វើការស្វែងយល់ឱ្យកាន់តែច្បាស់ពីការអនុវត្តការងារតាមនយោបាយវិមជ្ឈការនៃរដ្ឋបាលឃុំទឹកល្អក់។ ជុំវិញការអនុវត្តការងារប្រចាំថ្ងៃរបស់រដ្ឋបាលឃុំទឹកល្អក់ ដោយបានផ្សារភ្ជាប់ជាមួយទ្រឹស្តី គោល-នយោបាយ និងរបបគតិយុត្តនានាបន្ថែមទៀត។

ទោះបីជាយើងខ្ញុំខិតខំពិនិត្យឡើងវិញនូវខ្លឹមសារ និងពាក្យពេចន៍ច្រើនដងហើយក៏ពិតមែន តែយើងខ្ញុំជឿជាក់ថា ឯកសារមួយនេះក៏នូវមានចំណុចខ្វះចន្លោះមួយចំនួន និងមិនទាន់គ្រប់ជ្រុងជ្រោយពេញលក្ខណៈនូវឡើយទេ អាស្រ័យហេតុនេះ សូមសាស្ត្រាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានទាំងអស់គ្នាមេត្តាអធ្យាស្រ័យ។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមថាចំពោះសារណាស្រាវជ្រាវនេះ នឹងក្លាយជាឯកសារជំនួយស្មារតីដ៏មានប្រយោជន៍សម្រាប់មិត្តអ្នកអានទាំងអស់គ្នាជាក់ជាមិនខានឡើយ។

# មាតិកា

**ទំព័រ**

**អក្សរកាត់** ............ iv

## សេចក្តីផ្តើម

១.លំនាំបញ្ហា ............ ១
២.ចំណោទបញ្ហា ............ ២
៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ ............ ៣
៤.ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ ............ ៣
៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ............ ៣
៦.វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ ............ ៤
៧.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ............ ៦

## ជំពូកទី១

## រំលឹកទ្រឹស្តី និងគោលការណ៍សំខាន់ៗ

១.១.ប្រព័ន្ធវិមជ្ឈការនៅកម្ពុជា ............ ៨
១.១.១.និយមន័យវិមជ្ឈការ ............ ៩
១.១.២.មុខងារវិមជ្ឈការ ............ ៩
១.១.៣.លក្ខណៈពិសេសនៃវិមជ្ឈការ ............ ៩
១.១.៤.ទម្រង់ផ្សេងៗនៃវិមជ្ឈការ ............ ១០
១.២.ការរៀបចំរដ្ឋបាលឃុំ សង្កាត់ ............ ១២
១.២.១.ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ............ ១២
១.២.២.រចនាសម្ព័ន្ធ និងតួនាទីក្រុមប្រឹក្សាឃុំ សង្កាត់ ............ ១៣
១.២.៣.តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ ............ ១៧
១.៣.កិច្ចការរដ្ឋបាលឃុំ សង្កាត់ ............ ១៨
១.៣.១.លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់ ............ ១៨
១.៣.២.លិខិតរដ្ឋបាលឃុំ សង្កាត់ ............ ១៩
១.៣.៣.ការគ្រប់គ្រងបុគ្គលិក ឯកសារ និងសម្ភារបរិក្ខាររបស់ឃុំ សង្កាត់ ............ ២១
១.៣.៤.ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ............ ២២

## ជំពូកទី២

## ដំណើរការគ្រប់គ្រងរដ្ឋបាលរបស់ឃុំទឹកល្អក់

២.១.ប្រវត្តិ និងស្ថានភាពទូទៅ ..... ២៣
២.១.១.ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ ..... ២៣
២.១.២.ស្ថានភាពសេដ្ឋកិច្ច ..... ២៤
២.២.ការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋបាលឃុំទឹកល្អក់ ..... ២៤
២.២.១.សមាសភាពក្រុមប្រឹក្សា ..... ២៤
២.២.២.គណៈកម្មាធិការនានារបស់ឃុំទឹកល្អក់ ..... ២៥
២.៣.ការអភិវឌ្ឍរបស់ឃុំទឹកល្អក់ ..... ២៧
២.៣.១.ផែនការអភិវឌ្ឍន៍ឃុំ ..... ២៧
២.៣.២.កម្មវិធីវិនិយោគ ..... ៣០
២.៤.ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំ ..... ៣៣
២.៤.១.ការរៀបចំ និងអនុម័តថវិការបស់ឃុំ ..... ៣៣
២.៤.២.ចំណូល និងចំណាយថវិការបស់ឃុំ ..... ៣៣
២.៤.៣.ប្រព័ន្ធទូទាត់ គណនេយ្យភាព និងលទ្ធកម្ម ..... ៣៤

## ជំពូកទី៣

## បញ្ហាប្រឈម និងដំណោះស្រាយ

៣.១.សមិទ្ធផល ..... ៣៦
៣.១.១.ការគ្រប់គ្រងរដ្ឋបាល ..... ៣៦
៣.១.២.ការងារសន្តិសុខ សេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ និងវប្បធម៌ ..... ៣៨
៣.២.បញ្ហាប្រឈម ..... ៤០
៣.២.១.ផ្នែកកសិម្ម និងដីធ្លី ..... ៤០
៣.២.២.ផ្នែកគមនាគមន៍ និងដីធ្លី ..... ៤១
៣.២.៣.ផ្នែកសុខាភិបាល និងបរិស្ថាន ..... ៤១
៣.២.៤.ផ្នែកអប់រំ ..... ៤២
៣.២.៥.ផ្នែកសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ..... ៤២
៣.២.៦.ផ្នែកកាងាររដ្ឋបាល និងការចូលរួមរបស់ប្រជាពលរដ្ឋ ..... ៤២

៣.៣.ដំណោះស្រាយ ........ ៤៣
៣.៣.១.ការពង្រឹងវិស័យកសិកម្ម និងដីធ្លី ........ ៤៣
៣.៣.២.ការកែលម្អប្រព័ន្ធគមនាគមន៍ និងធនធានធម្មជាតិ ........ ៤៤
៣.៣.៣.ការថែទាំសេវាសុខាភិបាល និងបរិស្ថាន ........ ៤៤
៣.៣.៤.ការលើកម្ពស់គុណភាពអប់រំ ........ ៤៤
៣.៣.៥.ការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ........ ៤៥
៣.៣.៦.ការបង្កើនប្រសិទ្ធភាពការងាររដ្ឋបាល និងអភិបាលកិច្ចល្អ ........ ៤៦
៣.៤.ទិសដៅអនាគត ........ ៤៦
៣.៤.១.អភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ........ ៤៦
៣.៤.២.ផ្នែកសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយ ........ ៤៦
៣.៤.៣.ផ្នែកផ្តល់សេវាសាធារណៈ ........ ៤៧
**សេចក្តីសន្និដ្ឋាន** ........ ៤៨
**អនុសាសន៍** ........ ៥០
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

| | | | |
|---|---|---|---|
| ១. | **ច.គ.ឃ.ស** | : | ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ |
| ២. | **គ.ជ.ឃ.ស** | : | គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ |
| ៣. | **ក្របឃ.ស** | : | ក្រុមប្រឹក្សាឃុំ សង្កាត់ |
| ៤. | **គ.ក.ន.ក** | : | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ |

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

ប្រទេសកម្ពុជា ជាប្រទេសមួយដែលបានឆ្លងកាត់សង្គ្រាមស៊ីវិលច្រើនលើកច្រើនសារ។ ដោយសារតែឆ្លងកាត់សង្គ្រាមដែលបានអូសបន្លាយប្រមាណបីទសវត្សរ៍ មិនត្រឹមតែបង្អាក់ការអភិវឌ្ឍនៅកម្ពុជាលើគ្រប់វិស័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរនូវរចនាសម្ព័ន្ធ ប្រព័ន្ធនយោបាយ រដ្ឋបាល សង្គម សេដ្ឋកិច្ច វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ ជាពិសេស នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៩។ បន្ទាប់ពីប្រទេសកម្ពុជាបានចុះកិច្ចព្រមព្រៀងទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ រួមទាំងផ្អែកលើគំនិតផ្តួចផ្តើម ក្នុងការសម្របសម្រួល ខាងនយោបាយ ពីសំណាក់ប្រមុខរាជរដ្ឋាភិបាល បានរៀបចំក្របខណ្ឌគោលនយោបាយ សម្រាប់បោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ និងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយត្រូវបានរៀបចំឡើងនាឆ្នាំ១៩៩៩ និងបានឈានទៅដល់រៀបចំច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបានរដ្ឋសភាអនុម័តនាខែមករា ឆ្នាំ២០០១។ នៅឆ្នាំ២០០២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសចំនួន ១,៦២១ ឃុំ សង្កាត់ ត្រូវបានរៀបចំឡើងតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស។ ចាប់ពីពេលនោះមកកំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការ ត្រូវធ្វើឡើងនៅថ្នាក់ឃុំ សង្កាត់។ សមិទ្ធផលនៃកំណែទម្រង់ដែលបានសម្រេចបាននៅថ្នាក់ឃុំ សង្កាត់ បានជម្រុញ និងលើទឹកចិត្តដល់រាជរដ្ឋាភិបាល ដើម្បីពង្រីកដំណើរការកំណែទម្រង់នេះរហូតដល់ថ្នាក់ក្រោមជាតិតាមរយៈការដាក់ចេញក្របខណ្ឌ យុទ្ធសាស្ត្រ កំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការឆ្នាំ២០០៥។ ផ្អែកលើតម្រូវការកំណែទម្រង់នេះ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្ម ដោយបានរៀបចំដែនដីរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានីភ្នំពេញ និងខេត្ត។ រាជធានីភ្នំពេញចែកជាខណ្ឌ។ ខណ្ឌចែកជា សង្កាត់។ ខេត្តចែកជា ក្រុង និងស្រុក។ ក្រុងចែកជា សង្កាត់។ ស្រុកចែកជា ឃុំ និងសង្កាត់ ប៉ុន្តែសង្កាត់ក្នុងស្រុកមិនទាន់មានឡើយ។

ក្នុងនោះដែរ ផ្នែកមួយដ៏សំខាន់គឺ រាជរដ្ឋាភិបាលបានដាក់ចេញនូវនយោបាយវិមជ្ឈការថ្នាក់ឃុំ សង្កាត់ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងជាទិសដៅអាទិភាពធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ។ ជាក់ស្តែងនាពេលបច្ចុប្បន្ននេះ រដ្ឋបាលឃុំ សង្កាត់ជាមណ្ឌលរដ្ឋបាលអនុវត្តន៍នយោបាយវិមជ្ឈការផង និងវិសហវិមជ្ឈការផង។ ក្នុងដំណើរការនេះ រាជរដ្ឋាភិបាលចាត់ទុកដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្កិតសេវាសាធារណៈឲ្យកាន់តែជិតប្រជាពលរដ្ឋ។ ក្នុងន័យ ទិសដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការ គឺដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និងជំរុញការអភិវឌ្ឍនៅមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។ ពិសេសនឹងទទួលបាននូវផលប្រយោជន៍បីធំៗរួមមាន

ផ្តល់លទ្ធភាពប្រជាពលរដ្ឋក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្ត ប្រសិទ្ធភាពខ្ពស់នៃការផ្តល់សេវាសាធារណៈ និងការកៀរគរធនធាននៅមូលដ្ឋាន។ នយោបាយនេះ បានផ្តល់លទ្ធភាពខ្ពស់ទៅដល់ប្រជាពលរដ្ឋក្នុងការស្នើ និងការទទួលយកសេវា ប្រកបដោយប្រសិទ្ធភាព សាមញ្ញ រហ័សទាន់ចិត្ត តម្លាភាព គណនេយ្យភាព និងប្រសិទ្ធផលខ្ពស់។ ក្នុងន័យនេះ សិទ្ធិអំណាចមូលដ្ឋានដែលបានទទួលយកដោយក្រុមតំណាងប្រជាពលរដ្ឋមូលដ្ឋាន (ក្រុមប្រឹក្សាឃុំ សង្កាត់) ជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែលធ្វើសកម្មភាពបម្រើផលប្រយោជន៍ជូនសាធារណៈ ក្នុងកិច្ចការអភិវឌ្ឍន៍ដែលប្រជាពលរដ្ឋបានបោះឆ្នោតជាសកលដោយផ្ទាល់ ដើម្បីឈរជាតំណាងការពារសិទ្ធិសេរីភាព និងផលប្រយោជន៍របស់ខ្លួនក្នុងមូលដ្ឋានឃុំ សង្កាត់។

ដោយសារការសង្កេតឃើញនូវទិដ្ឋភាពនៃការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ បែបនេះហើយដែលជាចំណាប់អារម្មណ៍របស់ក្រុមយើងខ្ញុំ បានឈានដល់ការសម្រេចជ្រើសរើសយកប្រធានបទ **“ការគ្រប់គ្រងរដ្ឋបាលឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ តាមបែបវិមជ្ឈការ”** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ និងដើម្បីស្វែងយល់កាន់តែច្បាស់លាស់អំពីការអនុវត្តនយោបាយវិមជ្ឈការនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ ក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

## ២.ចំណោទបញ្ហា

យោងតាមលំនាំបញ្ហា បានជំរុញឱ្យក្រុមប្រឹក្សាឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ មានការទទួលខុសត្រូវលើការគ្រប់គ្រងលើកិច្ចការរដ្ឋបាល ការផ្តល់សេវាសាធារណៈ ការពារផលប្រយោជន៍ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងដោះស្រាយរាល់បញ្ហាប្រឈមក្នុងដែនសមត្ថកិច្ច តាំងនាមជាអ្នកដឹកនាំ និងជាអ្នកតំណាងប្រជាពលរដ្ឋ។ ដូច្នេះ ចំណុចសំខាន់នៃការស្រាវជ្រាវលើប្រធានបទស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ តាមបែបវិមជ្ឈការ ផ្តោតសំខាន់លើបញ្ហាដូចខាងក្រោម៖

- ហេតុអ្វីបានជារដ្ឋបាលថ្នាក់ឃុំ-សង្កាត់ត្រូវគ្រប់គ្រងតាមបែបវិមជ្ឈការ?
- តើរដ្ឋបាលឃុំទឹកល្អក់ បានអនុវត្តន៍តាមនយោបាយវិមជ្ឈការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានដល់កម្រិតណា? មានតម្លាភាព គណនេយ្យភាព គុណភាព និងប្រសិទ្ធភាពដែរឬទេ?
- តើដំណើរការនៃការគ្រប់គ្រងរដ្ឋបាលរបស់ឃុំទឹកល្អក់បានជួបប្រទះនូវបញ្ហាអ្វីខ្លះ?
- តើលទ្ធផលនៃការអនុវត្តការងារកន្លងមកនៅឃុំទឹកល្អក់ ទទួលបានផលយ៉ាងដូចម្តេច? និងមានបញ្ហាប្រឈមអ្វីខ្លះ?
- តើអាជ្ញាធរនៃរដ្ឋបាលឃុំទឹកល្អក់បានចាត់វិធានការដោះស្រាយចំពោះបញ្ហាប្រឈមបែបណាខ្លះ ដើម្បីដោះស្រាយ និងកែលម្អបញ្ហាទាំងនោះឱ្យបានល្អប្រសើរ?

## ៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះ មានគោលបំណង៖

- ឱ្យសាធារណជន និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានបានយល់ដឹងអំពីការគ្រប់គ្រងតាមបែបវិមជ្ឈការ និងតួនាទី ភារកិច្ច របៀបការងាររបស់អាជ្ញាធររដ្ឋបាលឃុំទឹកល្អក់
- ស្វែងយល់អំពីការអនុវត្តនយោបាយវិមជ្ឈការក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលឃុំទឹកល្អក់
- សិក្សាអំពីដំណើរការគ្រប់គ្រង និងរចនាសម្ព័ន្ធរបស់រដ្ឋបាលឃុំទឹកល្អក់
- ស្វែងយល់អំពីប្រព័ន្ធអភិបាលកិច្ចល្អ និងរបៀបបម្រើសេវាសាធារណៈរបស់រដ្ឋបាលឃុំទឹកល្អក់
- ស្វែងយល់អំពីសមិទ្ធផលដែលសម្រេចបាន វិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាប្រឈម រួមទាំងការកំណត់ទិសដៅអនាគតរបស់រដ្ឋបាលឃុំទឹកល្អក់
- រួមចំណែកក្នុងការកែលម្អនូវចំណុចខ្វះខាតដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ និងការជំរុញកិច្ចអភិវឌ្ឍន៍សង្គមប្រកបទៅដោយប្រសិទ្ធភាព តាមរយៈការផ្តល់ជាអនុសាសន៍ល្អៗ។

## ៤.ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ មានដែនកំណត់ និងវិសាលភាពគ្របដណ្តប់តែលើសកម្មភាពនៃការអនុវត្តការងាររបស់រដ្ឋបាលឃុំទឹកល្អក់ ក្នុងឆ្នាំ២០១៩ តែប៉ុណ្ណោះ។ ដូច្នេះហើយ ចំពោះប្រធានបទស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ តាមបែបវិមជ្ឈការនេះ យើងខ្ញុំសូមធ្វើការបកស្រាយទៅលើចំណុចមួយចំនួនដែលទាក់ទងជាមួយនឹងដំណើរការគ្រប់គ្រងរដ្ឋបាល សមិទ្ធផលដែលសម្រេចបាន បញ្ហាប្រឈម ទិសដៅអនាគត និងដំណោះស្រាយលើបញ្ហាផ្សេងៗរបស់រដ្ឋបាលឃុំទឹកល្អក់។

## ៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ជាទូទៅ ការសិក្សាស្រាវជ្រាវតែងតែមានគុណតម្លៃដល់អ្នកសិក្សាគ្រប់រូបលើប្រធានបទ ឬជំនាញដែលខ្លួនជ្រើសរើស មានន័យថាសារៈប្រយោជន៍នៃការសិក្សាស្រាវជ្រាវ ដំបូងគឺឲ្យអ្នកស្រាវជ្រាវបានយល់ដឹង និងចងចាំបានច្បាស់ ហើយកាន់តែលម្អិតលើប្រធានបទ បន្ទាប់មកវាក៏បានផ្តល់សារៈប្រយោជន៍ជាច្រើនទៀតដល់អ្នកអាន និងសាធារណជនទាំងឡាយ ដែលបានអាននូវស្នាដៃស្រាវជ្រាវនេះ។ សារៈប្រយោជន៍ទាំងនេះ រួមមានជាអាទិ៍គឺ៖

**ក.ប្រយោជន៍សម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន និងរដ្ឋបាលឃុំសាមី**

- បានយល់ដឹងអំពីការអនុវត្តការងារ និងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលឃុំ
- យល់ដឹងអំពីរបៀបការរៀបចំការងាររដ្ឋបាលមួយចំនួន
- អាចបង្ហាញអំពីការពេញចិត្ត ឬមិនពេញចិត្តចំពោះការដឹកនាំ និងការអនុវត្តការងាររបស់រដ្ឋបាលឃុំ

- បង្កើនការយល់ដឹងទាក់ទងការបម្រើសេវាសាធារណៈរបស់រដ្ឋបាលឃុំ
- យល់ដឹងអំពីតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំកាន់តែច្បាស់បន្ថែមទៀត
- រដ្ឋបាលឃុំបានបង្ហាញពីសក្តានុពល កិច្ចអភិវឌ្ឍន៍ និងសមិទ្ធផលដែលសម្រេចបាន
- បង្ហាញពីការយកចិត្តទុកដាក់របស់រដ្ឋបាលឃុំចំពោះប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- រដ្ឋបាលឃុំសាមីដែលចុះធ្វើការសិក្សាស្រាវជ្រាវ ទទួលបានឯកសារសម្រាប់តម្កល់ទុកក្នុងសាលាឃុំ

**ខ.ប្រយោជន៍សម្រាប់និស្សិត**

- បានប្រតិបត្តិតាមទិសដៅរបស់សាកលវិទ្យាល័យ ក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្របានដោយជោគជ័យ
- បានស្វែងយល់កាន់តែច្បាស់អំពីយន្តការ ការអនុវត្តនីតិវិធីក្នុងការបំពេញតួនាទី និងភារកិច្ចក្នុងរចនា-សម្ព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានស្វែងយល់កាន់តែច្បាស់ពីយុទ្ធសាស្ត្រ ក្របខណ្ឌច្បាប់ និងគោលនយោបាយ ក្នុងការបម្រើសេវាសាធារណៈ និងអភិបាលកិច្ចល្អជូនប្រជាពលរដ្ឋ
- បានរួមចំណែកដោយផ្ទាល់ ក្នុងការជួយជំរុញ និងលើកកម្ពស់ការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព

**គ.ប្រយោជន៍សម្រាប់សាកលវិទ្យាល័យ សាធារណជន និងប្រទេសជាតិ**

- សាកលវិទ្យាល័យទទួលបានឯកសារសម្រាប់តម្កល់ទុក
- មិត្តអ្នកអាន និងសាធារណជនអាចស្វែងយល់បន្ថែមពីទ្រឹស្តីមួយចំនួនពាក់ព័ន្ធក្នុងកិច្ចការស្រាវជ្រាវនេះ និងយល់កាន់តែច្បាស់អំពីការអនុវត្តការងាររដ្ឋបាលឃុំ
- ឃុំមានការរីកចម្រើនដោយកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋបាលឃុំ ធ្វើឱ្យប្រទេសមានការរីកចម្រើន
- ការផ្តល់សេវាសាធារណៈបានល្អ ធ្វើឱ្យការងាររលូនទៅមុខស្របតាមគោលនយោបាយជាតិ
- បានបង្ហាញពីការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិតាមរយៈការចូលរួមដែលមិនអាចខ្វះបានពីមូលដ្ឋាន។

## ៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

**ក.ក្របខណ្ឌនៃការសិក្សាស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវនេះ បានកំណត់លើការសិក្សាស្រាវជ្រាវនៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ តាមបែបវិមជ្ឈការ ក្នុងឆ្នាំ២០១៩ តែប៉ុណ្ណោះ។

**ខ.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ**

ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំជ្រើសរើសយកវិធីសាស្ត្រស្រាវជ្រាវចំនួន០៣បែបគឺ (១) វិធីសាស្ត្របែបរុករក (២) វិធីសាស្ត្របែបពិពណ៌នា និង(៣) វិធីសាស្ត្របែបប្រៀបធៀបវិភាគ។ មូលហេតុដែលយើងខ្ញុំជ្រើសរើសប្រធានបទនេះ ដោយសារមុននឹងសរសេរសារណាមួយឲ្យបានល្អ ត្រូវការឯកសារដែលមាន

ស្រាប់ ការសម្ភាសផ្ទាល់ជាមួយមន្ត្រី ការស្រង់យកទិន្នន័យ និងព័ត៌មានដើម្បីប្រៀបធៀប រួចធ្វើការវិភាគលើទ្រឹស្តីអត្ថបទគតិយុត្ត ទស្សនទានគោលនយោបាយវិមជ្ឈការ និងទស្សនទាននានា។ ហេតុដូច្នេះ ជាហេតុនាំឲ្យឈានទៅដល់ការសម្រេចជ្រើសរើសយកវិធីសាស្ត្រសិក្សាស្រាវជ្រាវខាងលើ សម្រាប់ធ្វើការបន្ថែមឱ្យគ្នាទៅវិញទៅមក។

**ខ.១.ការប្រមូលទិន្នន័យ**

ដើម្បីឱ្យការសិក្សាស្រាវជ្រាវកាន់តែច្បាស់ ទិន្នន័យដែលត្រូវមានពីរប្រភេទគឺ ទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។ ទិន្នន័យចម្បង ក្រុមយើងខ្ញុំបានមកពីការចូលរួមផ្ទាល់ក្នុងការសម្ភាសជាមួយមេឃុំ និងស្មៀនរបស់រដ្ឋបាលឃុំទឹកល្អក់ (មើលក្នុងឧបសម្ព័ន្ធ ៦.) មេប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំទឹកល្អក់ (មើលក្នុងឧបសម្ព័ន្ធ ៧.) សម្ភាសជាមួយប្រជាពលរដ្ឋរស់នៅក្នុងឃុំទឹកល្អក់ផ្ទាល់ (មើលក្នុងឧបសម្ព័ន្ធ ៨.) របាយការណ៍ប្រចាំខែធ្នូ ឆ្នាំ២០១៩ (មើលក្នុងឧបសម្ព័ន្ធ ៥.) ដែលទាក់ទងនឹងបទពិសោធន៍ក្នុងរដ្ឋបាលឃុំទឹកល្អក់ជាក់ស្តែងតែម្តង។ ចំណែកទិន្នន័យបន្ទាប់បន្សំ បានតាមរយៈការប្រមូលផ្តុំឯកសារផ្សេងៗ ការពិភាក្សាទាក់ទងច្បាប់ អនុ-ក្រឹត្យ សេចក្តីសម្រេច និងគោលនយោបាយនានាដែលរាជរដ្ឋាភិបាលបានដាក់ចេញ ជាពិសេសចំពោះច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (មើលក្នុងឧបសម្ព័ន្ធ ១.) ព្រឹត្តិបត្រស្រាវជ្រាវ សារព័ត៌មាន ឯកសារពាក់ព័ន្ធមួយចំនួនទៀតពីប្រព័ន្ធអ៊ីនធឺណិត ព្រមទាំងការប្រឹក្សាយោបល់ពីសាស្ត្រាចារ្យណែនាំផងដែរ។

**ខ.២.ការវិភាគទិន្នន័យ**

ការវិភាគអាស្រ័យលើប្រភេទទិន្នន័យ ចំពោះទិន្នន័យចម្បង ការវិភាគធ្វើឡើងដោយម៉ត់ចត់ទៅតាមការពិភាក្សា ការស្ទង់មតិជាច្រើនលើកច្រើនសារមានភាពជាក់លាក់ ច្បាស់លាស់ ដើម្បីបញ្ជាក់ថា ការបកស្រាយធ្វើឡើងអនុលោមតាមខ្លឹមសារដើមទាំងស្រុង ពុំមានការបញ្ចេញបញ្ចូល ឬបំផ្លើសព័ត៌មានឡើយ។ ហេតុដូច្នេះហើយ រដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា យុទ្ធសាស្ត្រ គោលនយោបាយ កម្មវិធីអភិវឌ្ឍន៍ និងរបាយការណ៍របស់រដ្ឋបាលឃុំទឹកល្អក់ ត្រូវបានលើកឡើងមកពិចារណា ឆ្លុះបញ្ចាំងជាមួយការអនុវត្តជាក់ស្តែង និងប្រៀបធៀបទៅនឹងទិន្នន័យដែលទទួលបានពីការសម្ភាសផ្ទាល់ពីមន្ត្រី របស់រដ្ឋបាលឃុំទឹកល្អក់ ស្របតាមលក្ខណៈសត្យានុម័ត។ ចំណែកឯ ទិន្នន័យបន្ទាប់បន្សំ ដែលបានដកស្រង់ចេញពីឯកសារផ្សេងៗ សៀវភៅរបស់សាស្ត្រាចារ្យល្បីៗ ក៏ដូចជាមតិពន្យល់បន្ថែមរបស់សាស្ត្រាណែនាំសារណា ការវិភាគចាត់ទុកទិន្នន័យនេះជាព័ត៌មានពិចារណាបំពេញបន្ថែមឱ្យខ្លឹមសារគោលនៃសារណាស្រាវជ្រាវនេះ។

**ខ.៣.វិធីសាស្ត្រវិភាគ**

ទិន្នន័យដែលប្រមូលបាន និងធ្វើការវិភាគលក្ខណៈបែបប្រៀបធៀប វិភាគ ដោយរកចំណុចវិជ្ជមាន និងអវិជ្ជមានដែលពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ការប្រៀបធៀប វិភាគរកចំណុចវិជ្ជមាន និងអវិជ្ជមាន ត្រូវផ្សាភ្ជាប់ជាមួយនឹងទ្រឹស្តីច្បាប់ ដែលកំពុងចូលជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា គោល-

នយោបាយរាជរដ្ឋាភិបាល ទ្រឹស្តីវិទ្យាសាស្ត្រ និងយុទ្ធសាស្ត្ររបស់ឃុំ សង្កាត់ ក្នុងការអនុវត្តការងារជាក់ស្តែងដែលពាក់ព័ន្ធ។ ក្នុងករណីមានភាពអវិជ្ជមានកើតឡើង វិធីសាស្ត្រវិភាគទិន្នន័យនេះ ក៏ត្រូវបានវិភាគស្វែងរកដំណោះស្រាយ សមស្រប ដើម្បីដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមានក្នុងរដ្ឋបាលឃុំ សង្កាត់ និងមូលដ្ឋាន។

## ៧.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

រចនាសម្ព័ន្ធស្រាវជ្រាវក្រោមប្រធានបទ "**ការគ្រប់គ្រងរដ្ឋបាលឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺតាមបែបវិមជ្ឈការ**" នេះ ត្រូវបានចងក្រងចែកចេញតាមប្លង់ដូចខាងក្រោមនេះ៖

- **សេចក្តីថ្លែងអំណរគុណ៖** បរិយាយអំពីការគោរព ការដឹងគុណ និងការថ្លែងអំណរគុណចំពោះលោកអ្នកមានគុណទាំងពីរ លោកសាស្ត្រាចារ្យ ឯកឧត្តមសាកលវិទ្យាធិការ លោកសាស្ត្រាចារ្យណែនាំ លោកមេឃុំ មិត្តភក្តរួមជំនាន់ទាំងអស់ដែលបានរួមចំណែកយ៉ាងធំធេង និងជួយជំរុញឱ្យយើងទាំងពីរបានបញ្ចប់ការសិក្សារដោយជោគជ័យ។
- **អារម្ភកថា៖** បរិយាយអំពីអារម្មណ៍ និងការយល់ឃើញចំពោះប្រធានបទដែលពួកខ្ញុំទាំងពីរបានខិតខំស្រាវជ្រាវ រួមទាំងគំនិតមួយចំនួនទៀត។
- **សេចក្តីផ្តើម៖** និយាយអំពីបញ្ហាដែលបានបង្ហាញពីចំណុចដំបូងបំផុតនៃប្រធានបទ ការកកើតឡើងដំបូងនៃការរៀបចំក្របខណ្ឌគោលនយោបាយសម្រាប់បោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិឆ្នាំ១៩៩៩។ ចំណោទបញ្ហា ដែលប្រមូលផ្តុំទៅដោយចម្ងល់ជាច្រើនដែលទាក់ទងទៅនឹងលិខិតបទដ្ឋានគតិយុត្ត ការគ្រប់គ្រងរដ្ឋបាល ការអនុវត្តការងារ ជាពិសេសលើសេវាសាធារណៈ និងការដោះស្រាយចំពោះបញ្ហាផ្សេងៗ គោលបំណងនៃការស្រាវជ្រាវរបស់អត្ថបទទាំងមូល ទំហំ និងដែនកំណត់នៃការស្រាវជ្រាវដែលក្រុមយើងខ្ញុំបានកំណត់ត្រឹម ឆ្នាំ២០១៩តែប៉ុណ្ណោះ សារៈសំខាន់នៃការស្រាវជ្រាវ គឺពិតជាល្អសម្រាប់ប្រជាពលរដ្ឋ ឃុំ សង្កាត់ និស្សិត សាកលវិទ្យាល័យ សាធារណជន និងប្រទេសជាតិ ដោយរួមមាន វិធីសាស្ត្រស្រាវជ្រាវដែលបង្ហាញពីវិធីសាស្ត្រក្នុងការប្រមូលព័ត៌មានជាមួយរដ្ឋបាលឃុំ មេប៉ុស្តិ៍ ប្រជាពលរដ្ឋ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។
- **ជំពូកទី១ រំលឹកទ្រឹស្តី និងគោលការណ៍សំខាន់ៗ៖** ជំពូកនេះបង្ហាញអំពីទ្រឹស្តីមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទ ដែលមានដូចជា ប្រព័ន្ធវិមជ្ឈការនៅកម្ពុជា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ រចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់ តួនាទី មុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ និងកិច្ចការរដ្ឋបាលរបស់ឃុំ សង្កាត់។

- **ជំពូកទី២ ដំណើរការគ្រប់គ្រងរដ្ឋបាលឃុំទឹកល្អក់៖** ជំពូកនេះបង្ហាញអំពី ស្ថានភាពទូទៅ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋបាលឃុំទឹកល្អក់ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រួមទាំងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំទឹកល្អក់។
- **ជំពូកទី៣ បញ្ហាប្រឈម និងដំណោះស្រាយ៖** ជំពូកនេះ បានលើកឡើងអំពី សមិទ្ធផលដែលរដ្ឋបាលឃុំទឹកល្អក់សម្រេចបាន បញ្ហាប្រឈម និងដំណោះស្រាយ រួមទាំងទិសដៅអនាគតរបស់រដ្ឋបាលឃុំទឹកល្អក់បានដាក់ចេញ។
- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** ផ្នែកនេះជាចំណុចចុងក្រោយនៃសារណានេះ ដោយសង្ខេបនូវរាល់លទ្ធផលទាំងអស់ ដែលទទួលបានពីការស្រាវជ្រាវ និងបង្ហាញពីអនុសាសន៍មួយចំនួន។

# ជំពូកទី១

# រំលឹកទ្រឹស្តី និងគោលការណ៍សំខាន់ៗ

## ១.១.ប្រព័ន្ធវិមជ្ឈការនៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា មានឆន្ទៈក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ។ ដោយសារវិមជ្ឈការ ជាធាតុផ្សំសំខាន់ក្នុងការអនុវត្តនៃកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។ ប្រព័ន្ធវិមជ្ឈការនៅកម្ពុជាមានគោលបំណងចម្បងបីយ៉ាងគឺ (១)ជំរុញឱ្យមានដំណើរការលទ្ធិប្រជាធិបតេយ្យ និងការគ្រប់គ្រងបែបអភិបាលកិច្ចល្អនៅមូលដ្ឋាន ជំរុញគុណភាពក្នុងការរស់នៅឱ្យកាន់តែល្អប្រសើរបស់ប្រជាពលរដ្ឋ។ (២)ផ្តល់ឱកាសកាន់តែច្រើនឡើងដល់ប្រជាពលរដ្ឋក្នុងការសម្រេចចិត្តរៀបចំការអភិវឌ្ឍនៅមូលដ្ឋាន និង (៣)ធានាការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការបែងចែកនូវសេវាកម្មជាមូលដ្ឋានផ្សេងៗ។[១]

រាជរដ្ឋាភិបាលកម្ពុជាយល់ឃើញថា វិមជ្ឈការ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការរបស់ប្រជារាស្ត្រ លើកកម្ពស់គុណភាពនៃជីវិតរស់នៅរបស់ប្រជារាស្ត្រ និងលើកកម្ពស់ការផ្តល់នូវសេវាកម្មចាំបាច់ដល់មូលដ្ឋានសមស្របទៅតាមតំរូវការជាក់ស្តែងរបស់ខ្លួន។ ការរៀបចំ ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានដែលធានាឲ្យមានការចូលរួមប្រាស្រ័យពីប្រជាពលរដ្ឋគឺជាវិធីសាស្ត្រគ្រប់គ្រងមាន តម្លាភាព គណនេយ្យភាព និងប្រសិទ្ធផលខ្ពស់។ វិមជ្ឈការ គឺជាមធ្យោបាយដ៏ប្រសើរបំផុតសម្រាប់លើកកម្ពស់អភិបាលកិច្ចល្អ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជារាស្ត្រសំដៅអភិវឌ្ឍន៍ប្រទេសទាំងមូល។ ដូច្នេះ ការសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការជ្រើសរើស ឃុំ សង្កាត់ឱ្យអនុវត្តន៍នូវការគ្រប់គ្រងតាមនយោបាយវិមជ្ឈការ គឺជាការថ្លឹងថ្លែងពិចារណាយ៉ាងហ្មត់ចត់ ដោយមានហេតុផលជាក់ស្តែង និងសមស្របបំផុតសម្រាប់បរិបទ នៃប្រទេសកម្ពុជា។ ទន្ទឹមនឹងហេតុផលនេះ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំបង្កើតច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានអនុម័តដោយរដ្ឋសភាកម្ពុជា ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការចាប់ផ្តើមអនុវត្តន៍នូវគោលនយោបាយវិមជ្ឈការ នៅកម្ពុជា។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុម័តនៅឆ្នាំ២០០១ ដែលនាំឱ្យមានការផ្លាស់ប្តូរយ៉ាងស៊ីជម្រៅទៅលើបរិយាកាសនយោបាយកម្ពុជា។ ច្បាប់ទាំងពីរនេះ បានបង្កើតឲ្យមានក្រុមប្រឹក្សាឃុំ សង្កាត់តាមបែបវិមជ្ឈការដែលជាអង្គភាពដ៏សំខាន់សម្រាប់អភិបាលកិច្ចមូលដ្ឋាន ហើយច្បាប់ទាំងពីរនេះ នាំឱ្យមានការបោះឆ្នោតសម្រាប់ក្រុមប្រឹក្សាទាំងនោះ។

ជាក់ស្តែងនៅប្រទេសកម្ពុជា វិមជ្ឈការបានក្លាយជាគោលនយោបាយពិតប្រាកដបន្ទាប់ពីមានការបោះ

[១] ដកស្រង់ចេញពីសៀវភៅ វិមជ្ឈការ និងវិសហមជ្ឈការ និពន្ធដោយ សាស្ត្រាចារ្យ កៅ មុយថង ឆ្នាំ២០០៧ ទំព័រទី៣

ឆ្នោតឃុំ សង្កាត់លើកទី១ ត្រូវបានរៀបចំធ្វើឡើងនៅថ្ងៃអាទិត្យ ទី០៣ ខែកុម្ភៈ ឆ្នាំ២០០២ ដោយមានអ្នកបោះឆ្នោតជាង ៤,៥លាននាក់ បានបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ១,១២៦រូប តំណាងឲ្យឃុំសង្កាត់ចំនួន ១,៦២១។ នៅក្នុងការបោះឆ្នោតនោះ មានបេក្ខជនឈរឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតចំនួន ៧៥,៦៥៥រូប។ មិនតែប៉ុណ្ណោះ មានការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លើកទី២ លើកទី៣ និងនីតិកាលបន្តបន្ទាប់ទៀត។

### ១.១.១.និយមន័យវិមជ្ឈការ

**វិមជ្ឈការ** គឺជាការដែលរាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មូលដ្ឋាន ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានលើបញ្ហាទាំងនេះ។ ក្នុងន័យនេះ រាល់កិច្ចការនានាដែលបានធ្វើវិមជ្ឈការទៅឲ្យក្រុមប្រឹក្សា ក្រុមប្រឹក្សាមានឆន្ទានុសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការទាំងនោះនៅក្នុងមូលដ្ឋានរបស់ខ្លួន។ ទន្ទឹមនេះ ក្រុមប្រឹក្សាក៏ជាអ្នកទទួលខុសត្រូវដោយផ្ទាល់លើការអនុវត្តកិច្ចការទាំងនោះផងដែរ។[២]

វាជាដំណើរមួយដែលសិទ្ធិអំណាច និងការទទួលខុសត្រូវនៃមុខងារសាធារណៈ ត្រូវបានផ្ទេរពីរដ្ឋបាលកណ្តាលឱ្យទៅរដ្ឋបាលថ្នាក់មូលដ្ឋាន ដែលមានគោលបំណងទំនាក់ទំនងយ៉ាងជិតស្និតទៅនឹងគោលគំនិតស្តីពី Subsidiarity ជាគោលគំនិតក្នុងការបង្ហាញនូវការផ្ទេរអំណាចឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមលក្ខណៈដែលរដ្ឋបាលថ្នាក់ក្រោមជាតិ អាចទទួលយកបានសមស្របទៅសមត្ថភាព ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាព។

### ១.១.២.មុខងារវិមជ្ឈការ

វិមជ្ឈការមានមុខងារពីរខុសគ្នាគឺ៖

- **មុខងារនៃធម្មានរូបកម្មនៃអំណាចរបស់រដ្ឋ** ពោលគឺនៅពេលធ្វើវិមជ្ឈការអំណាចរបស់រដ្ឋបង្ហាញឱ្យឃើញសេរីភាវូបនីយកម្ម និងរបបមួយមានលក្ខណៈប្រជាធិបតេយ្យ។ ហេតុនេះ នយោបាយក្នុងការធ្វើវិមជ្ឈការរបស់រដ្ឋ គឺនយោបាយមួយចំនេញខាងស្មារតី ឬចិត្តសាស្ត្រ និយាយរួមអំណាចកណ្តាលត្រូវបានគោរពដោយប្រជាជន។
- **មុខងារនៃការបំពេញចិត្តទាមទារចេញមកពីកម្លាំងនយោបាយ និងសង្គម** ដែលមិនត្រួតពិនិត្យដោយឧបករណ៍រដ្ឋ និងជាកម្លាំងដែលទាមទារសេរីភាពជាសមូហភាពមួយផ្នែក។

### ១.១.៣.លក្ខណៈពិសេសនៃវិមជ្ឈការ

បច្ចេកទេសនៃការគ្រប់គ្រងតាមនយោបាយវិមជ្ឈការមានលក្ខណៈពិសេសចំនួន បីគឺ៖

[២] ដកស្រង់ចេញពីសៀវភៅ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា ឆ្នាំ២០១៩ ទំព័រទី១៨

- **បុគ្គលភាពគតិយុត្ត** សំដៅដល់ប្រព័ន្ធវិមជ្ឈការដែលមានបុគ្គលភាពគតិយុត្តខុសពីរដ្ឋ។ ប្រព័ន្ធនេះ ជាប្រធាននៃនីតិខុសពីរដ្ឋ។ ប្រព័ន្ធទាំងនេះមានសិទ្ធិ និងកាតព្វកិច្ចផ្ទាល់ខ្លួន មានគោលដៅ សិទ្ធិ អំណាច និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន (ថវិកា សម្ភារៈ និងធនធានមនុស្ស)។
- **សមត្ថកិច្ចផ្ទាល់** សំដៅដល់ប្រព័ន្ធវិមជ្ឈការខុសពីសមត្ថកិច្ចរដ្ឋ។ ពោលគឺមានលក្ខណៈគតិយុត្តពីរគឺៈ (១)មិនមែនជាសមត្ថកិច្ចជាគោលការណ៍ទេ ប៉ុន្តែជាសមត្ថកិច្ចដែលកំណត់ដោយច្បាប់ និង(២)នៅពេលរដ្ឋកំណត់ភារកិច្ចឲ្យហើយ រដ្ឋមិនអាចចូលធ្វើអន្តរាគមន៍បានឡើយ។
- **ការប្រើប្រាស់សមត្ថកិច្ចស្វយ័ត** មានន័យថាគ្មានរណបឋានុក្រមទេ រវាងរដ្ឋ និងប្រព័ន្ធវិមជ្ឈការ។ គ្មានអំណាចបង្គាប់បញ្ជាទេ។ ប៉ុន្តែ ការត្រួតពិនិត្យរបស់អំណាចកណ្តាលនៅតែមាននូវឡើយ ព្រោះរដ្ឋនៅតែជារដ្ឋទោលដដែល។ ហើយស្វ័យភាពមិនមែនឯករាជ្យភាពទេ។ ការត្រួតពិនិត្យនេះ ត្រូវធ្វើឡើងតាមរបៀបពីរយ៉ាងដែលអង្គការត្រួតពិនិត្យអាចជាអង្គការតុលាការ ឬអាជ្ញាធររដ្ឋបាល។

### ១.១.៤.ទម្រង់ផ្សេងៗនៃវិមជ្ឈការ

ទម្រង់ផ្សេងៗនៃវិមជ្ឈការ មានការកំណត់ជាច្រើនប្រភេទទៅតាមការបោះពុម្ពផ្សាយរបស់បុគ្គលល្បីៗ និងស្ថាប័នផ្សេងៗលើសកលលោក ក្នុងការគ្រប់គ្រងរដ្ឋបាលសធារណៈ។ ចំណែកឯការបោះពុម្ពផ្សាយរបស់ United Nation Development Program (UNDP) ត្រូវបានមកស្រាយយ៉ាងសាមញ្ញនៃទ្រឹស្តីវិមជ្ឈការដោយផ្តោតលើការគ្រប់គ្រងវិស័យសាធារណៈ។ ទម្រង់វិមជ្ឈការនីមួយៗ ត្រូវឈរលើគោលការណ៍អភិបាលកិច្ចល្អ និងអាស្រ័យតាមករណីពិសេសរបស់ប្រទេសនីមួយ។

#### ១.១.៤.១.វិមជ្ឈការរដ្ឋបាល

វិមជ្ឈការរដ្ឋបាល ត្រូវបានគេចាត់ទុកថាមានការទាក់ទងនឹងការអភិវឌ្ឍ គឺជាទម្រង់ទូទៅ និងត្រូវបានគេទទួលស្គាល់ថាជាទម្រង់វិមជ្ឈការ។ វិមជ្ឈការរដ្ឋបាល មានន័យថា ជាការផ្ទេរការទទួលខុសត្រូវក្នុងការរៀបចំផែនការ ការគ្រប់គ្រង និងបែងចែកប្រភពប្រាក់វិភាជន៍ពីរាជរដ្ឋាភិបាល និងភ្នាក់ងារផ្សេងៗរបស់ខ្លួនឲ្យមូលដ្ឋានអង្គភាព ភ្នាក់ងាររាជរដ្ឋាភិបាលមូលដ្ឋាន ស្ថិតក្រោមបង្គាប់របស់រាជរដ្ឋាភិបាល ឬក្រុមហ៊ុនពាក់កណ្តាលស្វយ័តអាជ្ញាធរមុខងារ។

គេអាចហៅថាវិមជ្ឈការរដ្ឋបាលថា វិមជ្ឈការដែនដី។ វិមជ្ឈការដែនដី ត្រូវបានធ្វើឡើងទៅលើនីតិបុគ្គលសាធារណៈដែនដី ដែលមានដែនដីវិសាលភាពទូលំទូលាយ ដូចជាខេត្តដែលហៅថា វិមជ្ឈការផ្តល់ទៅឱ្យអភិបាលកិច្ច ឬសមូហភាពដែនដីវិញ ដែលមិនផ្តោតលើអភិបាលកិច្ច ឬសមូហភាពមូលដ្ឋានទេ។ នីតិបុគ្គលសាធារណៈដែនដី គឺមានក្រុមប្រឹក្សាដែលកើតចេញពីការបោះឆ្នោត ហើយក្រុមប្រឹក្សានេះ ជាអ្នកបោះឆ្នោតជ្រើស

តាំងនាយកប្រតិបត្តិ ដែលជាទូទៅមានអង្គទាំងពីរនេះ មានភារកិច្ច តួនាទីដោយឡែកពីគ្នា គឺក្រុមប្រឹក្សាមានតួ-នាទីជាអ្នកចេញសេចក្តីសំរេចនានា ហើយនាយកប្រតិបត្តិជាអ្នកអនុវត្តន៍សេចក្តីសំរេច។

**១.១.៤.២.វិមជ្ឈការបច្ចេកទេស**

វិមជ្ឈការអំពីមុខងារដែលសិទ្ធិអំណាចមានពីរប្រភេទ គឺវិមជ្ឈការបច្ចេកទេស និងវិមជ្ឈការសេវាកម្ម តម្រូវឱ្យមានការធ្វើវិមជ្ឈការនៅថ្នាក់រដ្ឋបាល។

វិមជ្ឈការបច្ចេកទេស ជារបៀបគ្រប់គ្រងសេវាកម្មសាធារណៈដោយមានការផ្ទេរការទទួលខុសត្រូវអំពីសិទ្ធិអំណាចដឹកនាំគ្រប់គ្រងបច្ចេកទេសណាមួយឲ្យទៅអាជ្ញាធរមួយគ្រប់គ្រងទៅតាមច្បាប់ ក្នុងគោលបំណងបម្រើផលប្រយោជន៍ទូទៅឲ្យមានប្រសិទ្ធភាព។

ក្នុងបរិបទប្រទេសកម្ពុជា វិមជ្ឈការបច្ចេកទេសបានរៀបចំរួចរាល់ហើយ ពោលគឺដែលបានប្រគល់សិទ្ធិអោយគ្រប់គ្រងតាមបែបវិមជ្ឈការបច្ចេកទេសមានដូចជា អាជ្ញាធរកំចាត់មីន អាជ្ញាធរអប្សរា អាជ្ញាធរអគ្គសនីកម្ម រដ្ឋាករទឹក។ល។[៣]

**១.១.៤.៣.វិមជ្ឈការហិរញ្ញវត្ថុ និងសារពើពន្ធ**

ការស្ថាបនានូវប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ការគ្រប់គ្រងហិរញ្ញវត្ថុ គឺជាស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការសម្រេចចិត្តប្រើប្រាស់ធនធានផ្សេងៗ។

ការទទួលខុសត្រូវខាងសារពើពន្ធ គឺជាធាតុផ្សំយ៉ាងសំខាន់នៃវិមជ្ឈការ ព្រោះថារដ្ឋបាលមូលដ្ឋានត្រូវមានប្រាក់ចំណូលគ្រប់គ្រាន់ (ប្រមូលនៅមូលដ្ឋាន និងបញ្ជូនពីថ្នាក់ជាតិ) ដើម្បីធ្វើការសម្រេចក្នុងការចំណាយ។ វិមជ្ឈការសារពើពន្ធមានទម្រង់ជាច្រើន ដែលសរុបជារួមមកមានដូចខាងក្រោម៖

- ហិរញ្ញប្បទានផ្ទាល់ខ្លួន ឬការទូទាត់ចំណាយយកតាមថ្លៃពីអ្នកប្រើប្រាស់
- ការពង្រីកចំណូលនៅមូលដ្ឋាន តាមរយៈការយកពន្ធអាករ និងការយកថ្លៃដោយប្រយោល
- ការផ្ទេរហិរញ្ញប្បទានដែលមានលក្ខណៈអន្តររដ្ឋបាល និង
- ការផ្តល់អំណាចក្នុងការខ្ចីហិរញ្ញប្បទាន ដើម្បីបម្រើផលប្រយោជន៍នៅមូលដ្ឋាន។

**១.១.៤.៤.វិមជ្ឈការនយោបាយ និងប្រជាធិបតេយ្យ**

វិមជ្ឈការនយោបាយ ជាការផ្តល់ឲ្យប្រជាពលរដ្ឋទាំងឡាយធ្វើការបោះឆ្នោតជ្រើសតាំងជាតំណាងពួកគាត់នូវការផ្តល់សិទ្ធិអំណាចច្រើនជាងមុន ក្នុងការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈ។ ទាំងនេះជាការគាំទ្រឱ្យមានការផ្តាច់ចេញនូវអំណាចប្រមូលផ្តុំនៅថ្នាក់កណ្តាល។ ធ្វើបែបនេះ ដើម្បីធានាបាននូវតុល្យភាព និងប្រព័ន្ធត្រួតពិនិត្យចម្រុះក្នុងការអនុវត្តនយោបាយ ដើម្បីមានការអភិវឌ្ឍ។

[៣] ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១៦ ចុះថ្ងៃទី២៥ ខែកម្ភៈ ឆ្នាំ១៩៩៤ ស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

វិមជ្ឈការប្រជាធិបតេយ្យ មានការពាក់ព័ន្ធទៅនឹងការផ្ទេររដ្ឋបាលសារពើពន្ធ អំណាចនយោបាយ គឺដើម្បីឱ្យវិមជ្ឈការទទួលបានជោគជ័យ។ វិមជ្ឈការប្រជាធិបតេយ្យ គឺជាការពង្រឹងយ៉ាងសំខាន់ក្នុងការសម្របសម្រួលដំណើរការរៀបចំ និងការអនុវត្តផែនការនៅមូលដ្ឋាន ហើយក៏ជាវិធីសាស្ត្រមួយ ដើម្បីទំនាក់ទំនងជាមួយអង្គការសង្គមស៊ីវិល និងធ្វើឯកជនសាកលភាវូបនីយកម្មផងដែរ។ វិមជ្ឈការប្រជាធិបតេយ្យ អាចជាដំណើរការដែលឈានទៅរកការបង្កើតឱ្យមានប្រជាធិបតេយ្យនៅមូលដ្ឋាន ធ្វើឱ្យប្រជាពលរដ្ឋមានការចូលរួមនៅ មូលដ្ឋានក្នុងកិច្ចការងារអភិវឌ្ឍន៍មូលដ្ឋាន និងសង្គមជាតិ។

## ១.២.ការរៀបចំរដ្ឋបាលឃុំ សង្កាត់

### ១.២.១.ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនតាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះដោយសម្ងាត់។ ការបោះឆ្នោតនេះ ត្រូវបានធ្វើឡើងរៀងរាល់៥ឆ្នាំម្តង ដោយការបោះឆ្នោតនៅគ្រប់ឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងនៅថ្ងៃអាទិត្យតែមួយថ្ងៃគត់។[៤] ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តន៍តាមប្រព័ន្ធសមាមាត្រដោយមានការបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុត ក្រោមសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។ ដំណើរការប្រព្រឹត្តិទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងត្រូវបានរៀបចំតាមលំដាប់លំដោយដូចតទៅ៖

#### ១.២.១.១.ការចុះឈ្មោះបេក្ខជនបោះឆ្នោត

បេក្ខជនដែលមានបំណងឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជូនឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណៈបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ស្តីពីគណៈបក្សនយោបាយ។[៥] បន្ទាប់មកគណៈបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលចុះហត្ថលេខាដោយប្រធានគណៈបក្សនយោបាយ ឬតំណាងដែលទទួលបានការផ្ទេរសិទ្ធិទៅជាគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងតិច ៩០ថ្ងៃ មុនថ្ងៃបោះឆ្នោតដោយមានភ្ជាប់មកជាមួយនូវបញ្ជីរាយនាមបេក្ខជនដែលមានចំនួនយ៉ាងហោចណាស់ស្មើនឹងពីរដងនៃចំនួនសមាជិករបស់ក្រុមប្រឹក្សាឃុំសង្កាត់។ ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរពីកំណើត

[៤] មាត្រា៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៦

[៥] មាត្រា៤៩ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៦

- ចេះអាន និងសរសេរអក្សរខ្មែរ
- ចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

• **ចំណែកជនត្រូវហាមមិនអោយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់** រួមមាន៖

- សមាជិករដ្ឋសភា ព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិករដ្ឋាភិបាល និងចៅក្រម
- ប្រតិភូរាជរដ្ឋាភិបាល អភិបាល ឬអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បុគ្គលិកបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែង
- ព្រះសង្ឃ ឬបុព្វសាសនា
- ស្មៀនឃុំ សង្កាត់

**១.២.១.២.ការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អោយបានយ៉ាងតិច ៩០ថ្ងៃមុនថ្ងៃបោះឆ្នោត។[៦] បន្ទាប់ពីរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់រួច គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់រយៈពេលនៃការត្រួតពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗមិនត្រូវតិចជាង ១៥ថ្ងៃឡើយ។

ដើម្បីមានសិទ្ធិចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានអាយុ ១៨ឆ្នាំ ឡើងគិតមកដល់ថ្ងៃបោះឆ្នោត
- មិនស្ថិតក្នុងស្ថានភាពជាទណ្ឌិត ឬស្ថានភាពជាជនវិកលចរិកជាដើម។[៧]

**១.២.២.រចនាសម្ពន្ធ និងតួនាទីរបស់រដ្ឋបាលឃុំ សង្កាត់**

រដ្ឋបាលឃុំ សង្កាត់នីមួយៗមានរចនាសម្ពន្ធជាក់លាក់របស់ខ្លួន ដោយផ្អែកតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

[៦] មាត្រា៤៣ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៦

[៧] មាត្រា១៩ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៦

**១.២.២.១.ក្រុមប្រឹក្សាឃុំ សង្កាត់**

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិក៥, ៧, ៩ ឬ១១នាក់ ផ្អែកតាមភូមិសាស្ត្រ និងចំនួនប្រជាជនដែលកំពុងរស់នៅក្នុងឃុំ សង្កាត់នោះ។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ។ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានប្រធានមួយរូប ដែលហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ហើយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់គឺ ជាមេឃុំ ឬចៅសង្កាត់។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាន និងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ។[៤]

- **សមាជិក កបឃ.ស** មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ធានាក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់អំណាចតួនាទី និងមុខងារដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ
- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋ។

**១.២.២.២.មេឃុំ ឬចៅសង្កាត់**

ឃុំ សង្កាត់នីមួយៗមានមេឃុំ ឬចៅសង្កាត់មួយនាក់។ ស្ត្រី និងបុរសអាចត្រូវបានជ្រើសរើសឱ្យធ្វើជាមេឃុំ ឬចៅសង្កាត់។ មេឃុំ ឬចៅសង្កាត់មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ធានាថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្តន៍
- រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការរៀបចំហិរញ្ញវត្ថុ និងការអនុវត្តអំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឱ្យ
- ផ្ទេរសិទ្ធិដល់ជំទប់ ឬចៅសង្កាត់រងតាមឋានានុក្រមនៅពេលខ្លួនអវត្តមាន។[៥]

---

[៤] មាត្រា១៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[៥] ដកស្រង់ចេញពីសៀវភៅ ការគ្រប់គងរដ្ឋបាលឃុំ សង្កាត់ តាមបែបវិមជ្ឈការ ឆ្នាំ២០១៧ ទំព័រទី១៣

**១.២.២.៣.ជំទប់ឃុំ ឬចៅសង្កាត់រង**

មេឃុំ ឬចៅសង្កាត់ត្រូវមានជំនួយការ ២រូបចាំបាច់គឺ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ ដែលមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- **ជំទប់ទី១ ឬចៅសង្កាត់រងទី១**

– ទទួលជួយមេឃុំ ឬចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

– មេឃុំ ឬចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមដល់ជំទប់ទី១ ឬចៅសង្កាត់រងទី១

– បំពេញការងារជាមេឃុំ ឬចៅសង្កាត់ស្ដីទីករណីមេឃុំ ឬចៅសង្កាត់អវត្តមាន។

- **ជំទប់ទី២ ឬចៅសង្កាត់រងទី២**

– ជួយមេឃុំ ឬចៅសង្កាត់ក្នុងការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និងកិច្ចការសណ្ដាប់ធ្នាប់សាធារណៈនៅក្នុងមូលដ្ឋាន

– មេឃុំ ឬចៅសង្កាត់អាចប្រគល់លើការងារបន្ថែមដល់ជំទប់ទី២ ឬចៅសង្កាត់រងទី២

– បំពេញការងារជាមេឃុំ ឬចៅសង្កាត់ស្ដីទី ក្នុងករណីមេឃុំ ឬចៅសង្កាត់ និងជំទប់ទី១ និងចៅសង្កាត់-រងទី១ អវត្តមាន។

**១.២.២.៤.គណៈកម្មាធិការនានា**

មេឃុំ ឬចៅសង្កាត់ អាចចាត់តាំងគណៈកម្មាធិការផ្តល់យោបល់។ គណៈកម្មាធិការនេះមានសមាជិកយ៉ាងតិច ០៣ នាក់ (អាចយកក្នុងចំណោមសមាជិកក្រុមប្រឹក្សា) ដើម្បីផ្តល់យោបល់ និងជួយការងារដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ឬចៅសង្កាត់អំពីបញ្ហាជាក់លាក់ណាមួយ។

គណៈកម្មាធិការនានាមានតួនាទី ភារកិច្ចដូចខាងក្រោម៖

– ផ្តល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដូចជា ការកសាងផែនការអភិវឌ្ឍន៍ និងថវិកា (គណៈកម្មាធិការកសាងផែនការ និងថវិកា) ជាដើម

– រាយការណ៍អំពីការអភិវឌ្ឍប្រចាំខែរបស់ខ្លួន

– ផ្តល់យោបល់ពីវិធានការត្រូវអនុវត្តន៍ដែលពាក់ព័ន្ធនឹងការងារ។

**១.២.២.៥.ស្មៀនឃុំ សង្កាត់**

ឃុំ សង្កាត់ នីមួយៗមានស្មៀនមួយរូបដែលត្រូវបានតែងតាំង និងបម្រើការងារស្ថិតនៅក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាលនៃក្រសួងមហាផ្ទៃ។ ស្មៀនឃុំ សង្កាត់ទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ មានន័យថា ការអនុវត្តការងាររបស់ស្មៀនឃុំ សង្កាត់ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់មានតួនាទីដូចខាងក្រោម៖

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងគណៈកម្មាធិការនានាបំពេញតួ-នាទី និងមុខងារស្របតាមតម្រូវការច្បាប់
- បំពេញការងាររដ្ឋបាល
- ធានាថាសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ស្របទៅនឹងលក្ខខណ្ឌច្បាប់
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តន៍កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ឃុំ សង្កាត់
- ចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណៈកម្មាធិការ លើកលែងតែបានទទួលការអនុញ្ញាតឱ្យអវត្តមានជាមុនពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់
- ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំឱ្យមានក្តារខៀនព័ត៌មានមួយ ឬច្រើនកន្លែង ដើម្បីបិទផ្សាយសេចក្តីជូនដំណឹង សេចក្តីសម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។[១០]

**១.២.២.៦.បុគ្គលិកឃុំ សង្កាត់**

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិក ដើម្បីជួយកិច្ចការរបស់ខ្លួនបាន ប៉ុន្តែបុគ្គលិកប្រភេទនេះ ជាបុគ្គលិកដែលស្ថិតនៅក្រៅក្របខណ្ឌរដ្ឋ។ ការជ្រើសរើសនេះ ធ្វើឡើងតាមរយៈការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នោះផ្ទាល់។ បុគ្គលិកឃុំ សង្កាត់មានភារកិច្ចជួយកិច្ចការតាមសេចក្តីត្រូវការចាំបាច់នៃការងារ និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់។[១១]

**១.២.២.៧.មេភូមិ**

ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិមួយនាក់ សម្រាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន។ មេភូមិត្រូវមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់ក្នុងភូមិ
- ជាអ្នកទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់
- ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់
- ចូលរួមក្នុងកិច្ចប្រជុំនានារបស់ឃុំ សង្កាត់នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវ ដើម្បីផ្តល់យោបល់អំពីកិច្ចការពាក់ព័ន្ធនឹងភូមិរបស់ខ្លួន

[១០] ប្រកាសលេខ ១៣២៩ ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ ស្តីពី តួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់

[១១] មាត្រា២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

- ធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់ចូលរបាយការណ៍ ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់ព័ត៌មានដែលពាក់ព័ន្ធនឹងភូមិដល់ប្រជាពលរដ្ឋរបស់ខ្លួន
- ទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឱ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

### ១.២.៣.តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់

ផ្អែកតាមបញ្ញត្តិនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្ទេរឱ្យនូវតួនាទី មុខងារ និងអំណាចមួយចំនួនសម្រាប់បម្រើប្រជាពលរដ្ឋ និងការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួន។

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជម្រុញ និងគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធានប្រកបដោយចីរភាព សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍ជាតិ ស្របតាមគោលនយោបាយទូទៅរបស់រដ្ឋ។[១២]

#### ១.២.៣.១.អំណាចរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំដោយក្រុមប្រឹក្សាឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។

- **អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់** ស្តែងតាមរយៈដីកាឃុំ សង្កាត់ តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តន៍តែនៅក្នុងរង្វង់ដែនដីរបស់ខ្លួនតែប៉ុណ្ណោះ។
- **អំណាចប្រតិបត្តិរបស់ឃុំ សង្កាត់** មានន័យថារដ្ឋបាលឃុំ សង្កាត់មានសិទ្ធិអនុវត្តន៍សេចក្តីសម្រេចរបស់ខ្លួននៅក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។

រដ្ឋបាលឃុំ សង្កាត់អាចធ្វើសកម្មភាពតែនៅក្នុងក្របខណ្ឌអំណាច តួនាទី និងមុខងារដែលច្បាប់បានប្រគល់ឱ្យតែប៉ុណ្ណោះ។ មានន័យថា រដ្ឋបាលឃុំ សង្កាត់មិនអាចធ្វើផ្ទុយពីគោលការណ៍ និងបញ្ញត្តិដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាឡើយ។ រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសម្រេចលើវិស័យៈ ព្រៃឈើ ប្រៃសណីយ៍ និងទូរគមនាគមន៍ ការពារប្រទេស សន្តិសុខជាតិ រូបិយ-វត្ថុ នយោបាយក្រៅប្រទេស គោលនយោបាយសារពើពន្ធ និងវិស័យផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់លិខិតបទដ្ឋានដែលពាក់ព័ន្ធ។[១៣]

[១២] មាត្រា៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[១៣] មាត្រា៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

**១.២.៣.២.តួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់**

រដ្ឋបាលឃុំ សង្កាត់នីមួយៗមានតួនាទីពីរប្រភេទគឺ តួនាទីបម្រើកិច្ចការមូលដ្ឋាន និងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ។

- **តួនាទីបម្រើកិច្ចការមូលដ្ឋាន**

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការទទួលខុសត្រូវឱ្យកិច្ចការទាំងនោះ ដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។[១៤]

- **តួនាទីជាភ្នាក់ងារតំណាងរដ្ឋ**

រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តន៍ទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្តត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកាសម្រាប់អនុវត្តន៍។ ប្រតិភូកម្មនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ។ ឧទាហរណ៍៖ ការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់។

## ១.៣.កិច្ចការរដ្ឋបាលឃុំ សង្កាត់

កិច្ចការរដ្ឋបាលរបស់ឃុំ សង្កាត់មានដូចជា លិខិតបទដ្ឋានគតិយុត្ត លិខិតរដ្ឋបាល ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងឯកសារ ការគ្រប់គ្រងសម្ភារៈបរិក្ខារ និងការរៀបចំកិច្ចប្រជុំជាដើម។

### ១.៣.១.លិខិតបទដ្ឋានគតិយុត្តឃុំ សង្កាត់

លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់ គឺជាលិខិតដែលកំណត់នូវវិធាន បទបញ្ញត្តិ បទបញ្ជា ឬគោលការណ៍នានាសម្រាប់ការគ្រប់គ្រង ការតាក់តែង ការបង្កើតឡើងនូវយន្តការ និងការណែនាំអនុវត្តន៍កិច្ចការនានា។ ប្រភេទលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់មានដូចជា៖

[១៤] មាត្រា៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

**១.៣.១.១.ដីកាឃុំ សង្កាត់**

ដីកាឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលកំណត់នូវបទប្បញ្ញត្តិទាំងឡាយដែលរដ្ឋបាលឃុំ សង្កាត់បង្កើតឡើង សំដៅបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅក្នុងឃុំ សង្កាត់ដោយស្មើភាព មិនរើសអើង និងសម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តន៍ក្នុងរង្វង់ដែនដីរបស់ខ្លួន។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនិងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋឡើយ។ ដីកាឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ឬចៅសង្កាត់ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

**១.៣.១.២.សេចក្តីសម្រេចឃុំ សង្កាត់**

សេចក្តីសម្រេចឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលបង្កើតឡើង ដើម្បីអនុវត្តន៍ដីការបស់ខ្លួន ឬលិខិតបទដ្ឋាននានារបស់រដ្ឋ ឬចែងអំពីការបង្កើត ការតែងតាំង ការរៀបចំ ឬការគ្រប់គ្រងកិច្ចការនានាក្នុងក្រប-ខណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តន៍ក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន។

សេចក្តីសម្រេចមានលក្ខណៈប្រហាក់ប្រហែល និងដីកាឃុំ សង្កាត់ដែរ ប៉ុន្តែមានឋានានុក្រមទាបជាងដីកា និងខ្ពស់ជាងលិខិតរដ្ឋបាលសាមញ្ញធម្មតាផ្សេងៗទៀតក្នុងឃុំ សង្កាត់។ សេចក្តីសម្រេចឃុំ សង្កាត់មិនត្រូវផ្ទុយនិងច្បាប់ ឬលិខិតបទដ្ឋាននានារបស់រដ្ឋ និងដីការបស់ខ្លួនឡើយ។ សេចក្តីសម្រេចឃុំ សង្កាត់ត្រូវចុះហត្ថ-លេខាដោយ មេឃុំ ឬចៅសង្កាត់តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

ករណីមានប្រធានសក្តិ និងបន្ទាន់បំផុតដែលមិនអាចកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បាន មេឃុំ ចៅសង្កាត់អាចចេញសេចក្តីសម្រេច ដើម្បីដោះស្រាយស្ថានភាពបន្ទាន់នោះ។ សេចក្តីសម្រេចនេះ និងត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នៅកិច្ចប្រជុំបន្ទាប់ ដើម្បីពិនិត្យឡើងវិញអំពីភាពមិនត្រឹមត្រូវតាមច្បាប់។[១៥]

**១.៣.២.លិខិតរដ្ឋបាលឃុំ សង្កាត់**

លិខិតរដ្ឋបាល គឺជាលិខិតដែលរៀបចំតាក់តែងឡើងជាលាយលក្ខណ៍អក្សរសម្រាប់ជាមធ្យោបាយទំនាក់ទំនងផ្លូវការរបស់រដ្ឋបាលឃុំ សង្កាត់ជាមួយស្ថាប័ន អង្គភាព និងបុគ្គលនានា ក្នុងគោលបំណងជូនព័ត៌មាន អញ្ជើញ រាយការណ៍ ផ្សព្វផ្សាយ ឆ្លើយតប ឬចាត់តាំងបុគ្គលណាមួយឱ្យទៅបំពេញបេសកកម្ម។

លិខិតរដ្ឋបាលឃុំ សង្កាត់ដែលប្រើប្រាស់ជាផ្លូវការរួមមាន លិខិតស្នើ លិខិតជូនដំណឹង ឬសេចក្តីជូនដំណឹង លិខិតអញ្ជើញ លិខិតបញ្ជាបេសកកម្ម របាយការណ៍ កំណត់ហេតុ លិខិតផ្ទេរសិទ្ធិ និងដីកាអម។

[១៥] ដកស្រង់ចេញពីសៀវភៅ ការគ្រប់គងរដ្ឋបាលឃុំ សង្កាត់ តាមបែបវិមជ្ឈការ ឆ្នាំ២០១៧ ទំព័រ ២២

- **លិខិតស្នើ** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីបង្ហាញពីគោលបំណង និងមូលហេតុនៃតម្រូវការជាក់លាក់ណាមួយដែលខ្លួនថ្លែងទៅកាន់រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈ ឯកជន ក្រសួង ស្ថាប័នអង្គការ ឬសង្គមស៊ីវិលដែលមានសិទ្ធិអំណាចសម្រេច ឬដោះស្រាយចំពោះការស្នើសុំនោះ។
- **សេចក្តីជូនដំណឹង** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការទំនាក់ទំនងជាមួយបុគ្គល ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលមានខ្លឹមសារជាការឆ្លើយបំភ្លឺចំពោះបញ្ហា ឬជាការឆ្លើយតបចំពោះសំណើ ឬជូនដំណឹងឱ្យសាធារណៈបានដឹងព័ត៌មានទាំងឡាយដែលឃុំ សង្កាត់ត្រូវការផ្សព្វផ្សាយ។
- **លិខិតអញ្ជើញ** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីអញ្ជើញបុគ្គល តំណាងក្រសួង ស្ថាប័នអង្គការសង្គមស៊ីវិលឱ្យចូលរួមក្នុងសកម្មភាពរបស់ឃុំ សង្កាត់ ចំពោះកិច្ចការដែលពាក់ព័ន្ធទៅនឹងបុគ្គល ឬអង្គភាពទាំងនោះ ដោយមានបញ្ជាក់ឈ្មោះ និងឋានៈ (អ្នកដែលត្រូវអញ្ជើញ) ទីកន្លែងប្រជុំ ឬប្រារព្ធ កាលបរិច្ឆេទកម្មវិធី ឬរបៀបវារៈប្រជុំ (និងអាចមានឯកសារដែលពាក់ព័ន្ធនឹងការប្រជុំភ្ជាប់ជាមួយ)។
- **លិខិតបញ្ជាបេសកកម្ម** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីចាត់តាំងមន្ត្រី បុគ្គលិកឃុំ សង្កាត់ឱ្យចូលរួមក្នុងសកម្មភាពនានានៅក្រៅឃុំ សង្កាត់។ លិខិតនេះមានភ្ជាប់ជាមួយទិដ្ឋាការពេលធ្វើដំណើរ។ ទិដ្ឋាការធ្វើដំណើរ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ឱ្យអ្នកដែលមានភារៈកិច្ចទៅបំពេញបេសកកម្ម យកទៅចុះទិដ្ឋាការនៅទីកន្លែង កាលបរិច្ឆេទ មធ្យោបាយធ្វើដំណើរ និងហត្ថលេខារបស់អង្គភាពដែលមានសមត្ថកិច្ចដែលបានអនុញ្ញាត និងអង្គភាពដែលទទួលដឹងឮ អំពីការចេញដំណើរ និងការមកដល់ពីដំណាក់មួយទៅដំណាក់មួយទៀត។ នៅពេលត្រឡប់មកវិញ ត្រូវធ្វើរបាយការណ៍ ឬរាយការណ៍ជូនមេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបានជ្រាបអំពីលទ្ធផល ឬបញ្ហាសំខាន់ៗដែលខ្លួនបានទៅចូលរួម។
- **របាយការណ៍** គឺជាសេចក្តីរាយការណ៍អំពីសកម្មភាព ដំណើរការ និងលទ្ធផលការងាររបស់ឃុំ សង្កាត់ ឬបុគ្គលិកណាម្នាក់ ឬមួយក្រុមដែលរដ្ឋបាលឃុំ សង្កាត់បានបំពេញ ឬឃុំ សង្កាត់បានចាត់តាំងឱ្យទៅបំពេញ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធ។
- **កំណត់ហេតុ** គឺជាការកត់ត្រា ស្រង់មតិយោបល់ សេចក្តីសម្រេច និងការឯកភាពលើសកម្មភាព ដែលត្រូវអនុវត្តន៍ពីគ្រប់សមាជិកអង្គប្រជុំ និងការសម្រេចរបស់អង្គប្រជុំ ឬជាការកត់ត្រារាល់ហេតុការណ៍ណាមួយដែលបានកើតឡើងជាក់ស្តែង ដើម្បីរក្សាទុកជាសក្ខីភាពនៅពេលដែលមានតម្រូវការ។

- **លិខិតផ្ទេរសិទ្ធិ** គឺជាលិខិតរបស់មេឃុំ ឬចៅសង្កាត់ប្រកាសជាលាយលក្ខណ៍អក្សរប្រគល់សិទ្ធិឱ្យទៅជំទប់ ចៅសង្កាត់រងតាមឋានានុក្រម ដើម្បីធ្វើជាមេឃុំ ឬចៅសង្កាត់ស្តីទីក្នុងកំឡុងពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន។
- **ដីការអម** គឺជាឯកសាររដ្ឋបាលដែលឃុំ សង្កាត់រៀបចំឡើងផ្ញើអមភ្ជាប់ជាមួយសំណុំលិខិត ដែលត្រូវផ្ញើចេញទៅឱ្យអង្គភាព ក្រសួង ស្ថាប័នណាមួយដោយមានកត់ត្រាឈ្មោះ និងចំនួនលិខិត (ឯកសារ) លើដីការអមនោះ។ ឃុំ សង្កាត់ប្រើដីការអម ដើម្បីជៀសវាងការបាត់បង់ឯកសារដែលរដ្ឋបាលឃុំ សង្កាត់ផ្ញើចេញ។

### ១.៣.៣.ការគ្រប់គ្រងបុគ្គលិក ឯកសារ និងសម្ភារបរិក្ខាររបស់ឃុំ សង្កាត់

#### ១.៣.៣.១.ការគ្រប់គ្រងបុគ្គលិក

រដ្ឋបាលឃុំ សង្កាត់មានបុគ្គលិកពីរប្រភេទ គឺស្មៀនដែលរាជរដ្ឋាភិបាលបានបញ្ជូនឱ្យមកធ្វើការក្នុងឃុំ សង្កាត់ និងបុគ្គលិករបស់ឃុំ សង្កាត់ផ្ទាល់។ ស្មៀនឃុំគ្មានសិទ្ធិគ្រប់គ្រងលើបុគ្គលិកផ្ទាល់របស់ក្រុមប្រឹក្សាឃុំទេ។ ករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនមានភាពមិនចុះសម្រុងគ្នា ក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិស្នើសុំផ្លាស់ប្តូរស្មៀន ហើយក្រសួងមហាផ្ទៃត្រូវតែឆ្លើយតបជាវិជ្ជមានចំពោះការស្នើសុំនេះ។ ដូច្នេះការចាត់ចែងរបៀបនេះនាំឱ្យមានតុល្យភាពអំណាចរវាងក្រុមប្រឹក្សា និងស្មៀនឃុំ ក្នុងការងាររដ្ឋបាលប្រចាំថ្ងៃ និងការធ្វើសេចក្តីសម្រេចនានា។

ក្របខណ្ឌច្បាប់មិនបានចែងលំអិតអំពីប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ទេ ច្បាប់គ្រាន់តែបញ្ជាក់ថាក្រុមប្រឹក្សាអាចជួលបុគ្គលិករបស់ខ្លួនផ្ទាល់ ស្ថិតក្រោមការចាត់ចែងសព្វថ្ងៃនេះក្រុមប្រឹក្សាឃុំ សង្កាត់អាចជួលគណនេយ្យករអោយជួយគ្រប់គ្រងចំណូលដែលឃុំរកបាន។

#### ១.៣.៣.២.ការគ្រប់គ្រងឯកសារ

ការគ្រប់គ្រងឯកសារ គឺជាការរៀបចំទុកដាក់ និងថែរក្សាឯកសារទាំងឡាយតាមប្រព័ន្ធមួយដែលមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព។

ការគ្រប់គ្រងឯកសាររបស់ឃុំ សង្កាត់ផ្តល់ផលប្រយោជន៍មួយចំនួនដូចជា៖

- បង្ករលក្ខណៈងាយស្រួលក្នុងការស្វែងរកព័ត៌មាន និងទិន្នន័យសម្រាប់ដឹកនាំនៅក្នុងការពិភាក្សា និងការធ្វើសេចក្តីសម្រេច
- ជួយបន្តនិរន្តរភាពព័ត៌មាននៅពេលមានអ្នកមកកាន់ការងារថ្មី និងអ្នកផ្លាស់ចេញ
- ផ្តល់នូវភស្តុតាងជាក់លាក់ពីកិច្ចការ ឬព្រឹត្តិការណ៍ដែលកើតរួចមកហើយ
- បង្កើនប្រសិទ្ធភាព និងសន្សំពេលវេលាដល់ការងាររដ្ឋបាលឃុំ សង្កាត់។

**១.៣.៣.៣.ការគ្រប់គ្រងសម្ភារបរិក្ខារ**

គ្រប់សម្ភារបរិក្ខាររបស់ឃុំ សង្កាត់ត្រូវចុះបញ្ជីអោយបានត្រឹមត្រូវ។ ចំពោះបញ្ជីគ្រប់គ្រងសម្ភារបរិក្ខារនេះត្រូវរក្សាទុកឱ្យបានល្អ ប្រកបដោយសុវត្ថិភាព និងធ្វើបច្ចុប្បន្នភាពជាប្រចាំ។ គ្រប់សម្ភារបរិក្ខាររបស់ឃុំ សង្កាត់ដែលកាត់ចេញពីបញ្ជីត្រូវធ្វើឡើងស្របតាមនីតិវិធី និងត្រូវសម្រេចដោយអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

**១.៣.៤.ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់**

**១.៣.៤.១.លិខិតអញ្ជើញ**

មេឃុំ ចៅសង្កាត់ត្រូវធានាថា លិខិតអញ្ជើញត្រូវបានរៀបចំ និងផ្ញើជូនដល់អ្នកត្រូវបានចូលរួមកិច្ចប្រជុំគ្រប់គ្នាទាំងអស់ឱ្យបានមុនពេលប្រជុំ។

លិខិតអញ្ជើញត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់អំពី ពេលវេលា ទីកន្លែង និងបញ្ហាសំខាន់ដែលត្រូវពិភាក្សា ឬជំរាបនៅពេលប្រជុំ និងឯកសារពាក់ព័ន្ធដែលភ្ជាប់ជាមួយលិខិតអញ្ជើញ។

**១.៣.៤.២.ការបង្កើតរបៀបវារៈប្រជុំ**

គ្រប់ប្រជុំទាំងអស់ត្រូវមានរបៀបវារៈ ហើយត្រូវផ្ញើជូនដល់អ្នកចូលរួមជាមុន។ ជាការប្រសើរដល់អ្នកចូលរួមមានឱកាសចូលរួមក្នុងការរៀបរបៀបវារៈ។

ចំណុចមួយចំនួនដែលយើងគួរលើកមកក្នុងការបង្កើតរបៀបវារៈរួមមានដូចជា៖

- ការងារដែលត្រូវពិភាក្សា និងសម្រេច
- ព័ត៌មានដែលត្រូវជំរាប
- ពេលវេលាសម្រាប់កិច្ចប្រជុំ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ច្រើនជាងមួយភាគបីអាចបន្ថែមប្រធានបទផ្សេងទៀតដែលស្ថិតនៅក្នុងអំណាច និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

**១.៣.៤.៣.ការផ្សព្វផ្សាយអំពីកិច្ចប្រជុំដល់សាធារណជន**

កាលបរិច្ឆេទ និងទីកន្លែងនៃកិច្ចប្រជុំ ត្រូវផ្សព្វផ្សាយជាសាធារណៈដោយបិតផ្សាយនៅលើក្តារខៀនព័ត៌មានឃុំ សង្កាត់ និងនៅកន្លែងសាធារណៈក្នុងភូមិទាំងអស់ និងមធ្យោបាយផ្សព្វផ្សាយសមស្របដែលមាននៅមូលដ្ឋានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

# ជំពូកទី២

# ដំណើរការគ្រប់គ្រងរដ្ឋបាលរបស់ឃុំទឹកល្អក់

## ២.១.ប្រវត្តិ និងស្ថានភាពទូទៅ

ឃុំទឹកល្អក់ ជាឃុំមួយដែលបានកកើតតាំងពីយូរលង់ណាស់មកហើយ ពោលគឺមុនសម័យអាណានិគមនិយមបារាំងមកម្ល៉េះ។ បើតាមការរៀបរាប់របស់លោក ចក់ សារិន ដែលជាមេឃុំទឹកល្អក់ផ្ទាល់បានមានប្រសាសន៍ថា ឃុំទឹកល្អក់នេះគ្មានប្រវត្តិជាក់លាក់ទេ គ្រាន់តែដឹងតាមចាស់ៗដំណាលតៗគ្នាមកថា ដើមឡើយគ្មានឃុំទឹកល្អក់ទេ ប្រជាពលរដ្ឋបានមករស់នៅម្តុំវត្តត្រពាំងឫស្សី ប៉ុន្តែដោយសារកើតមានជំងឺអាសន្នរោគទើបធ្វើអោយប្រជាជននាំគ្នាផ្លាស់ប្តូរទីលំនៅមករស់នៅ ភូមិស្ទួលជ្រុំ និងភូមិព្រៃកន្ទោច ហើយខ្លះទៀតទៅរស់នៅដីទួលមួយនៅក្បែរនោះ ដោយសារតែខ្វះទឹកប្រើប្រាស់តាម្នាក់ (មិនស្គាល់ឈ្មោះពិតប្រាកដ) បានជីកដីធ្វើត្រពាំងមួយយ៉ាងជ្រៅដើម្បីបានទឹកប្រើប្រាស់ ដោយឱ្យឈ្មោះថា ត្រពាំងថ្មីក បន្ទាប់ពីជីកបានរួចរាល់ សម្រាប់ប្រើប្រាស់ទឹកត្រពាំងនោះមានទឹកមិនថ្លាសោះគឺល្អក់រហូត ហើយក៏ចេះតែនាំគ្នាប្រើប្រាស់រហូតមក បន្ទាប់មកបានប្តូរឈ្មោះត្រពាំងនោះពីត្រពាំងថ្មីក មកជាត្រពាំងទឹកល្អក់វិញ។ សម័យក្រោយៗមកទៀតរដ្ឋាភិបាលធ្វើការជ្រើសរើស ឃុំ និងមេឃុំម្នាក់ ដោយសម្រេចជ្រើសរើសយកម្នាក់ក្នុងចំណោមមនុស្សម្នាក់ៗមកពីគ្រប់ភូមិ ហើយក្នុងចំណោមនោះមានតាម្នាក់មកពីភូមិទឹកល្អក់ជាអ្នកជាប់បានក្លាយជាមេឃុំ ហើយត្រូវបានប្រជាជនហៅតៗគ្នាថាតាមេឃុំមកពីភូមិទឹកល្អក់ លុះយូរទៅហៅកាត់មកត្រឹម តាមេឃុំទឹកល្អក់។ក្រោយមក ដោយសារស្រុកមានការប្រែប្រួលមានសន្តិភាព និងភាពសម្បូរសប្បាយនៅទីនេះក៏បង្កើតអោយមានរដ្ឋបាលឃុំសង្កាត់ហើយបានផ្លាស់ប្តូរឈ្មោះជាផ្លូវការមកជាឃុំទឹកល្អក់វិញ ចំណែកឯទួល និងត្រពាំងទឹកល្អក់សព្វថ្ងៃរាក់ត្រូវបានប្រជាពលនាំគ្នាបង្កបង្កើនផលនៅទីនោះអស់ ដោយបន្សល់ត្រឹមតែឈ្មោះនិងប្រវត្តិខ្លះៗទុកប្រាប់កូនចៅជំនាន់ក្រោយតែប៉ុណ្ណោះ។ សព្វថ្ងៃនេះឃុំទឹកល្អក់ ជាឃុំមួយក្នុងចំណោមឃុំទាំង ១៣ នៃស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ឃុំនេះ មានភូមិសាស្ត្រ និងប្រជាសាស្ត្រអំណោយផលល្អបង្គួរ អាចឱ្យប្រជាពលរដ្ឋមានមុខរបរសមស្របអាចចិញ្ចឹមគ្រួសារបាន។ មិនតែប៉ុណ្ណោះ មានការរីកចម្រើនផ្នែកសេដ្ឋកិច្ចឆាប់រហ័សជាកត្តាកាត់បន្ថយភាពក្រីក្រនៅក្នុងមូលដ្ឋាន។

### ២.១.១.ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ

ឃុំទឹកល្អក់ មានព្រំប្រទល់ខាងលិច និងខាងត្បូងជាប់នឹងឃុំស្រង់ ខាងកើតមានព្រំប្រទល់ជាប់នឹងឃុំព្រៃញាតិ ខ័ណ្ឌដោយផ្លូវជាតិលេខ ៤១ ខាងជើងទល់នឹងឃុំពេជមុន្នី មានផ្ទៃដីសរុប ១៥៤២,០៣ គីឡូម៉ែត្រការ៉េ ក្នុងនោះដីស្រែមាន ៨០៧ ហិកតា ដីចំការមាន ៤,១២៥ ហិកតា ដីលំនៅដ្ឋានមាន ១១៧,៩០ ហិកតា និងដីភ្នំ ៤៧៩,២៧ ហិកតា។ មានផ្លូវគមនាគមន៍ចំនួន ០៤ ខ្សែ មានប្រវែង ១៩,០០០ ម៉ែត្រ ផ្លូវកៅស៊ូមានប្រវែង ៣,០០០ ម៉ែត្រ និងផ្លូវសាងសង់ពីបេតុងគ្មាន។ ឃុំទឹកល្អក់មានភូមិចំនួន ១២ភូមិ ក្នុងនោះរួមមានភូមិ ច្រេស ភូមិ

ចំបកក្អែរ ភូមិសន្លង់ ភូមិអង្គដូនពិស ភូមិប្រវឹកពង ភូមិក្បាលដំរី ភូមិបឹងងោង ភូមិព្រៃកន្ទោច ភូមិតាងៅ ភូមិស្នួលជ្រុំ និងភូមិត្រាវ។ ចំពោះស្ថិតិប្រជាជនមានសរុបចំនួន ៦,៩៨១នាក់ ចំនួនគ្រួសារសរុបមាន ១,៥៧៥ គ្រួសារ ប្រជាពលរដ្ឋជាស្រីមានចំនួន ៣,៤២៦នាក់ មានប្រជាពលរដ្ឋអាយុ ១៨ឆ្នាំឡើងចំនួន ៤,៨៩៨ និងមានប្រជាពលរដ្ឋចំណាកស្រុកចំនួន ៦៥នាក់។

### ២.១.២.ស្ថានភាពសេដ្ឋកិច្ច

ឃុំទឹកល្អក់ មានសណ្ឋានដីតំបន់ជាវាលទំនាបកណ្តាល មានបឹងបួរ ប្រឡាយទឹកស្រោចស្រពជាច្រើនខ្សែរ ដែលអំណោយផលដល់ការធ្វើកសិកម្ម។

ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំទឹកល្អក់ មានចំនួន៥០% ជាកសិករធ្វើស្រែចំការ ក្រៅពីវិស័យកសិកម្មដែលជាស្នូល និងជាចម្បង ប្រជាជនក៏មានមុខរបរបន្ទាប់បន្សំធ្វើការជាមន្ត្រីរាជការ នៅតាមអង្គភាពរដ្ឋជុំវិញស្រុកគងពិសី ប្រកបមុខរបរធ្វើជំនួញ លក់ដូរ ធ្វើជាងសង្ហារិម កម្មករ កម្មការនីរោងចក្រ រត់ម៉ូតូឌុប ម៉ូតូកង់បីនៅទីក្រុង ធ្វើចំការ ដាំបន្លែបង្ការ និងដំណាំផ្សេងៗ មុខរបរចិញ្ចឹមសត្វ (គោ ជ្រូក មាន់ ទា) និងមានមុខរបរសិប្បកម្មឡើងត្នោតដែលជាមូលដ្ឋានបង្កើតការងារជូនប្រជាពលរដ្ឋជាដើម។ ចំពោះអ្នកធ្វើស្រែចំការពឹងផ្អែកលើទឹកភ្លៀងចំនួន៧០% និងពឹងផ្អែកលើប្រភពទឹកផ្សេងៗមានចំនួន៣០%។[១៦]

ឃុំទឹកល្អក់ មានប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសមល្មមបង្កើនកំណើនសេដ្ឋកិច្ចបានខ្ពស់ជាងមុនពោលគឺមានផ្លូវគមនាគមន៍ជាច្រើនខ្សែរ ដូចជា ផ្លូវក្រាលកៅស៊ូ ផ្លូវក្រាលគ្រួសក្រហម ផ្លូវដីស និងផ្លូវលំធម្មតា។ ចំណែកប្រព័ន្ធធារាសាស្ត្រមានជាច្រើនខ្សែរទាំងប្រឡាយមេ និងប្រឡាយរង ស្រោចស្រពក្នុងឃុំទឹកល្អក់តែម្តង។ ជាក់ស្តែង ប្រព័ន្ធធារាសាស្ត្ររបស់ឃុំទឹកល្អក់មានប្រភពពីរសំខាន់ៗគឺ៖

- ទំនប់ទីមួយ នៅក្នុងភូមិក្បាលដំរី អាចស្រោចស្រពស្រូវវស្សានៅពេលរាំងស្ងួតបានចំនួន ១៨៩ហិកតា ហើយបានស្តារ និងកសាងក្នុងឆ្នាំ២០០៨ ដោយមន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ស្ពឺ។
- ទំនប់ទីពីរ គឺទំនប់ប្រកស្បា ស្ថិតនៅក្នុងភូមិព្រៃកន្ទោច អាចស្តុកទឹកបានរាប់ពាន់ម៉ែត្រគីប និងស្រោចស្រពស្រូវរដូវវស្សានៅពេលរាំងស្ងួតបានចំនួន ៨៧ហិកតា។ ទំនប់នេះបានសាងសង់ និងស្តារក្នុងឆ្នាំ ២០១១ ដោយក្រសួងធនធានទឹក។

## ២.២.ការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋបាលឃុំទឹកល្អក់

### ២.២.១.សមាសភាពក្រុមប្រឹក្សា

យោងតាមប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ៧៧៩៨ ប្រក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ ប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំទឹក-

[១៦] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៩-២០២១ របស់ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

ល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ក្រុមប្រឹក្សាឃុំទឹកល្អក់ អាណត្តិទី៤ មានសមាសភាព ៧រូប មានរាយនាមដូច ខាងក្រោម៖

- លោក **ចក់ សារិន** មេឃុំ
- អ្នកស្រី **អ៊ុំ សុខហេង** ជំទប់ទី១
- អ្នកស្រី **អែម សាម៉េត** ជំទប់ទី២
- លោក **ឃឹម វណ្ណា** សមាជិក
- អ្នកស្រី **ស៊ុំ ស៊ីណាត** សមាជិក
- លោក **មិន វណ្ណៈ** សមាជិក
- លោក **នុប វណ្ណា** សមាជិក។

ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំទឹកល្អក់ទាំង ០៧រូប សុទ្ធតែមកពីគណបក្សប្រជាជនកម្ពុជា។[១៧] ក្រុមប្រឹក្សាឃុំទឹកល្អក់អាណត្តិទី៤ បានបង្កើតគណៈកម្មាធិការមួយចំនួនជាជំនួយការរួមមានដូចជា គណៈកម្មាធិការកសាងផែនការ និងថវិកា គណៈកម្មការលទ្ធកម្ម គណៈកម្មការគ្រប់គ្រងគម្រោង និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ។ គណៈកម្មាធិការនីមួយៗ ក្រៅពីមានសមាជិកក្រុមប្រឹក្សាឃុំជាសមាជិក ហើយនៅមានសមាជិកដទៃទៀតដែលពុំមែនជាសមាជិកក្រុមប្រឹក្សាឃុំទឹកល្អក់ ដែលត្រូវបានតែងតាំង ជាជនបង្គោល និងសមាជិកខ្លះទៀតជាតំណាងប្រជាជនក្នុងឃុំទឹកល្អក់។

### ២.២.២.គណៈកម្មាធិការនានារបស់ឃុំទឹកល្អក់

#### ២.២.២.១.គណៈកម្មាធិការកសាងផែនការ និងថវិកា

គណៈកម្មាធិការកសាងផែនការ និងថវិការបស់ឃុំទឹកល្អក់ មានសមាសភាពចំនួន ៣១រូប ដឹកនាំដោយប្រធាន ១រូប ជាមេឃុំ និងមានសមាជិកចំនួន ២៩រូបទៀត ក្នុងនោះមានសមាជិកក្រុមប្រឹក្សាឃុំចំនួន ៦រូប មេភូមិចំនួន ១២រូប អនុភូមិចំនួន ៣រូប សមាជិកភូមិចំនួន ៧រូប គ្រូមត្តេយ្យភូមិ ១រូប និងមានស្មៀនឃុំ ១រូបជាលេខាធិការ។[១៨] គណៈកម្មាធិការនេះទទួលខុសត្រូវជួយមេឃុំក្នុងការរៀបចំ កសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ និងរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំ។ ទន្ទឹមនឹងនេះ គណៈកម្មាធិការនេះ ត្រូវអនុវត្តន៍នីតិវិធីកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ និងរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំ តាមអភិក្រមដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់។

[១៧] សម្ភាសជាមួយលោក ចក់ សារិន មេឃុំទឹកល្អក់ នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ៩:៣០នាទីព្រឹក នៅសាលាឃុំទឹកល្អក់

[១៨] សេចក្តីសម្រេច លេខ ០០៤/១៩ ស.ស.រ ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការផែនការ និងថវិកាឃុំទឹកល្អក់

**`២.២.២.២.គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ មានសមាសភាពចំនួន ៣០រូប ដឹកនាំដោយប្រធាន ១រូបជាមេឃុំ អនុប្រធាន ១រូបជាជំទប់ទី២ ជនបង្គោលស្ត្រីកុមារ ១រូបជាក្រុមប្រឹក្សាឃុំ និងស្មៀនឃុំទឹកល្អក់ ១រូប ជាលេខាកត់ត្រា រួមទាំងសមាជិកចំនួន ២៦រូបផ្សេងទៀត។[១៩] គ.ក.ន.ក មានតួនាទី និងភារកិច្ចដូចជា៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាឃុំអនុម័ត ផ្តល់យោបល់ក្រុមប្រឹក្សាឃុំ ជួយមេឃុំចំពោះការងារពាក់ព័ន្ធ និងកិច្ចការនារី និងកុមារនៅក្នុងឃុំ
- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់ដឹងអំពីច្បាប់ គោលនយោបាយនានារបស់រដ្ឋ ដែលពាក់ព័ន្ធការការពារសិទ្ធនារី និងកុមារ បំផុសចលនាលើវិស័យសុខភាព អប់រំ កិច្ចការពារកុមារ ព្រមទាំងចុះបញ្ជីអត្រានុកូលដ្ឋានជូនទារកទើបកើត
- ជួយមេឃុំក្នុងការប្រមូលព័ត៌មាន វិភាគទិន្នន័យពាក់ព័ន្ធ និងបញ្ហាជាតំរូវការរបស់នារី និងកុមារ បញ្ចូលទៅនឹងផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ
- រៀបចំប្រជុំប្រចាំខែ ប្រចាំឆមាស ប្រចាំត្រីមាស និងប្រចាំឆ្នាំអំពីការរីកចម្រើនរបស់គណៈកម្មាធិការ និងរាយការណ៍ជូនកិច្ចប្រជុំអាណត្តិក្រុមប្រឹក្សាឃុំប្រចាំខែ
- គណៈកម្មាធិការទទួលបន្ទុកការងារស្ត្រី និងកុមារឃុំចូលរួមសម្របសម្រួល កិច្ចសហការយ៉ាងជិតស្និតជាមួយអ្នកផ្តល់សេវានានាក្នុងវិស័យសង្គមកិច្ចនៅតាមមូលដ្ឋានឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

**២.២.២.៣.គណៈកម្មការលទ្ធកម្ម**

គណៈកម្មការលទ្ធកម្មឃុំទឹកល្អក់ មានសមាសភាពចំនួន ៤រូប ដឹកនាំដោយប្រធាន ១រូប ជាមេឃុំ និងមានសមាជិក ៣រូបទៀតក្នុងនោះមានសមាជិកក្រុមប្រឹក្សាឃុំចំនួន ២រូប និងស្មៀនឃុំ ១រូបជាលេខាធិការ។ ចំពោះគណៈកម្មការលទ្ធកម្មរបស់ឃុំទឹកល្អក់មានតួនាទី និងភារកិច្ចដូចជា៖

- អនុវត្តន៍កិច្ចដំណើរការនៃការដេញថ្លៃ ទៅតាមនីតិវិធីដែលបានកំណត់
- ពិនិត្យ និងវាយតម្លៃសំណើរដេញថ្លៃ និងឯកសារពាក់ព័ន្ធដែលបានដាក់ដោយអ្នកដេញថ្លៃ
- ផ្តល់អនុសាសន៍ដល់មេឃុំអំពីអ្នកឈ្នះក្នុងការដេញថ្លៃ។

**២.២.២.៤.គណៈកម្មការគ្រប់គ្រងគម្រោង**

គណៈកម្មការគ្រប់គ្រងគម្រោង មានសមាសភាពចំនួន ១១រូប ដឹកនាំដោយប្រធាន ១រូប ជាមេឃុំ និងអនុប្រធាន ១រូប ជាជំទប់ទី១ រួមទាំងសមាជិកចំនួន ៩រូបទៀត ក្នុងនោះមានដូចជា សមាជិកក្រុមប្រឹក្សាឃុំចំនួន ៥រូប មេភូមិចំនួន ៣រូប និងស្មៀនឃុំទឹកល្អក់ជាលេខាធិការ។ គណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចជា៖

---

[១៩] សេចក្តីសម្រេច លេខ ០០៤/១៧ ស.ស.រ ឆ្នាំ២០១៧ ស្តីពីការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំទឹកល្អក់

- **ក្នុងការរៀបចំគម្រោង**
  - ពិនិត្យ និងអនុម័តផែនការសិក្សាគម្រោង
  - គ្រប់គ្រងចាត់ចែងដំណើរការសិក្សា និងរៀបចំគម្រោង
  - ពិនិត្យ និងអនុម័តសំណើរគម្រោង។
- **ក្នុងការអនុវត្តគម្រោង**
  - គ្រប់គ្រង ចាត់ចែងដំណើរការអនុវត្តន៍គម្រោង
  - រៀបចំប្រជុំចាប់ផ្តើម និងបញ្ចប់នៃការអនុវត្តការងារ ឬផ្គត់ផ្គង់ទំនិញ និងរៀបចំប្រជុំពិនិត្យ អនុម័តការទូទាត់គ្រោង
  - តាមដានត្រួតពិនិត្យការអនុវត្តគម្រោង
  - រៀបចំកិច្ចប្រជុំនានានៅក្នុងអំឡុងពេលអនុវត្តន៍គម្រោង ដើម្បីពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង។

#### ២.២.២.៥.កិច្ចប្រជុំរបស់គណៈកម្មាធិការ

ជាគោលការណ៍ កិច្ចប្រជុំរបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាឃុំ ត្រូវអនុវត្តន៍ដូចកិច្ចប្រជុំក្រុមប្រឹក្សាឃុំដែរ ប៉ុន្តែមានចំណុចពិសេសមួយចំនួនដូចខាងក្រោមៈ

- **របៀបវារៈសម្រាប់កិច្ចប្រជុំគណៈកម្មាធិការផ្តល់យោបល់** ចំពោះរបៀបវារៈសម្រាប់នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការផ្តល់យោបល់ ត្រូវរៀបចំដោយស្មៀន ដោយមានការពិគ្រោះយោបល់ដោយមេឃុំ និងប្រធានគណៈកម្មាធិការ។ ប្រសិនបើ សមាជិកគណៈកម្មាធិការច្រើនជាងមួយភាគបី មានបំណងពិភាក្សាលើបញ្ហាដែលស្ថិតក្នុងការងាររបស់គណៈកម្មាធិការ ត្រូវយកបញ្ហានោះ ដាក់ចូលក្នុងរបៀបវារៈរបស់កិច្ចប្រជុំគណៈកម្មាធិការ។
- **សេចក្តីសម្រេចរបស់គណៈកម្មាធិការ** គណៈកម្មាធិការត្រូវធ្វើសេចក្តីសម្រេចដោយការព្រមព្រៀងឯកភាពគ្នា តាមរយៈការលើកដៃចំពោះការធ្វើសេចក្តីសម្រេច។ ប្រសិនបើមិនមានការព្រមព្រៀងឯកភាពគ្នាទេ គណៈកម្មាធិការ ត្រូវធ្វើការបោះឆ្នោត។ គណៈកម្មាធិការត្រូវធ្វើការរាយការណ៍អំពីសេចក្តីសម្រេចរបស់ខ្លួន ជូនក្រុមប្រឹក្សាឃុំ ឬមេឃុំ ដូចដែលបានបញ្ជាក់នៅក្នុងតួនាទី និងភារកិច្ចរបស់ខ្លួន។

## ២.៣.ការអភិវឌ្ឍរបស់ឃុំទឹកល្អក់

### ២.៣.១.ផែនការអភិវឌ្ឍន៍ឃុំ

ផែនការអភិវឌ្ឍន៍ឃុំ គឺមានអាណត្តិរយៈពេលប្រាំឆ្នាំ ដូចអាណត្តិរបស់ក្រុមប្រឹក្សាដែរ។ ផែនការអភិវឌ្ឍឃុំ ដែលត្រូវបានប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា តម្រូវការ និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយរាល់បញ្ហាទាំងនោះ សំដៅឆ្លើយតបទៅនឹងបញ្ហាជាអាទិភាពរបស់ប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាព។

**២.៣.១.១.ការរៀបចំផែនការអភិវឌ្ឍន៍**

ក្រុមប្រឹក្សាឃុំ សង្កាត់ជារដ្ឋបាលដែលនៅដាច់ឆ្ងាយពីរដ្ឋបាលកណ្តាល ប៉ុន្តែជារដ្ឋបាលដែលនៅជិតប្រជាពលរដ្ឋជាងរដ្ឋបាលដទៃទៀតហើយក៏ដឹងច្បាស់អំពីតម្រូវការរបស់ប្រជាពលរដ្ឋ ក៏ដូចជាស្ថានភាពនៅមូលដ្ឋានរបស់ឃុំ សង្កាត់នីមួយៗផងដែរ។ ដូច្នេះ ការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ឃុំ សង្កាត់នីមួយៗត្រូវពឹងផ្អែកលើវិធានការ និងការរៀបចំគម្រោងនានារបស់ឃុំ សង្កាត់នីមួយៗស្របតាមលទ្ធភាពផ្ទាល់របស់ឃុំ សង្កាត់នោះ។

ការរៀបចំ អនុម័ត និងអនុវត្តន៍នូវផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយគោលបំណងនៃការបង្កើតផែនការអភិវឌ្ឍន៍នេះ ដើម្បីកំណត់នូវទស្សនៈវិស័យ កម្មវិធី និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ហើយត្រូវតែស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច។

ផែនការអភិវឌ្ឍន៍ គឺពិតជាមានសារៈសំខាន់ដែលក្រុមប្រឹក្សាឃុំ សង្កាត់ចាំបាច់ត្រូវតែរៀបចំ អនុម័ត ហើយធ្វើការកែសម្រួលនូវទិន្នន័យថ្មីៗដែលមានការប្រែប្រួលជារៀងរាល់ឆ្នាំ នៅពេលស្ថិតិក្នុងអាណត្តិ ឬក្នុងឆ្នាំទីមួយ នៃអាណត្តិក្រុមប្រឹក្សាទើបនឹងជាប់ឆ្នោត។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវរៀបចំជាលាយលក្ខណ៍អក្សរ ដោយមានផែនទី ស្ថិតិ និងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយ។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ដែរនូវវិធីសាស្ត្រ និងមធ្យោបាយនានា ដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល។

ក្នុងករណីផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមច្បាប់នោះទេ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងធ្វើការណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ កែតម្រូវឱ្យបានសមស្របក្នុងកំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីទទួលច្បាប់ចម្លងនៃផែនការនោះ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការកែសម្រួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**២.៣.១.២.វដ្តនៃផែនការអភិវឌ្ឍន៍**

វដ្តនៃផែនការអភិវឌ្ឍន៍របស់ឃុំទឹកល្អក់ មានប្រាំជំហានគឺ ១.សេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍន៍ និងថវិកា ២.កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍន៍ ៣.សេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ ៤.ការអនុម័តផែនការអភិវឌ្ឍន៍ឃុំ ៥.ការវាយតម្លៃអំពីផែនការអភិវឌ្ឍន៍ឃុំ។[២០]

**ជំហានទី១ សេចក្តីព្រាងក្របខណ្ឌផែនការអភិវឌ្ឍន៍ឃុំ**

ជាដំបូងគណៈកម្មាធិការកសាងផែនការ និងថវិកា ដែលមាន លោក **ចក់ សារិន** ជាប្រធាននៃគណៈ-កម្មាធិការជួបប្រជុំនៅថ្នាក់ឃុំ ដើម្បីធ្វើការវិភាគទិន្នន័យភូមិ ទិន្នន័យឃុំ ឯកសារព័ត៌មាន ស្ថានភាពឃុំ និងទិន្នន័យ ឬព័ត៌មាន និងឧបករណ៍វិភាគផ្សេងៗក្នុងការកំណត់អំពីបញ្ហា មូលហេតុនៃបញ្ហា និងដំណោះស្រាយ

[២០] សម្ភាសជាមួយលោក ញ៉ែម ធន ស្មៀនឃុំទឹកល្អក់ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ៩:៣០នាទីព្រឹក នៅសាលាឃុំទឹកល្អក់

នានាសម្រាប់ពិភាក្សាជាមួយប្រជាពលរដ្ឋ។ បន្ទាប់មកគណៈកម្មាធិការ ធ្វើការរៀបចំប្រជុំនៅតាមភូមិ ដើម្បីពិភាក្សា និងធ្វើសុពលភាពលើបញ្ហា មូលហេតុ និងដំណោះស្រាយទាំងឡាយដែលបានកំណត់នៅថ្នាក់ឃុំ និងដើម្បីពិភាក្សាកំណត់បញ្ហា ឬតម្រូវការ និងដំណោះស្រាយនានាបន្ថែម។ បន្ទាប់ពីនេះ គណៈកម្មាធិការធ្វើការជួបប្រជុំនៅថ្នាក់ឃុំម្តងទៀត ដើម្បីបូកសរុបបញ្ហា មូលហេតុ និងដំណោះស្រាយដែលបានមកពីបណ្តាភូមិនានា និងពិភាក្សាកំណត់សេចក្តីត្រូវការអភិវឌ្ឍន៍ គោលដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍ សកម្មភាពជាអាទិភាព ទំហំគម្រោង និងទីតាំងគម្រោង រួមទាំងតម្លៃប៉ាន់ស្មានគម្រោង។

**ជំហានទី២ កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍ**

កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍឃុំ ត្រូវបានរៀបចំឡើងដើម្បីប្រជុំជាមួយប្រជាពលរដ្ឋនៅក្នុងឃុំ និងអ្នកពាក់ព័ន្ធនានា ផ្តល់មតិយោបល់ទៅលើសេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍន៍ និងថវិកាឃុំ។

**ជំហានទី៣ សេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ**

គណៈកម្មាធិការកសាងផែនការ និងថវិការៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ ហើយដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងឯកភាព។ បន្ទាប់ពីទទួលបានឯកភាព មេឃុំផ្ញើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំជូនអភិបាលខេត្តកំពង់ស្ពឺ តាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្តកំពង់ស្ពឺ ដើម្បីពិនិត្យ និងផ្តល់យោបល់។

**ជំហានទី៤ ការអនុម័តផែនការអភិវឌ្ឍន៍ឃុំ**

គណៈកម្មាធិការកសាងផែនការ និងថវិកា និងស្មៀនឃុំ ពិនិត្យ ពិចារណា និងកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំទៅតាមមតិយោបល់របស់អភិបាលខេត្តកំពង់ស្ពឺ។ ក្រោយមកទៀត ក្រុមប្រឹក្សាឃុំទឹកល្អក់ធ្វើការពិនិត្យ និងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ។ ឯកសារផែនការអភិវឌ្ឍន៍ឃុំដែលបានអនុម័ត ត្រូវផ្សព្វផ្សាយជាសាធារណៈ និងប្រើប្រាស់ជាមូលដ្ឋានសម្រាប់កម្មវិធីវិនិយោគប្រចាំឆ្នាំ។

**ជំហានទី៥ ការវាយតម្លៃអំពីផែនការអភិវឌ្ឍន៍ឃុំ**

គណៈកម្មាធិការកសាងផែនការ និងថវិកា ពិនិត្យ និងវាយតម្លៃទៅលើប្រសិទ្ធភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ និងដកស្រង់បទពិសោធន៍នានា សម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រងការអនុវត្ត និងរៀបចំផែនការពេលក្រោយ។

**២.៣.១.៣.ការអនុវត្តផែនការអភិវឌ្ឍន៍**

នៅពេលអនុវត្តន៍ផែនការអភិវឌ្ឍន៍ ក្រុមប្រឹក្សាឃុំ ត្រូវធានាថាគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ពិសេសអ្នកទទួលផលពីគម្រោងបានចូលរួមយ៉ាងពេញលេញ នៅក្នុងការរៀបចំគម្រោង និងការត្រួតពិនិត្យការអនុវត្តគម្រោងដែលមានក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ។ មេឃុំត្រូវធ្វើលទ្ធកម្មការងារសាងសង់ សម្ភារៈ ឬទំនិញ និងសេវាកម្ម ដើម្បីអនុវត្តន៍គម្រោងទាំងអស់ និងសកម្មភាពនានាឱ្យស្របទៅតាមនីតិវិធីដែលបាន

កំណត់។ មុនធ្វើលទ្ធកម្មការងារសាងសង់ សម្ភារៈ ឬទំនិញ និងសេវាកម្មសម្រាប់អនុវត្តន៍គម្រោងណាមួយ មេឃុំត្រូវស្វែងរកការបញ្ជាក់ផ្នែកបច្ចេកទេសពីមន្ទីជំនាញ ឬអង្គភាពពាក់ព័ន្ធជុំវិញខេត្ត និងតាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត។ ការវាយតម្លៃគ្រប់ជ្រុងជ្រោយទៅលើលទ្ធផល ផលប៉ះពាល់ពីការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ ត្រូវធ្វើឡើងក្នុងរយៈពេល ៦ខែចុងក្រោយនៃអាណត្តិរបស់ក្រុមប្រឹក្សា។

**២.៣.១.៤.ការត្រួតពិនិត្យ និងវាយតម្លៃ**

បន្ទាប់ពីការរៀបចំផែនការអភិវឌ្ឍន៍ឃុំ រួចក្រុមប្រឹក្សាឃុំ ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើសកម្មភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ គម្រោង និងការផ្តល់សេវាសាធារណៈនានារបស់ឃុំ ប្រកបដោយតម្លាភាព ជាមួយនឹងការទទួលខុសត្រូវខ្ពស់របស់អ្នកផ្តល់សេវា។ ដោយស្របទៅតាមស្ថានភាពជាក់ស្តែង ក្រុមប្រឹក្សាឃុំទឹកល្អក់ អាចជ្រើសរើសយកសមាសភាពផ្សេងទៀតមកអនុវត្តន៍ផែនការ កម្មវិធី និងគម្រោងនានារបស់ឃុំ ប៉ុន្តែក្រុមប្រឹក្សាឃុំ នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃចំពោះការអនុវត្តរបស់សមាសភាព។

ម្យ៉ាងទៀត ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តផែនការរបស់ឃុំ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំដល់ក្រុមប្រឹក្សាឃុំ អំពីវិធីសាស្ត្រផ្សេងៗក្នុងការអនុវត្តផែនការ និងការត្រួតពិនិត្យវាយតម្លៃរបស់ក្រុមប្រឹក្សាឃុំចំពោះការប្រើប្រាស់មូលនិធិសម្រាប់ផែនការអភិវឌ្ឍន៍ឃុំ។

**២.៣.២.កម្មវិធីវិនិយោគ**

**២.៣.២.១.ក្របខណ្ឌវិនិយោគ**

ក្របខណ្ឌវិនិយោគ គឺជាផ្នែកមួយដ៏សំខាន់របស់កម្មវិធីវិនិយោគឃុំទឹកល្អក់។ ក្រុមប្រឹក្សាឃុំទឹកល្អក់ ដែលមានគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំជាជំនួយការ បានយកចិត្តទុកដាក់គិតគូរ និងរៀបចំអំពីគោលបំណងសំខាន់ៗ ដើម្បីធ្វើការអភិវឌ្ឍន៍មូលដ្ឋាននាពេលខាងមុខដោយផ្អែកទៅលើផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ (២០១៧-២០២២) ជាឯកសារគោល និងជាត្រីវិស័យសម្រាប់ឱ្យក្រុមប្រឹក្សាឃុំអនុវត្តន៍ តាមរយៈការរៀបចំ និងការអនុវត្តកម្មវិធីវិនិយោគប្រចាំឆ្នាំនីមួយៗរបស់ឃុំ។ នៅពេលពិនិត្យលើបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋឡើងវិញ ការរៀបចំគម្រោងវិនិយោគប្រចាំឆ្នាំរបស់ឃុំ ត្រូវឆ្លងកាត់ការពិភាក្សាគ្នាឱ្យបានល្អិតល្អន់ ដើម្បីជ្រើសរើស និងចាត់អាទិភាពគម្រោងសម្រាប់យកទៅអនុវត្តន៍ឱ្យចំគោលដៅតាមការជាក់ស្តែងនៅក្នុងមូលដ្ឋានថាតើអ្វីដែលជាបញ្ហាប្រឈម ហើយចាំបាច់ត្រូវធ្វើការដោះស្រាយមុនឱ្យស្របទៅនឹងប្រភពធនធានដែលឃុំមាន និងទុនពីខាងក្រៅដែលបានមកពីការជួយឧបត្ថម្ភពីសំណាក់មន្ទីជំនាញ អង្គការមិនមែនរដ្ឋាភិបាល សប្បុរសជន និងដៃគូរអភិវឌ្ឍន៍នានា ជួយគាំទ្រដល់គម្រោងកម្មវិធីវិនិយោគនេះ នៅពេលសមាហរណកម្មផែនការឃុំនៅថ្នាក់ស្រុក និងគម្រោងខ្លះទៀតជួយគាំទ្រនៅក្រោយពេលសមាហរណកម្មផែនការផងដែរ។

ជាគ្មានេះដែរ ឃុំ ត្រូវធ្វើការកោះប្រជុំពេញអង្គក្រុមប្រឹក្សា ដើម្បីសម្រេចជ្រើសរើសគម្រោងដែលនៅសេសសល់គ្មានការសន្យាគាំទ្រសម្រាប់ប្រើប្រាស់មូលនិធិឃុំ ទុនចូលរួមពីប្រជាពលរដ្ឋ និងថវិកាផ្សេងៗទៀតរបស់ឃុំដែលទទួលបានពីមជ្ឈដ្ឋានខាងក្រៅ ត្រូវបញ្ចូលក្នុងតារាងថវិកាវិនិយោគតាមប្រភព តារាងវិនិយោគដែលមានការសន្យាគាំទ្រ និងតារាងគម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រ។

**២.៣.២.២.វដ្តនៃកម្មវិធីវិនិយោគ**

វដ្តនៃកម្មវិធីវិនិយោគរបស់ឃុំទឹកល្អក់មានប្រាំជំហានគឺ ១.ការពិនិត្យលើបញ្ហា ឬតម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញ ២.ការរៀបចំគម្រោងវិនិយោគឃុំ ៣.សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ៤.ការអនុម័តកម្មវិធីវិនិយោគឃុំ ៥.ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគឃុំ។

**ជំហានទី១ ការពិនិត្យបញ្ហា ឬតម្រូវការជាមួយប្រជាជនឡើងវិញ**

គណៈកម្មាធិការការសាងផែនការ និងថវិកាជួបប្រជុំនៅថ្នាក់ឃុំ ដើម្បីពិភាក្សាពិនិត្យបញ្ហា ឬតម្រូវការមូលហេតុនៃបញ្ហា និងដំណោះស្រាយឡើងវិញ ដោយធ្វើការឆ្លុះបញ្ចាំងជាមួយទិន្នន័យភូមិ ទិន្នន័យឃុំ ឯក-សារព័ត៌មានស្ថានភាពឃុំ និងទិន្នន័យ ឬព័ត៌មានផ្សេងៗ ហើយកំណត់អំពីបញ្ហា មូលហេតុនៃបញ្ហា និងដំណោះស្រាយនានា សម្រាប់ពិភាក្សាជាមួយប្រជាពលរដ្ឋ។ បន្ទាប់មក គណៈកម្មាធិការធ្វើការរៀបចំប្រជុំនៅតាមភូមិ ដើម្បីពិភាក្សា និងធ្វើសុពលភាពទៅលើបញ្ហា មូលហេតុ និងដំណោះស្រាយទាំងឡាយដែលបានកំណត់នៅថ្នាក់ឃុំ និងដើម្បីពិភាក្សាកំណត់លើបញ្ហា ឬតម្រូវការ និងដំណោះស្រាយបន្ថែមនានា។ ក្រោយមក គណៈកម្មា-ធិការធ្វើការជួបប្រជុំម្តងទៀតនៅថ្នាក់ឃុំ ដើម្បីបូកសរុបបញ្ហា មូលហេតុ និងដំណោះស្រាយដែលបានមកពីបណ្តាភូមិនានា។

**ជំហានទី២ ការរៀបចំគម្រោងវិនិយោគឃុំ**

គណៈកម្មាធិការការសាងផែនការ និងថវិកាធ្វើការឆ្លុះបញ្ចាំងលទ្ធផលនៃជំហានទី១ ជាមួយនឹងគម្រោងតាមបណ្តាឆ្នាំនីមួយៗនៃផែនការអភិវឌ្ឍន៍ឃុំ ដើម្បីកំណត់គម្រោងវិនិយោគប្រចាំឆ្នាំ ដែលត្រូវយកទៅបង្ហាញ និងកៀរគរធនធាននៅសិក្ខាសាលាសមាហរណកម្មផែនការនៅថ្នាក់ស្រុក។

**ជំហានទី៣ សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក**

សិក្ខាសាលាសមាហរណកម្មផែនការនេះ ត្រូវរៀបចំឡើង ដើម្បីៈ

- ផ្តល់ឱកាសឱ្យមានការផ្សាភ្ជាប់កម្មវិធីវិនិយោគឃុំ ជាមួយនឹងផែនការមន្ទីរជំនាញ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា
- កៀរគរ និងសម្របសម្រួលធនធានពីប្រភពផ្សេងៗសម្រាប់គាំទ្រដល់គម្រោងវិនិយោគឃុំ
- ជួយតម្រង់ទិសសកម្មភាពរបស់មូលដ្ឋានឃុំ ឱ្យស្របតាមគោលនយោបាយអភិវឌ្ឍន៍ជាតិ និងខេត្ត។

**ជំហានទី៤ ការអនុម័តកម្មវិធីវិនិយោគ**

គណៈកម្មាធិការការសាងផែនការ និងថវិការៀបចំតារាងថវិកាវិនិយោគតាមប្រភព តារាងគម្រោងវិនិយោគដែលមានការសន្យាគាំទ្រ និងតារាងគម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រ ព្រមទាំងជ្រើសរើសគម្រោងដែលមិនទាន់មានការសន្យាគាំទ្រ សម្រាប់ប្រើប្រាស់មូលនិធិឃុំ។ បន្ទាប់មក គណៈកម្មាធិការ ត្រូវរៀបចំប្រជុំផ្សព្វផ្សាយនៅតាមភូមិ ដើម្បីឱ្យប្រជាពលរដ្ឋផ្តល់យោបល់លើគម្រោងវិនិយោគប្រចាំឆ្នាំ ជាពិសេសគម្រោងប្រើប្រាស់មូលនិធិឃុំ។ ក្រោយពីប្រមូលមតិយោបល់រួចគណៈកម្មាធិការត្រូវរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគឃុំ ហើយដាក់ជូនក្រុមប្រឹក្សា ដើម្បីពិនិត្យ និងអនុម័ត។

ឯកសារកម្មវិធីវិនិយោគដែលអនុម័តរួច ត្រូវប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការ និងបង្កភាពងាយស្រួលដល់អ្នកពាក់ព័ន្ធធ្វើការសិក្សាស្វែងយល់។

**ជំហានទី៥ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគឃុំ**

ជំហានចុងក្រោយ គណៈកម្មាធិការត្រូវតាមដានត្រួតពិនិត្យការរីកចម្រើន និងប្រសិទ្ធភាពនៃការអនុវត្តគម្រោង ឬសកម្មភាពនានាដែលមាននៅក្នុងកម្មវិធីវិនិយោគឃុំ ដើម្បីធានាការអនុវត្តគម្រោង ឬសកម្មភាពទាំងនោះឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។ មិនត្រឹមតែប៉ុណ្ណោះ គណៈកម្មាធិការក៏ត្រួតពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីវិនិយោគឃុំ និងបានដកស្រង់បទពិសោធន៍នានា សម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រងការអនុវត្ត និងការរៀបចំកម្មវិធីវិនិយោគឆ្នាំក្រោយ។

**២.៣.២.៣.គម្រោងវិនិយោគរបស់ឃុំ**

នៅឆ្នាំ២០១៩ ថវិការបស់ឃុំទឹកល្អក់ មានប្រភពមកពីទុនក្នុងឃុំ ដែលបានមកពីចំណូលផ្ទាល់របស់ឃុំមានចំនួន ២៤៥,៧៨៣,០០០រៀល រីឯទុនក្រៅឃុំបានមកពីមន្ទីរកិច្ចការនារីខេត្តចំនួន ៤,០០០,០០០រៀល ទុនពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តចំនួន ៨០០,០០០រៀល ទុនពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តចំនួន ៥០,១៩០,០០០រៀល ទុនពីមន្ទីរអភិវឌ្ឍន៍ជនបទចំនួន ៣៤៤,០០០,០០០រៀល។ សរុបថវិកាវិនិយោគតាមប្រភពរបស់ឃុំមានចំនួន ៦៤៤,៧៧៣,០០០រៀល។[២១] មូលនិធិអភិវឌ្ឍន៍ឃុំចំនួនទើបគម្រោងវិនិយោគជាច្រើនត្រូវបានដំណើរការ ដោយបែងចែកជាគម្រោងវិនិយោគដែលមានថវិកាគាំទ្រ និងគម្រោងវិនិយោគដែលពុំទាន់មានថវិកាគាំទ្រ។ គម្រោងវិនិយោគដែលមានថវិកាឃុំគាំទ្រភាគច្រើនអនុវត្តន៍ទៅលើ ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈតែប៉ុណ្ណោះ។ ចំពោះគម្រោងវិនិយោគដែលពុំទាន់មានថិវកាឃុំគាំទ្រមានដូចជា ការជួសជុល និងស្តារទំនប់ទឹក ការផ្តល់ពូជត្រី និងពូជបន្លែគ្រប់មុខ ការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី ការ

[២១] សៀវភៅផែនការឃុំ ឆ្នាំ២០១៩ របស់ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

សាងសង់ប្រព័ន្ធទឹកស្អាត ការសាងសង់មណ្ឌលសុខភាពក្នុងឃុំទឹកល្អក់ ការផ្សព្វផ្សាយការជួញដូរស្ត្រី និងកុមារ វគ្គបណ្តុះបណ្តាលយេនឌ័រ ការផ្សព្វផ្សាយពីគ្រោះមហន្តរាយផ្សេងៗ ការផ្តល់ប័ណ្ណកម្មសិទ្ធិប្រើប្រាស់ដីធ្លី និងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពថ្នាក់ភូមិ ឃុំ។ល។

## ២.៤.ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំ

ឃុំទឹកល្អក់ ជានីតិបុគ្គលសាធារណៈដែលមានធនធាន ថវិកាសម្រាប់ដំណើរការសកម្មភាពរបស់ខ្លួន។ តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តម្រូវឱ្យឃុំ សង្កាត់នីមួយៗមានធនធាន ហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន។ ដូច្នេះ រដ្ឋបាលឃុំទឹកល្អក់មានសិទ្ធិអំណាចគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន និងមានប្រភពចំណូល និងចំណាយរបស់ខ្លួនផងដែរ។

### ២.៤.១.ការរៀបចំ និងអនុម័តថវិការបស់ឃុំ

គម្រោងថវិការបស់ឃុំទឹកល្អក់ ត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ និងដោយមានជំនួយពីគណៈកម្មាធិការកសាងផែនការ និងថវិការបស់ឃុំទឹកល្អក់ រួចទើបបញ្ជូនទៅក្រុមប្រឹក្សាឃុំ ដើម្បីពិនិត្យ និងអនុម័ត។ ជារៀងរាល់ឆ្នាំ ដំណើរការរៀបចំថវិការបស់ឃុំទឹកល្អក់ ត្រូវបានកំណត់គោលដៅឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ដើម្បីជួយផ្តល់ជាមតិយោបល់ ព្រមទាំងផ្តិតមេដៃបញ្ជាក់ពីការចូលរួមរបស់ខ្លួន។ ប៉ុន្តែជារឿយៗ ក្រោយពីការប្រកាសផ្សាយឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋហើយ ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំទឹកល្អក់ហាក់មិនចាប់អារម្មណ៍ និងពុំសូវឱ្យតម្លៃពីការចូលរួមរបស់ខ្លួនឡើយ។ ម្យ៉ាងវិញទៀត ដោយហេតុថា ប្រជាពលរដ្ឋផ្តល់ភាពចាំបាច់លើការប្រកបរបរប្រចាំថ្ងៃជាជាងការចូលរួមនេះ។

នៅដំណាក់កាលបន្ទាប់ពីការអនុម័តគម្រោងថវិកានៅថ្នាក់ឃុំរួចហើយ មេឃុំទឹកល្អក់ បញ្ជូនគម្រោងថវិកាទៅកាន់អភិបាលខេត្តកំពង់ស្ពឺ។ ក្រោយពីមានការឯកភាពលើគម្រោងថវិកានេះហើយ អភិបាលខេត្តកំពង់ស្ពឺបញ្ជូនគម្រោងថវិកាមកកាន់មេឃុំទឹកល្អក់វិញនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ដើម្បីបញ្ជាក់ ពីការទទួលស្គាល់លើគម្រោងថវិកា ដែលសេចក្តីជូនដំណឹងនេះក៏មានការចម្លងជូន និងភ្ជាប់ជាមួយគម្រោងថវិកាទៅឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារខេត្តកំពង់ស្ពឺដែរ។[២២]

### ២.៤.២.ចំណូល និងចំណាយថវិការបស់ឃុំ

#### ២.៤.២.១.ប្រភពចំណូល និងចំណាយរបស់ឃុំ

ដោយយោងតាមអនុសារណៈ ស្តីពីការរៀបចំគម្រោងថវិកា ឆ្នាំ២០១៩ ឃុំទឹកល្អក់មានស្ថានភាពចំណូល និងចំណាយដូចតទៅ៖

– ចំណូលចរន្ត ៣៤៤,២០០,០០០ រៀល

[២២] មាត្រា១៥ នៃអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

- ចំណូលមូលធន ៤១,៧៤៧,០៥៥ រៀល
- ចំណាយចរន្ត ៣៨៥,៩៤៧,០៥៥ រៀល
- ចំណាយជាមូលធន ១១៤,៦៩៨,៨០០ រៀល។

**២.៤.២.២.ប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សាឃុំ និងមន្ត្រីភូមិ**

យោងតាមអនុក្រឹត្យ លេខ៣៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់សមាជិកក្រុមប្រឹក្សាឃុំ និងមន្ត្រីភូមិនៃឃុំទឹកល្អក់ដែលត្រូវអនុវត្តន៍ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ បានកំណត់ដូចខាងក្រោម៖

- មេឃុំ ១,១១០,០០០ រៀល ក្នុងមួយខែ
- ជំទប់ទី១ និងជំទប់ទី២(១នាក់) ៨៧០,០០០ រៀល ក្នុងមួយខែ
- សមាជិកក្រុមប្រឹក្សាឃុំ ៧៦០,០០០ រៀល ក្នុងមួយខែ
- មេភូមិ ៤៣០,០០០ រៀល ក្នុងមួយខែ
- អនុប្រធានភូមិ ៣១០,០០០ រៀល ក្នុងមួយខែ
- សមាជិកភូមិ ២៨០,០០០ រៀល ក្នុងមួយខែ។

**២.៤.៣.ប្រព័ន្ធទូទាត់ គណនេយ្យភាព និងកិច្ចលទ្ធកម្មរបស់ឃុំ**

**២.៤.៣.១.គោលការណ៍ទូទៅ**

ឃុំ ត្រូវបង្កើតគណនីប្រាក់បញ្ញើរនៅរតនាគាខេត្តក្រុង។ មេឃុំ គឺជាអាណាប័ក និងមានសិទ្ធិពេញលេញលើការប្រមូល ឬសន្យាចំណាយ និងបញ្ជាចំណាយដោយផ្អែកលើថវិកាដែលបានអនុម័ត។ មេឃុំ អាចផ្ទេរសិទ្ធិក្នុងការសម្រេចលើថវិកាទៅឱ្យជំទប់របស់រដ្ឋបាលឃុំ។ ការផ្ទេរសិទ្ធិជាអាណាប័កនេះ ត្រូវធ្វើសកម្មភាពដោយស្ថិតក្នុងការទទួលខុសត្រូវ និងត្រួតពិនិត្យរបស់មេឃុំ។ មេឃុំ និងអ្នកទទួលសិទ្ធិត្រូវតែតម្កល់គំរូហត្ថលេខាជាផ្លូវការដល់គណនេយ្យករមុខការ។ ហើយអ្នកទទួលសិទ្ធិ និងបុគ្គលិករដ្ឋបាលឃុំទឹកល្អក់ មិនត្រូវអនុញ្ញាតឱ្យកាន់កាប់មូលនិធិ ឬធ្វើការទូទាត់ចំណាយ លើកលែងតែក្នុងករណីទូទាត់បេឡាបុរេប្រទាន និងចំណូលដែលប្រមូលបានដោយភ្នាក់ងារប្រមូលចំណូល។ លើសពីនេះទៅទៀត សិទ្ធិបញ្ជាចំណាយ និងការទូទាត់មិនត្រូវប្រគល់ឱ្យមនុស្សតែម្នាក់ឡើយ ហើយរតនាគាខេត្តកំពង់ស្ពឺត្រូវបំពេញមុខងារជាគណនេយ្យកររបស់ឃុំទឹកល្អក់។

**២.៤.៣.២.ប្រព័ន្ធទូទាត់**

ការទូទាត់ផ្ទាល់ គឺជាការទូទាត់តាមរយៈរតនាគាខេត្ត ហើយការទូទាត់តាមរយៈបេឡាបុរេប្រទានត្រូវប្រើសម្រាប់តែចំណាយចរន្ត (លើកលែងប្រាក់បៀវត្ស ប្រាក់បំណាច់) និងចំណាយវិនិយោគរដ្ឋបាល។ ហើយការ

ចំណាយមួយលើកៗចេញពីបេឡាបុរេប្រទានត្រូវមានចំនួនទឹកប្រាក់ នៅក្រោមកម្រិតមួយជាក់ណាត់ និងតាមនីតិវិធីបេឡាបុរេប្រទាន។

**២.៤.៣.៣.ប្រព័ន្ធគណនេយ្យ**

**គណនេយ្យហិរញ្ញវត្ថុ** គឺជាកិច្ចបញ្ជីការរាល់ចំណូល ចំណាយនៅក្នុងប្រព័ន្ធគណនេយ្យ។ ហើយអ្នកដែលមានភារកិច្ចអនុវត្តន៍គណនេយ្យហិរញ្ញវត្ថុ គឺគណនេយ្យករនៅរតនាគាខេត្តកំពង់ស្ពឺ។

**គណនេយ្យថវិកា** គឺជាការតាមដាន និងរាយការណ៍អំពីការអនុវត្តចំណូល ចំណាយ និងថវិកាដែលមានអនុម័ត។ អ្នកដែលមានភារកិច្ចក្នុងការទទួលខុសត្រូវក្នុងការអនុវត្តគណនេយ្យថវិកាគឺលោក ចក់ សារិន ដែលជាមេឃុំ នៃឃុំទឹកល្អក់។

**២.៤.៣.៤.កិច្ចលទ្ធកម្មឃុំ**

កិច្ចលទ្ធកម្ម គឺជាដំណើរការលទ្ធកម្មចាប់ពីពេលរៀបចំឯកសារដេញថ្លៃរហូតដល់ទទួលបានទំនិញ សំណង់ ឬសេវាកម្ម។ ចំណែកឯលទ្ធកម្មវិញ សំដៅទៅដល់ការទិញ ឬការរកបាននូវទំនិញ សំណង់ ឬសេវាកម្មតាមរយៈវិធីសាស្ត្រដែលបានកំណត់។

គោលការណ៍សំខាន់ៗនៃកិច្ចលទ្ធកម្មមានដូចជា៖

- លទ្ធកម្មសំណង់ លទ្ធកម្មសេវាកម្ម និងលទ្ធកម្មទំនិញត្រូវអនុវត្តន៍ក្នុងលក្ខណៈមួយដែលមានតម្លាភាព ប្រសិទ្ធភាព និងសន្សំសំចៃបំផុតតាមដែលអាចធ្វើទៅបានដោយធានាគុណភាព
- អ្នកទទួលការ អ្នកផ្តល់សេវា និងអ្នកផ្គត់ផ្គង់ត្រូវមានឱកាសស្មើៗគ្នា ដើម្បីចូលរួមក្នុងដំណើរការដេញថ្លៃក្រោមលក្ខខណ្ឌយុត្តិធម៌ និងស្មើភាព
- លទ្ធផលនៃការដេញថ្លៃត្រូវផ្សព្វផ្សាយជាសាធារណៈ

ចំពោះសមាសភាពគណៈកម្មការលទ្ធកម្មរបស់ឃុំទឹកល្អក់មាន ៤រូប ក្នុងនោះមានលោក ចក់ សារិន ជាប្រធានគណៈកម្មការលទ្ធកម្ម និងជាមេឃុំទឹកល្អក់ រួមទាំងសមាជិកក្រុមប្រឹក្សា ២រូប ហើយស្មៀនឃុំ ១រូប ដែលបំពេញតួនាទីជាលេខាធិការឱ្យគណៈកម្មការលទ្ធកម្មឃុំទឹកល្អក់។[២៣] ដោយឡែកចំពោះ វិធីសាស្ត្រវិញ គឺត្រូវអនុវត្តន៍ដូចជា ការដេញថ្លៃដោយមានការប្រគួតប្រជែងជាចំហ (ជាសាធារណៈ) ការស្ទង់តម្លៃក្នុងស្រុក និងការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់ (ការចរចារតម្លៃផ្ទាល់)។

[២៣] សេចក្តីសម្រេច លេខ ០០៤/១៩ ស.ស.រ ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការលទ្ធកម្មឃុំទឹកល្អក់

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១.សមិទ្ធផល

ស្របតាមគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល សម្រាប់ធ្វើការបង្កិតសេវាឱ្យកាន់តែជិតប្រជាពលរដ្ឋ ដើម្បីមានភាពងាយស្រួលក្នុងការទទួលយកសេវាប្រកបដោយតម្លា-ភាព សមភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ជូនប្រជាពលរដ្ឋដោយដាក់ឱ្យរដ្ឋបាលឃុំទឹកល្អក់ អនុវត្តន៍នូវប្រកាសអន្តរក្រសួង លេខ ១៤៣៨៤ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការផ្ដល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានការលើកលែងការយកប្រាក់កម្រៃសេវាសាធារណៈមួយចំនួននៅថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ឃុំ សង្កាត់។

ក្នុងនោះកិច្ចការបម្រើមូលដ្ឋានមានការងារជាច្រើនលើគ្រប់វិស័យដូចជា ការគ្រប់គ្រងរដ្ឋបាលទូទៅ ការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ ការអនុវត្តថវិកាឃុំ ការងារសេដ្ឋកិច្ច សង្គមកិច្ច សន្តិសុខសណ្ដាប់ធ្នាប់ ការបម្រើសេវាសាធារណៈ គម្រោងផែនការអភិវឌ្ឍន៍ ការងាររបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាឃុំទឹកល្អក់ និងការចុះបញ្ជីឈ្មោះបោះឆ្នោតជាដើម។

### ៣.១.១.ការគ្រប់គ្រងរដ្ឋបាល

ក្រុមប្រឹក្សាឃុំទឹកល្អក់ មានភារកិច្ចបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋជាមូលដ្ឋាន។ មិនតែប៉ុណ្ណោះក្រុមប្រឹក្សាឃុំ ក៏មានភារកិច្ចអភិបាលកិច្ចរាល់សកម្មភាពទូទៅក្នុងការរស់នៅរបស់ប្រជាពលរដ្ឋ។ ក្នុងនោះ មានការងារជាមូលដ្ឋានលើការគ្រប់គ្រងរដ្ឋបាលជាច្រើនផ្នែកដូចជា ការងារគ្រប់គ្រងស្ថិតិប្រជាជន ការងារលិខិតស្នាម និងការធ្វើផែនការអភិវឌ្ឍន៍ និងថវិការបស់ឃុំទឹកល្អក់ដែលអនុវត្តន៍ក្នុងឆ្នាំ២០១៩។

#### ៣.១.១.១.ស្ថិតិប្រជាជន

ការងារគ្រប់គ្រងស្ថិតិប្រជាជនរបស់ឃុំទឹកល្អក់ អាណត្តិទី៤ ឆ្នាំ២០១៩ មានដូចតទៅ៖

- គ្រួសារសរុប ចំនួន ១,៥១១ គ្រួសារ
- គ្រួសារអចិន្ត្រៃយ៍ ចំនួន ១,៥១១ គ្រួសារ
- ប្រជាជនសរុប ចំនួន ៦,៦០២ នាក់
- ប្រជាជនជាស្រី ចំនួន ៤,០២៦ នាក់
- អ្នកមានអាយុ១៨-៦០ឆ្នាំ ចំនួន ៨៦%
- កំណើនប្រជាជនប្រចាំឆ្នាំ ចំនួន ០១%
- អត្រាភាពក្រីក្រ ចំនួន ១២%។

### ៣.១.១.២.លិខិតបទដ្ឋានគតិយុត្ត និងលិខិតនានា

ក្រុមប្រឹក្សាឃុំទឹកល្អក់ អាណត្តិទី៤ ក្នុងឆ្នាំ២០១៩ បានដាក់ចេញនូវ លិខិតបទដ្ឋានគតិយុត្ត និង លិខិតនានា មានចំនួនដូចខាងក្រោម៖

- ដីការរបស់ក្រុមប្រឹក្សា ចំនួន ០៤ ច្បាប់
- សេចក្ដីសម្រេច ចំនួន ០៩ ច្បាប់
- សេចក្ដីជូនដំណឹង ចំនួន ០៧ ច្បាប់
- លិខិតបង្គាប់ការ ចំនួន ០៣ ច្បាប់
- លិខិតបញ្ជាបេសកម្ម ចំនួន ២៥០ ច្បាប់
- លិខិតឧទ្ទេសនាម ចំនួន ៣០ ច្បាប់
- លិខិតអញ្ជើញ ចំនួន ៦០ ច្បាប់
- លិខិតណែនាំ ចំនួន ០៣ ច្បាប់
- លិខិតសំណូមពរ ចំនួន ១០ ច្បាប់
- លិខិតសំណើរ ចំនួន ៣០ ច្បាប់
- របាយការណ៍ ចំនួន ៤៤ ច្បាប់
- កំណត់ហេតុ ចំនួន ៥០ ច្បាប់
- លិខិតផ្ទេរសិទ្ធិ ចំនួន ០៥ ច្បាប់។

### ៣.១.១.៣.ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

ក្រុមប្រឹក្សាឃុំទឹកល្អក់ ក្នុងអាណត្តិទី៤ ឆ្នាំ២០១៩ បានបើកកិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការរបស់ខ្លួន មានចំនួនដូចខាងក្រោម៖

- កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ចំនួន ១១ លើក
- កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា ចំនួន ០១ លើក
- កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា (គ្មាន)
- កិច្ចប្រជុំ គ.ក.ន.ក ចំនួន ០៦ លើក។

### ៣.១.១.៤.កម្មវិធីប្រតិបត្តិការសេវារដ្ឋបាល

ក្រុមប្រឹក្សាឃុំទឹកល្អក់ ក្នុងអាណត្តិទី៤ ឆ្នាំ២០១៩ សម្រេចបាននូវការបម្រើសេវារដ្ឋបាលជូនប្រជា-ពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួនមានដូចខាងក្រោម៖

- សំបុត្រកំណើត ចំនួន ១៨០ សន្លឹក

| | | | | |
|---|---|---|---|---|
| – | សេចក្តីចម្លងសំបុត្រកំណើត | ចំនួន | ៦០ | សន្លឹក |
| – | សំបុត្របញ្ជាក់កំណើត | ចំនួន | ៩០ | សន្លឹក |
| – | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ចំនួន | ៥០ | សន្លឹក |
| – | សំបុត្រមរណភាព | ចំនួន | ៤០ | សន្លឹក |
| – | សេចក្តីចម្លងសំបុត្រមរណភាព | ចំនួន | ៨០ | សន្លឹក |
| – | សំបុត្រអាពាហ៍ពិពាហ៍ | ចំនួន | ១៥០ | សន្លឹក |
| – | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ចំនួន | ៨០ | សន្លឹក |
| – | សំបុត្រអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរ និងបរទេស | ចំនួន | ០៣ | សន្លឹក |
| – | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរ និងបរទេស | ចំនួន | ២០ | សន្លឹក |
| – | កិច្ចសន្យាខ្ចីប្រាក់ | ចំនួន | ៤០ | ច្បាប់ |
| – | កិច្ចសន្យាជួល | ចំនួន | ២០ | ច្បាប់ |
| – | លិខិតបញ្ជាក់ទីលំនៅ | ចំនួន | ២០០ | សន្លឹក |
| – | លិខិតបញ្ជាក់អំពីទាយាទ | ចំនួន | ១០ | សន្លឹក |
| – | លិខិតបញ្ជាក់កិរិយាមាយាទ | ចំនួន | ៦០ | សន្លឹក |
| – | បញ្ជាក់ប្រវត្តិរូបសង្ខេប | ចំនួន | ១២០ | សន្លឹក |
| – | បញ្ជាក់ពីប្រវត្តិដី | ចំនួន | ៦០០ | សន្លឹក |
| – | បញ្ជាក់បណ្តាញអគ្គិសនី | ចំនួន | ០៥ | ច្បាប់ |
| – | បញ្ជាក់បណ្តាញទឹកស្អាត | ចំនួន | ០៥ | ច្បាប់ |
| – | លិខិតលក់ទិញសត្វពាហនៈ | ចំនួន | ៤០ | សន្លឹក |
| – | លិខិតស្នាមផ្សេងៗ | ចំនួន | ១៥០ | សន្លឹក។ |

**៣.១.១.៥.ការសម្រុះសម្រួលទំនាស់**

ក្រុមប្រឹក្សាឃុំទឹកល្អក់ បានទទួល និងបានសម្របសម្រួលទំនាស់ក្នុងចំនួន ១៥ករណីគឺ៖

- ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយរដ្ឋបាលឃុំ និងរដ្ឋបាលស្រុកគងពិសី ចំនួន ១៣ ករណី
- ករណីដែលបានបញ្ជូនទៅស្ថានប័នពាក់ព័ន្ធ ចំនួន ០២ ករណី។

## ៣.១.២.ការងារសន្តិសុខ សេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ និងវប្បធម៌

ឈរលើមូលដ្ឋាននៃកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ឃុំទឹកល្អក់មិនអាចខ្វះបានឡើយនូវការគ្រប់គ្រង ការរៀបចំសន្តិសុខ សណ្តាប់ធ្នាប់ ការថែរក្សាសម្បត្តិបេតិកភ័ណ្ឌជាតិ ការបង្កើនសេដ្ឋកិច្ច ដើម្បីកាត់បន្ថយភាពក្រីក្រ។

ហេតុដូចនេះ ឃុំទឹកល្អក់បានអនុវត្តន៍ការងាររបស់ខ្លួនលើការងារសន្តិសុខ សង្គមកិច្ច ធនធានធម្មជាតិ និងវប្បធម៌ក្នុងអាណត្តិទី៤ ក្នុងឆ្នាំ២០១៩ ដូចតទៅៈ

**៣.១.២.១.ការងារសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយ**

ស្របតាមគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា រដ្ឋបាលឃុំទឹកល្អក់តែងតែបើកកិច្ចប្រជុំគណៈបញ្ជាការឯកភាពឃុំជារៀងរាល់ខែ។ ក្នុងនោះ រដ្ឋបាលឃុំទឹកល្អក់មានប៉ុស្តិ៍នគបាលរដ្ឋបាលឃុំទឹកល្អក់ និងភ្នាក់ងារសន្តិសុខភូមិបានអនុវត្តន៍ការងាររបស់ខ្លួនយ៉ាងសកម្ម ដោយបង្ការ ទប់ស្កាត់នូវរាល់បទល្មើសផ្សេងៗ និងគ្រោះអាសន្ននានា។ ជាក់ស្តែង ប៉ុស្តិ៍នគបាលរដ្ឋបាលឃុំទឹកល្អក់ បានចុះផ្សព្វផ្សាយជូនប្រជាពលរដ្ឋចំពោះផលប៉ះពាល់ និងបញ្ហាផ្សេងៗមួយចំនួនដូចជាៈ

- គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ចំនួន ០៧ លើក
- វេទិកាសាធារណៈ ចំនួន ១១ លើក
- ផលប៉ះពាល់គ្រឿងញៀន ចំនួន ២៧ លើក
- ច្បាប់ចរាចរណ៍ផ្លូវគោក ការជួញដូរស្ត្រី និងកុមារ ចំនួន ១២ លើក
- បទល្មើសព្រហ្មទណ្ឌ និងច្បាប់ផ្សេងៗទៀត ចំនួន ១៥ លើក។[២៤]

**៣.១.២.២.វិស័យកសិកម្ម**

ចំពោះវិស័យកសិកម្ម ឆ្នាំ២០១៩ រួមមាន ស្រូវវស្សាអនុវត្តន៍បាន ៨០៧ ហិកតា ទិន្នផលទទួលបាន ៨៩២,៨០០ តោន ខូចខាតអស់ ៦៣ ហិកតា ដោយសារគ្រោះរាំងស្ងួត។

**៣.១.២.៣.វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត**

ការជួសជុលផ្លូវ នៅក្នុងឃុំទឹកល្អក់រួមមានៈ

- ជួសជុលផ្លូវក្រាលល្បាយថ្មភ្នំចំនួន ០៦ភូមិ ប្រវែង ៦,៣៩០ម៉ែត្រ ស្មើនឹងទឹកប្រាក់ប្រមាណជា ៦៩,០០០,០០០ រៀល ជាថវិការបស់មូលនិធិឃុំ។

**៣.១.២.៤.ការងារគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន វប្បធម៌ និងបេតិកភ័ណ្ឌជាតិ**

ក្រុមប្រឹក្សាឃុំទឹកល្អក់ ជារឿយៗបានផ្សព្វផ្សាយ និងអប់រំដល់ប្រជាពលរដ្ឋពីបញ្ហាប៉ះពាល់ និងអត្ថប្រយោជន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងបេតិកភ័ណ្ឌជាតិ។ ជាក់ស្តែងក្រុមប្រឹក្សាឃុំទឹកល្អក់បានចូលរួមសម្អាតបរិស្ថាន ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃបរិស្ថានជាមួយរដ្ឋបាលស្រុកគងពិសី រួមជាមួយមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ។

[២៤] សម្ភាសជាមួយមេប៉ុស្តិ៍នគបាលរដ្ឋបាលទឹកល្អក់ អនុសេនីយ៍ឯក ជា សារ៉ន នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ១០:៣៥នាទីព្រឹក នៅប៉ុស្តិ៍នគបាលរដ្ឋបាលទឹកល្អក់

នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩ បានប្រារព្ធទិវាបរិស្ថានជាតិ ដោយចុះសម្អាតតាមដងផ្លូវ និងដាក់ស្លាកសញ្ញាហាមចាក់សំរាមតាមដងផ្លូវនៃឃុំទឹកល្អក់។

**៣.១.២.៥.ការងារសហការជាមួយអង្គភាពពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន**

រដ្ឋបាលឃុំទឹកល្អក់ បានធ្វើការសហការ ចូលរួមរាល់សកម្មភាពដែលជាផលប្រយោជន៍សាធារណៈ។ ក្នុងនោះដែរ ដៃគូពាក់ព័ន្ធទាំងឡាយ អនុវត្តន៍រាល់សកម្មភាពរបស់ខ្លួនសុទ្ធតែរំពឹងទុកនូវលទ្ធផលល្អគាប់ប្រសើរដល់ប្រជាពលរដ្ឋទូទៅ ឬតំបន់គោលដៅ។ សកម្មភាពការងារទាំងនោះរួមមានដូចជា ការងារសប្បុរសធម៌ ការងារបរិស្ថាន បេតិកភ័ណ្ឌជាតិ ការងារអប់រំ ការងារកសិកម្ម ការងារអភិវឌ្ឍន៍ក្នុងសហគមន៍ និងការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈជាដើម។ កន្លងមក រដ្ឋបាលឃុំទឹកល្អក់ បានបង្កើតកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ន អង្គភាពជាដៃគូដូចជា៖

- រដ្ឋបាលខេត្តកំពង់ស្ពឺ
- មន្ទីរជំនាញជុំវិញខេត្តកំពង់ស្ពឺ
- កាកបាទក្រហមកម្ពុជាខេត្តកំពង់ស្ពឺ
- កងកម្លាំងប្រដាប់អាវុធចំណុះខេត្តកំពង់ស្ពឺ
- រដ្ឋបាលស្រុកគងពិសី
- កងកម្លាំងប្រដាប់អាវុធចំណុះស្រុកគងពិសី
- ការិយាល័យជំនាញជុំវិញស្រុកគងពិសី
- ដៃគូអភិវឌ្ឍន៍ឃុំ
- អង្គការសង្គមស៊ីវិលផ្សេងៗ និង
- ភូមិ ក្នុងឃុំសាមី។

**៣.២.បញ្ហាប្រឈម**

ដោយបានពិនិត្យទៅលើសៀវភៅផែនការឃុំ ឆ្នាំ២០១៩ របស់ឃុំទឹកល្អក់ និងការចុះអង្កេតផ្ទាល់នៅមូលដ្ឋានឃុំ ដើម្បីស្វែងយល់ពីស្ថានភាពរបស់ឃុំ ព្រមជាមួយនឹងការជួបសម្ភាសព័ត៌មានជាមួយអាជ្ញាធរឃុំ និងប្រជាពលរដ្ឋនៅទីនោះ យើងខ្ញុំសង្កេតឃើញមានបញ្ហាប្រឈមមួយចំនួនដែលរាំងស្ទះការអភិវឌ្ឍឃុំរួមមាន៖

**៣.២.១.ផ្នែកកសិកម្ម និងដីធ្លី**

បើទោះបីជាហេដ្ឋារចនាសម្ព័ន្ធមួយចំនួនត្រូវបានកសាង និងស្តារឡើងវិញ ប៉ុន្តែនៅមិនទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាកសិករនៅក្នុងឃុំនោះទេ។ ឃុំទឹកល្អក់ ជាឃុំមួយដែលប្រជាពលរដ្ឋរស់នៅពឹងផ្អែកលើវិស័យកសិកម្មជាចម្បង ប៉ុន្តែទោះជាយ៉ាងនេះក្តី ប្រជាពលរដ្ឋមួយចំនួនធំធ្វើស្រែចំការតាមប្រពៃណី

របស់ខ្លួន ដោយពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង។ យោងតាមស្ថានភាពបច្ចុប្បន្ន ទាក់ទងនឹងផ្នែកកសិកម្មមានការប្រើប្រាស់ជីគីមីច្រើនបណ្តាលឱ្យដីឆាប់ខូចគុណភាព ប្រជាពលរដ្ឋប្រកបមុខរបរកសិកម្មមាន ៥៦.៧%នៃប្រជាពលរដ្ឋទូទាំងឃុំ។ បញ្ហាខ្វះទឹកធ្វើស្រែជាមូលហេតុ ដោយអាងទឹក ទំនប់ទឹក ប្រឡាយបានសឹករិចរិល ដីហូរច្រោះធ្វើឱ្យរាក់ និងខ្វះអណ្តូងទឹកសម្រាប់ប្រើប្រាស់ជាដើម។ ឆ្នាំខ្លះក៏ត្រូវរងការខាតបង់ដោយសារតែភ្លៀងធ្លាក់មិនគ្រាប់គ្រាន់ក្នុងការធ្វើស្រែចំការ។ បញ្ហាទាំងនេះពិតជាជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងឃុំទឹកល្អក់។

ដោយឡែកទំនាស់ដីធ្លីក្នុងឃុំទឹកល្អក់ បានបង្កឡើងជាច្រើនករណី ដោយសារតែប្រជាពលរដ្ឋពុំមានការយល់ដឹងអំពីច្បាប់ភូមិបាល ពុំមានការផ្សព្វផ្សាយច្បាប់បានទូលំទូលាយដល់ប្រជាពលរដ្ឋ ឯករណីខ្លះទៀតប្រជាពលរដ្ឋមួយចំនួនមានចេតនាបំពានច្បាប់ ដោយសាររំលោភដីអ្នកដទៃ។

### ៣.២.២.ផ្នែកគមនាគមន៍ និងធនធានធម្មជាតិ

ឃុំទឹកល្អក់ សម្បូរទៅដោយផ្លូវខ្វាត់ខ្វែង ប៉ុន្តែផ្លូវលំខ្លះទទួលរងការខូចខាតដោយសារទឹកភ្លៀង និងរងនូវទម្ងន់រថយន្តដឹកថ្មធំៗឆ្លងកាត់ បណ្តាលឱ្យផ្លូវមានការខូចខាត រអិល ហុយ ពិបាកក្នុងការធ្វើដំណើរ។ ចំណែកឯស្ពានមួយចំនួន មានសភាពទ្រុឌទ្រោម ដែលទាមទារឱ្យមានការជួសជុលជាបន្ទាន់ ចៀសវាងបង្កគ្រោះថ្នាក់ដល់អ្នកធ្វើដំណើរ។

ផ្នែកធនធានធម្មជាតិ ឃុំទឹកល្អក់មានភ្នំគ្របដណ្តប់ចំនួន ៤៧៩,២៧ ហិកតា ដែលស្ថិតនៅភាគខាងលិចឃុំ ជាប់ព្រំប្រទល់ឃុំស្រង់ ពេជ្រមុនី និងស្រុកសំរោងទង។ តំបន់ភ្នំនេះមិនមានឈើធំៗ ព្រៃក្រាស់ៗទេ តែត្រូវបានរិចរិលរងការកាប់បំផ្លាញដោយជនមួយចំនួនកាប់អុសយកដុត យកទៅលក់ និងទទួលរងនូវភ្លើងឆេះព្រៃបំផ្លាញជារៀងរាល់ឆ្នាំ។ ហើយមានតំបន់ភ្នំ ០២ កន្លែងត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្ម ដោយក្រុមហ៊ុនកិនថ្ម។

### ៣.២.៣.ផ្នែកសុខាភិបាល និងបរិស្ថាន

ចំពោះវិស័យសុខាភិបាលក្នុងឃុំទឹកល្អក់បានជួបនូវបញ្ហាប្រឈម ដោយនៅក្នុងឃុំបច្ចុប្បន្ន មិនទាន់មានមណ្ឌលសុខភាព សម្រាប់បម្រើសេវាជូនប្រជាពលរដ្ឋនោះទេ ពោលគឺប្រើប្រាស់ជាមួយនឹងឃុំពេជ្រមុនី។ នៅមានបញ្ហាប្រឈមផ្សេងៗទៀតដូចជា ការឆ្លងជំងឺសម្រាប់សត្វពាហនៈ កុមារកើតជំងឺគ្រុនឈាម និងស្ត្រីគ្រោះថ្នាក់ពេលសម្រាលកូន។ មូលហេតុដែលនាំឱ្យមានបញ្ហាទាំងនេះកើតឡើង គឺបណ្តាលមកពីកង្វះអនាម័យក្នុងការរស់នៅរបស់ប្រជាពលរដ្ឋ ការចាក់សំរាមតាមទីសាធារណៈ តាមព្រៃជើងភ្នំដោយពុំមានការទុកដាក់ត្រឹមត្រូវ ធ្វើឱ្យទឹកដក់ ដែលបង្កឱ្យមានមូសខ្លាច្រើននៅក្នុងភូមិ ជាពិសេសក្នុងរដូវភ្លៀងធ្លាក់ រួមទាំងការគេងដោយមិនបានដាក់មុងត្រឹមត្រូវ ឬមិនបានប្រើមុងជ្រលក់ថ្នាំជាដើម។

លើសពីនេះទៅទៀតបញ្ហាមួយទៀតដែលយើងគួរយកចិត្តទុកដាក់នោះ គឺបញ្ហាបរិស្ថានដោយសារតែទីផ្សារលក់ដូរនៅក្នុងឃុំមានលក្ខណៈតូចតាចពុំទាន់មានអ្នកប្រមូលភាស៊ី ដើម្បីប្រមូលសំរាម យកទៅទុកដាក់កន្លែងណាមួយឱ្យបានត្រឹមត្រូវតាមបច្ចេកទេសទេ។ រួមទាំងខ្វះទីលានចាក់សំរាម ខ្វះរថយន្តដឹកសំរាម ប្រជាពលរដ្ឋលក់ដូររកវិធីសាស្ត្រដោះស្រាយសំអាតសំរាមដោយមធ្យោបាយផ្ទាល់ខ្លួនតែប៉ុណ្ណោះ ចំពោះ ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថាននៅមានកម្រិត និងរោងចក្រ សហគ្រាស សិប្បកម្ម កសិដ្ឋានមួយចំនួនមិនមានកិច្ចសហការល្អជាមួយអាជ្ញាធរមូលដ្ឋាន ស្ថាប័នជំនាញ និងមិនមានកិច្ចសន្យាការពារបរិស្ថាននោះទេជាហេតុបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អនាម័យសាធារណៈនៅក្នុងឃុំទឹកល្អក់នេះតែម្តង។

### ៣.២.៤.ផ្នែកអប់រំ

វិស័យអប់រំ ជាតម្រូវការបន្ទាន់ និងចាំបាច់សម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅក្នុងឃុំទឹកល្អក់ឱ្យកាន់តែមានការរីកចម្រើន។ ក៏ប៉ុន្តែចំពោះស្ថានភាពអប់រំនៅក្នុងឃុំទឹកល្អក់មិនទាន់មានភាពល្អប្រសើរនូវឡើយ ដោយសារនៅក្នុងឃុំទឹកល្អក់សព្វថ្ងៃមានសាលាបឋមសិក្សា ០២ កន្លែង គឺបឋមសិក្សាព្រៃកន្ទោច និងបឋមសិក្សាអង្គរៀន។ ចំពោះអនុវិទ្យាល័យមាន ០១ កន្លែង គឺអនុវិទ្យាល័យព្រៃកន្ទោច ស្ថិតនៅក្នុងភូមិច្រេស ដូច្នេះធ្វើឱ្យសិស្សានុសិស្សនៅក្នុងភូមិដទៃទៀតមានការលំបាក ពីព្រោះត្រូវធ្វើដំណើរឆ្ងាយពីផ្ទះទៅសាលារៀន ហើយចំនួនសិស្សមានការកើនឡើងជាលំដាប់ និងអាគារសិក្សាក្នុងឃុំមានការខ្វះខាតនូវឡើយ។ ជាក់ស្តែងនៅរដូវវស្សាសាលាបឋមសិក្សាអង្គរៀនតែងតែលិចទឹកជារៀងរាល់ឆ្នាំ។ ចំណែកឯថ្នាក់មត្តេយ្យរដ្ឋមានចំនួន ០៤ ថ្នាក់ និងមត្តេយ្យសហគមន៍មានចំនួន ១៣ ភូមិ ប៉ុន្តែនៅខ្វះខាតដូចជា សំភារៈប្រើប្រាស់សម្រាប់ក្មេងលេង និងអប់រំបច្ចេកទេសគ្រូ ទោះជាបីឆ្នាំកន្លងមកមានការគាំទ្រពីក្រសួងអប់រំ មន្ទីរអប់រំខេត្តកំពង់ស្ពឺ ការិយាល័យអប់រំ យុវជន និងកីឡាស្រុកគងពិសី និងបណ្តាដៃគូអភិវឌ្ឍន៍នានាក៏ដោយ។

### ៣.២.៥.ផ្នែកសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម

នៅក្នុងឃុំទឹកល្អក់ ពេលខ្លះជួបប្រទះនឹងបញ្ហាអសន្តិសុខនៅតាមបណ្តាភូមិ ដោយសារក្មេងទំនើងដើរលេងយប់ ការសេពគ្រឿងញៀន និងបញ្ហាគ្រោះថ្នាក់ចរាចរណ៍ជាដើម។[២៥] ទោះបីជាយុវជនជាច្រើនទទួលបានការអប់រំពីសាលា ប៉ុន្តែយុវជនមួយចំនួនតូចបានបង្កើតបក្សពួកដើរលេងពេលយប់ ហើយតែបង្កនូវជម្លោះដល់កម្មវិធីបុណ្យទាន កម្មវិធីរៀបអាពាហ៍ពិពាហ៍ កម្មវិធីផ្សេងៗដែលបណ្តាលឱ្យមានការវាយតប់បង្ករបួសស្នាម។ មួយវិញទៀតនៅក្នុងឃុំបច្ចុប្បន្ននៅមានគ្រួសារមួយចំនួនតូចប្រើអំពើហិង្សាក្នុងគ្រួសារ។ កត្តាទាំងនេះ ភាគច្រើនកើតមានតែលើគ្រួសារដដែលៗ ជាទម្លាប់របស់ខ្លួនដោយគ្មានទទួលយកការអប់រំ ពិសេសបណ្តាលមកពី

[២៥] សម្ភាសជាមួយមេប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកល្អក់ អនុសេនីយ៍ឯក ជា សារ៉ន នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ១០:៣៥នាទីព្រឹក នៅប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកល្អក់

ឥទ្ធិពលគ្រឿងញៀន និងសេពគ្រឿងស្រវឹង។ ហើយការអនុវត្តការងាររដ្ឋបាលសព្វថ្ងៃ ឃុំនៅខ្វះវិទ្យុទាក់ទង និងមធ្យោបាយធ្វើដំណើរនូវឡើយ និងបញ្ហាគ្រោះថ្នាក់ចរាចរណ៍កើតមានជារៀងរាល់ថ្ងៃ បានធ្វើឱ្យមនុស្សរងរបួសស្លាប់ រួមទាំខាតបង់សម្ភារៈ ថវិកាជាច្រើន។ ទន្ទឹមនឹងបញ្ហាខាងលើ ការរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈនៅក្នុងឃុំទឹកល្អក់នៅមានបញ្ហាប្រឈមមួយចំនួនទៀតដូចជា ល្បែងស៊ីសង ជួញដូរគ្រឿងញៀន និងអំពើលួចឆក់ ប្លន់ជាដើម។

### ៣.២.៦.ផ្នែកការងាររដ្ឋបាល និងការចូលរួមរបស់ប្រជាពលរដ្ឋ

នៅក្នុងឃុំទឹកល្អក់ ការបំពេញការងាររដ្ឋបាលសព្វថ្ងៃមិនសូវបានល្អ ដោយសារក្រុមប្រឹក្សាឃុំមួយចំនួនតូចមិនទាប់យល់ច្បាស់ពីតួនាទីរបស់ខ្លួន និងខ្វះសមត្ថភាពយល់ដឹង។ ម្យ៉ាងទៀតសព្វថ្ងៃនេះ ឃុំមិនទាន់មានកន្លែងធ្វើការឱ្យបានសមរម្យនូវឡើយ ដោយសារសាលាឃុំតូចចង្អៀត ធ្វើការបណ្ដោះអាសន្នដែលសាងសង់ពីបេតុងប្រក់ស័ង្កសី ដែលជាថវិកាមូលនិធិឃុំមានទំហំទទឹង ០៩ ម៉ែត្រ បណ្ដោយ ១២ ម៉ែត្រ គ្មានបន្ទប់គ្មានកន្លែងប្រជុំគ្រប់គ្រាន់សម្រាប់ធ្វើការ ពេលមានការប្រជុំម្ដងៗអង្គុយមិនអស់គ្នានោះឡើយ។ ចំពោះការចូលរួមរបស់ប្រជាពលរដ្ឋពុំសូវមានសកម្មភាពក្នុងការចូលរួមកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សាឃុំនោះទេ។ ការមិនបានតាមដានសកម្មភាពរបស់អាជ្ញាធរឃុំដូច្នេះ គឺជាកង្វះការទទួលខុសត្រូវមួយរបស់ប្រជាពលរដ្ឋខ្លួនឯងដែលជាម្ចាស់ឆ្នោតក្នុងការចូលរួមធ្វើសេចក្ដីសម្រេចចិត្ត ដើម្បីអភិវឌ្ឍន៍ក្នុងមូលដ្ឋានដែលខ្លួនរស់នៅ។ មួយវិញទៀតចំពោះការរៀបចំទុកដាក់កសាងឯកសាររបស់ឃុំក៏នៅមានកម្រិតដែលជាហេតុនាំឱ្យការរៀបចំឯកសារ នៅមានលក្ខណៈពុំទាន់ត្រឹមត្រូវ គ្រប់ជ្រុងជ្រោយនូវឡើយ។ លើសពីនេះទៅទៀត ចំពោះមន្ត្រីមួយចំនួនមានចំណេះដឹងផ្នែកបច្ចេកទេសមានចំនួនតិច ដោយសារតែពុំសូវទទួលបានការបណ្ដុះបណ្ដាលបន្ថែម។

## ៣.៣.ដំណោះស្រាយ

### ៣.៣.១.ការពង្រឹងវិស័យកសិកម្ម និងដីធ្លី

ដោយឃុំទឹកល្អក់ ជាឃុំដែលពឹងផ្អែកលើវិស័យកសិកម្ម ដូច្នេះបញ្ហាដីធ្លីគឺជាបញ្ហាចំបងមួយដែលសំខាន់សម្រាប់រដ្ឋបាលឃុំយកចិត្តទុកដាក់ក្នុងការដោះស្រាយ ហើយដើម្បីដោះស្រាយនៅរាល់បញ្ហា ដែលបានកើតមានដោយអាជ្ញាធរឃុំទទួលបានជំនួយពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំបណ្ដុះបណ្ដាលលើបច្ចេកទេសដាំដុះស្រូវវស្សា ព្រមទាំងវិធានការការពារការបំផ្លាញពីសត្វល្អិត រួមទាំងការជ្រើសរើសពូជស្រូវពូជដំណាំផ្សេងៗដល់ប្រជាកសិករ។ ដោយឡែក សម្រាប់ប្រព័ន្ធធារាសាស្ត្រ អាជ្ញាធរឃុំក៏បានខិតខំស្វែងរកប្រភពធនធានពីបណ្ដាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងប្រភពពីថ្នាក់ជាតិបន្ថែម តាមរយៈការជួបប្រជុំលើកសំណូមពរពីតម្រូវការរបស់ឃុំទឹកល្អក់នៅថ្នាក់ស្រុក និងថ្នាក់ខេត្ត ដើម្បីធ្វើការសាងសង់ប្រព័ន្ធស្រោចស្រពសម្រាប់បម្រើដល់វិស័យកសិកម្មរបស់ឃុំឱ្យមានការរីកចម្រើនកាន់តែខ្លាំង។

ចំពោះបញ្ហាទាក់ទងដីធ្លី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមរយៈមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ស្ពឺ និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុកគងពិសី បានដោះស្រាយបញ្ហាដីធ្លីដែលកើតមាននៅក្នុងឃុំទឹកល្អក់ ដើម្បីបញ្ចៀសជម្លោះដីធ្លី។

### ៣.៣.២.ការកែលម្អប្រព័ន្ធគមនាគមន៍ និងធនធានធម្មជាតិ

យើងដឹងស្រាប់ហើយថា ប្រព័ន្ធគមនាគន៍ជាចំណែកមួយដ៏សំខាន់ដល់ការរស់នៅ ដូច្នេះការលំបាក ដែលមានចំពោះមុខ ឃុំទឹកល្អក់ក៏សម្រេចចិត្តជួសជុលក្រាលគ្រួសក្រហមប្រវែង ៧,៨០០ ម៉ែត្រ ផ្លូវលំប្រវែង ៩,៨៨០ ម៉ែត្រ និងលើកផ្លូវថ្មីដូចជា ផ្លូវក្រាលគ្រួសក្រហមប្រវែង ២២,៦៦៣ ម៉ែត្រ ផ្លូវដីសប្រវែង ១៤,១០០ ម៉ែត្រ ចូលទៅក្នុងកម្មវិធីវិនិយោគរបស់ឃុំ ព្រមទាំងទំនាក់ទំនងជាមួយសប្បុរសជននានា និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីជួយសម្រួលដល់ការដឹកទំនិញ ធ្វើដំណើរ និងសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋនៅក្នុងឃុំទឹកល្អក់។ ទាំងអស់នេះ គឺក្នុងគោលបំណងដើម្បីជួយដោះស្រាយនូវបញ្ហាដែលប្រជាពលរដ្ឋនៅក្នុងឃុំបានជួបប្រទះ។

### ៣.៣.៣.ការថែទាំសេវាសុខាភិបាល និងបរិស្ថាន

ចំពោះការលើកកម្ពស់សេវាសុខាភិបាលនៅឃុំទឹកល្អក់ ត្រូវចាប់ផ្តើមពីការជួយផ្គត់ផ្គង់សម្ភារៈ និងថ្នាំពេទ្យឱ្យបានគ្រប់គ្រាន់ដល់មណ្ឌលសុខភាពពីសំណាក់មន្ទីរសុខាភិបាល និងណែនាំដល់ប្រជាពលរដ្ឋ ឱ្យកែប្រែទម្លាប់សម្រាលកូនដោយឆ្មប ឱ្យមកប្រើសេវាពេទ្យឆ្មបដែលធានាសុវត្ថិភាពជាមួយបុគ្គលិកក្រសួងសុខាភិបាល ដែលមានជំនាញច្បាស់លាស់ រួមទាំងការចាក់វ៉ាក់សាំងដល់កុមារគ្រប់រូបដែលរស់នៅក្នុងមូលដ្ឋាន។ ដោយឡែកបញ្ហាទាក់ទងជាមួយប្រជាពលរដ្ឋដែលមានផ្ទុកមេរោគអេដស៍ កុមារកំព្រាក្រោមអាយុ ១៨ឆ្នាំ ជនពិការ ឃុំមានគោលដៅសហការជាមួយអង្គការ ស្ថាប័ន ដែលពាក់ព័ន្ធឱ្យជួយស្តារលទ្ធភាពរាងកាយជនពិការ បណ្តុះបណ្តាលវិជ្ជាជីវៈ កម្មវិធីអាហារូបត្ថម្ភ អប់រំសុខភាពបន្តពូជ សុខភាពមាតា និងកុមារ លុបបំបាត់មូលហេតុដែលបណ្តាលឱ្យមានជំងឺ ចាត់វិធានបង្ការ និងផ្តល់ការព្យាបាលដែលចាំបាច់ដល់ប្រជាពលរដ្ឋ។ ប្រការមួយទៀតនោះ គឺ ការសម្អាតបរិស្ថាន ដោយអាជ្ញាធរឃុំគួរតែខិតខំបន្តបើកវគ្គបណ្តុះបណ្តាលបន្ថែមដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីការរក្សាអនាម័យក្នុងការរស់នៅ ក្រោមពាក្យស្លោក ហូបស្អាត ផឹកស្អាត រស់នៅស្អាត ព្រមទាំងការទុកដាក់សំណល់ផ្សេងឱ្យមានរបៀបរៀបរយ និង វិធីបង្ការទប់ស្កាត់ជំងឺកូវីដ-១៩ ដើម្បីសុខមាលភាពប្រជាពលរដ្ឋទាំងមូល ពិសេសកុមារ និងចាស់ជរា។

### ៣.៣.៤.ការលើកកម្ពស់គុណភាពអប់រំ

ដើម្បីជម្រុញឱ្យការអប់រំនៅក្នុងឃុំទឹកល្អក់ មានប្រសិទ្ធភាព និងឆ្លើយតបបានទៅនឹងតម្រូវការរបស់សិស្ស និងគ្រូបង្រៀន រដ្ឋបាលថ្នាក់ជាតិដែលមានក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងមន្ទីរចំណុះរបស់ខ្លួននៅខេត្តកំពង់ស្ពឺ និងការិយាល័យអប់រំ យុវជន និងកីឡាស្រុកគងពិសី គប្បីពិនិត្យលទ្ធភាពផ្តល់ថវិកា ឬស្វែងរក

ជំនួយ ដើម្បីកសាងវិទ្យាល័យមួយមាននៅក្នុងឃុំទឹកល្អក់សម្រាប់សិស្សានុសិស្ស និងគ្រូបង្រៀនងាយស្រួលធ្វើដំណើរទៅសាលារៀន និងកាត់បន្ថយពេលពេលវេលាក្នុងការធ្វើដំណើរ។ បន្ថែមពីនេះ ការលើកទឹកចិត្តគ្រូបង្រៀន តាមរយៈការបង្កើនប្រាក់បៀវត្សរ៍ ប្រាក់លើកទឹកចិត្ត ឬប្រាក់ឧបត្ថម្ភផ្សេងៗដែលជាកត្តាមួយជំរុញឱ្យគ្រូមានកម្លាំងចិត្ត និងកម្លាំងកាយក្នុងការផ្តល់ចំណេះដឹងដល់សិស្សគ្រប់រូបនៅក្នុងឃុំទឹកល្អក់នេះផងដែរ។ លើសពីនេះ ឃុំទឹកល្អក់បានសហការជាមួយស្ថាប័នពាក់ព័ន្ធបង្កើតមត្តេយ្យសហគមន៍ និងមត្តេយ្យរដ្ឋនៅតាមភូមិនានាដែលចំណុះឃុំទឹកល្អក់។ ជាពិសេស រដ្ឋបាលឃុំទឹកល្អក់ក៏បានចូលរួមកាត់បន្ថយចំណាយរបស់សិស្សដែលក្រីក្រ តាមរយៈការផ្តល់អាហាររូបករណ៍ (ថ្នាក់បឋម និងមធ្យមសិក្សា) ពង្រឹង និងកំណត់មុខសញ្ញាឱ្យបានល្អជាងមុនសម្រាប់កម្មវិធីផ្តល់អាហារពេលព្រឹកនៅបឋមសិក្សា និងកម្មវិធីលើកទឹកចិត្តដល់សិស្សថ្នាក់ទី ០៧ ដល់ទី ០៩។ កាត់បន្ថយអក្ខរជនឱ្យនៅកម្រិតទាបបំផុត និងឈានទៅបំបាត់នាពេលខាងមុខ តាមរយៈការធ្វើកិច្ចសហការជាមួយការិយាល័យអប់រំស្រុកគងពិសី មន្ទីរអប់រំខេត្តកំពង់ស្ពឺ និងដៃគូពាក់ព័ន្ធនានា ក្នុងការបង្កើតថ្នាក់អក្ខរកម្ម ពីព្រោះភាពអវិជ្ជមាននៃប្រជាជនជាឧបសគ្គសម្រាប់ការអភិវឌ្ឍជីវភាពគ្រួសារ និងសង្គមជាតិ។

### ៣.៣.៥.ការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម

ផ្អែកតាមអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចំពោះការងារសន្តិសុខ សណ្តាប់ធ្នាប់សង្គម រដ្ឋបាលឃុំទឹកល្អក់បានអនុវត្តន៍តាមសេចក្តីណែនាំ លេខ ០២០ របស់ក្រសួងមហាផ្ទៃស្តីពីការអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព ដោយអនុវត្តន៍ជាប្រចាំ។ សកម្មភាពទាំងនេះ មានការគាំទ្រពីក្រសួងមហាផ្ទៃ ស្នងការនគរបាលខេត្តកំពង់ស្ពឺ អធិការដ្ឋាននរគបាលស្រុកគងពិសី ប៉ុស្តិ៍នរគបាលរដ្ឋបាលឃុំទឹកល្អក់ គណៈបញ្ជាការឯកភាពឃុំទឹកល្អក់ ហើយបានផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីច្បាប់របស់រដ្ឋ និងគោលនយោបាយ គឺធ្វើយ៉ាងណាជម្រុញឱ្យឃុំទឹកល្អក់ ភូមិចំណុះក្លាយជាមូលដ្ឋានដែលមានលក្ខណៈសម្បត្តិដូចខាងក្រោមនេះ៖

- គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ
- គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀន
- គ្មានអំពើអនាចារ ការជួញដូរស្ត្រី កុមារ និងអំពើហិង្សាក្នុងគ្រួសារ
- គ្មានក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងខុសច្បាប់ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
- គ្មានគ្រោះថ្នាក់ចរាចរណ៍
- គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
- មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- គ្មានការត្រួតពិនិត្យខុសច្បាប់។

### ៣.៣.៦.ការបង្កើនប្រសិទ្ធភាពការងាររដ្ឋបាល និងអភិបាលកិច្ចល្អ

ជាការឆ្លើយតប ចំពោះកង្វះខាតក្នុងការបំពេញការងាររដ្ឋបាលរបស់សាលាឃុំទឹកល្អក់ ក្រសួងមហាផ្ទៃបានរៀបចំជារឿយៗនូវកម្មវិធីបណ្តុះបណ្តាលមេឃុំ ក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ ពាក់ព័ន្ធនឹងការងាររៀបចំផែនការវិនិយោគ និងផែនការថវិការបស់ឃុំជាដើម។ មួយវិញទៀត ក្រសួងមហាផ្ទៃក៏បានយកចិត្តទុកដាក់បន្ថែមលើការបណ្តុះបណ្តាល ស្មៀនឃុំ ដើម្បីឱ្យក្លាយទៅជាធនធានមនុស្សដ៏សំខាន់ សម្រាប់ទទួលបន្ទុកសម្រួលការងាររដ្ឋបាលឃុំឱ្យមានដំណើរការរលូនស្របតាមគោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្ត។ ក្រៅពីនេះចំពោះការសាងសង់អាគារសាលាឃុំថ្មី គឺកំពុងដំណើរការសាងសង់នូវឡើយ ដែលឧបត្ថម្ភដោយក្រសួងមហាផ្ទៃផងដែរ។ រដ្ឋបាលឃុំទឹកល្អក់ក៏បានផ្សព្វផ្សាយការងារអត្រានុកូលដ្ឋាន ការធ្វើសៀវភៅគ្រួសារ ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំទឹកល្អក់ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការបម្រើសាធារណៈរបស់រដ្ឋបាលឃុំ សំដៅបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ។

## ៣.៤.ទិសដៅអនាគត

### ៣.៤.១.អភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

បន្ទាប់ពីការអនុវត្តការងារផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត អាណត្តិទី៤ ឆ្នាំ២០១៩ រដ្ឋបាលឃុំទឹកល្អក់មានទិសដៅការងារជាអាទិភាពសម្រាប់ឆ្នាំ២០២០ មានដូចខាងក្រោម៖

- សិក្សាលទ្ធភាពគម្រោងហេដ្ឋារចនាសម្ព័ន្ធឆ្នាំ២០២០
- សាងសង់ផ្លូវបេតុងក្នុងឃុំទឹកល្អក់ ប្រវែង ២,១០០ ម៉ែត្រ តម្លៃប៉ាន់ស្មាន ៨០,០០០,០០០ រៀល
- ជួសជុលផ្លូវ និងថែទាំផ្លូវដែលមានការខូចខាតដោយទឹកភ្លៀង និងដោយសកម្មភាពផ្សេង ធ្វើយ៉ាងណាធានាឱ្យប្រជាពលរដ្ឋមានផ្លូវសមរម្យសម្រាប់ធ្វើដំណើរ។
- សាងសង់បង្គន់អនាម័យសម្រាប់គ្រួសារក្រីក្រគ្មានលទ្ធភាព ចំនួន ៨០បង្គន់ តម្លៃប៉ាន់ស្មាន ៦០,០០០,០០០ រៀល
- ជួសជុលផ្គត់ផ្គង់សម្ភារៈក្នុងក្រៅថ្នាក់មត្តេយ្យ ចំនួន ១៣ ថ្នាក់ តម្លៃប៉ាន់ស្មាន ៤០,០០០,០០០ រៀល

### ៣.៤.២.ផ្នែកសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ

បន្ទាប់ពីការអនុវត្តការងារផ្នែកសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ក្នុងឆ្នាំ២០១៩ រួចមក រដ្ឋបាលឃុំទឹកល្អក់មានទិសដៅការងារជាអាទិភាព សម្រាប់អាណត្តិទី៤ ក្នុងឆ្នាំ២០២០ ដូចជា៖

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក (ថ្មី) និង

- បន្តអនុវត្តន៍គោលនយោបាយភូមិ ឃុំមានសុវត្ថិភាពឱ្យទទួលបានប្រសិទ្ធភាពកាន់តែល្អប្រសើរឡើង ដោយលុបបំបាត់បទល្មើសគ្រប់រូបភាព គ្រឿងញៀន អំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ ជាដើម។

**២.៤.៣.ផ្នែកផ្តល់សេវាសាធារណៈ**

បន្ទាប់ពីការអនុវត្តការងារផ្នែកសេវាសាធារណៈ ក្នុងអាណត្តិទី៤ ឆ្នាំ២០១៩រួចមក រដ្ឋបាលឃុំទឹកល្អក់ មានទិសដៅជាអាទិភាពក្នុងឆ្នាំ២០២០ មានដូចខាងក្រោមៈ

- បន្តផ្សព្វផ្សាយការកំណត់តម្លៃសេវាសាធារណៈនៅក្នុងសាលាឃុំ និងទីសាធារណៈក្នុងឃុំ
- បន្តទទួលពាក្យបណ្តឹង និងសម្របសម្រួលទំនាស់ផ្នែកសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព និងយុត្តិធម៌
- បន្តការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិស្របតាម ប្រកាសអន្តរក្រសួងលេខ ១៤៣៤៤ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាល របស់រដ្ឋបាលថ្នាក់ក្រោមជាតិរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

# សេចក្តីសន្និដ្ឋាន

ឃុំ សង្កាត់ ជានីតិបុគ្គលសាធារណៈ។ កាលណានិយាយអំពីរដ្ឋបាលឃុំ សង្កាត់ គឺសំដៅដល់ក្រុមប្រឹក្សាឃុំ សង្កាត់។ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមនយោបាយបែបវិមជ្ឈការ ដូច្នេះប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ត្រូវអនុវត្តន៍នៅថ្នាក់ឃុំ សង្កាត់។ អំណាចដឹកនាំ និងគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានមកពីការបោះឆ្នោតជាសកល ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីកំណែទម្រង់រដ្ឋបាលតាមនយោបាយវិមជ្ឈការឃុំ សង្កាត់ ជាការលើកកម្ពស់សមធម៌ តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់សម្រាប់តម្រូវការជាមូលដ្ឋានជូនប្រជាពលរដ្ឋ។ ចំពោះវិមជ្ឈការនៅរដ្ឋបាលថ្នាក់ឃុំ សង្កាត់ជាកត្តាចម្បងដែលមិនអាចមានការធ្វេសប្រហែសបានឡើយ ហើយត្រូវតែយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តតាមបច្ចេកទេសនៃប្រព័ន្ធវិមជ្ឈការ ស្របនឹងទីកន្លែង ពេលវេលា និងតម្រូវការជាក់ស្តែង។ ជាពិសេសគោលនយោបាយនេះ បានកាត់បន្ថយការិយាធិបតេយ្យ និងបានធ្វើការបង្កិតសេវាឱ្យកាន់តែជិតប្រជាពលរដ្ឋ ដើម្បីចំនេញពេលវាលា សន្សំប្រាក់កាក់ និងកាត់បន្ថយភាពក្រីក្រ។

សិទ្ធិអំណាចមូលដ្ឋានដែលត្រូវបានទទួលយកដោយក្រុមតំណាងរបស់ប្រជាពលរដ្ឋមូលដ្ឋាន ហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដោយក្រុមប្រឹក្សានេះធ្វើសកម្មភាពដើម្បីប្រយោជន៍ទូទៅ និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ក្នុងកិច្ចអភិវឌ្ឍន៍ដែលរាស្ត្របានបោះឆ្នោតជាតំណាងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន និងមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅរបស់ឃុំ សង្កាត់សាមី។ ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមួយអាណត្តិមានរយៈពេល ០៥ឆ្នាំ ដែលមានប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ។

ជាក់ស្តែងឃុំទឹកល្អក់ ជានីតិបុគ្គលសាធារណៈដែលមានតួនាទីសំខាន់ៗគឺ បម្រើកិច្ចការមូលដ្ឋានសម្រាប់ផលប្រយោជន៍ទូទៅរបស់ឃុំ និងជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។ រដ្ឋបាលឃុំទឹកល្អក់ ត្រូវបានដឹកនាំ គ្រប់គ្រងកិច្ចការងាររដ្ឋបាលដោយក្រុមប្រឹក្សាឃុំចំនួន ០៧ រូប ដែលមាន ០១ រូប ជាប្រធានក្រុមប្រឹក្សា ០២ រូបជាជំទប់ និង ០៤ រូបផ្សេងទៀតជាសមាជិកក្រុមប្រឹក្សាក្នុងអាណត្តិទី៤ របស់ឃុំទឹកល្អក់។ ក្រុមប្រឹក្សាឃុំគ្រប់រូប បានខិតខំបំពេញការងារជូនរដ្ឋបាលឃុំស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលជាធរមាន។

រដ្ឋបាលឃុំតែងតែគិតគូពីសុខទុក្ខរបស់ប្រជាពលរដ្ឋ ដោយមានកិច្ចប្រជុំរបស់ គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ដើម្បីលើកឡើងនូវផែនការ និងរិះរកឱ្យឃើញពីបញ្ហា មូលហេតុនៃបញ្ហា តម្រូវការចាំបាច់យកមកដោះស្រាយ។ ការដោះស្រាយបញ្ហាទាំងនោះ ដោះស្រាយនូវបញ្ហាតម្រូវការអាទិភាព និងបញ្ហាបន្ទាប់បន្សំ។

ចំណែកឯ ការពង្រឹងកិច្ចសហប្រតិបត្តិការវិញនោះ រដ្ឋបាលឃុំបានពង្រឹង និងស្វែងរកដៃគូសហប្រតិបត្តិការអន្តររដ្ឋបាល ដើម្បីសម្រួលការងារជាមូលដ្ឋានក្នុងឃុំ ប្រកបដោយប្រសិទ្ធភាព តាមឋានានុក្រម។

អ្វីដែលសំខាន់នោះ រដ្ឋបាលឃុំទឹកល្អក់បានអនុវត្តន៍មុខងាររបស់ខ្លួនស្របតាមនយោបាយវិមជ្ឈការរបស់រាជរដ្ឋាភិបាលដែលបានប្រគល់មុខងារ សិទ្ធិអំណាច ធនធាន (ថវិកា សម្ភារៈ និងធនធានមនុស្ស) ជូនរដ្ឋបាលឃុំ ដើម្បីបំពេញតម្រូវការមូលដ្ឋានរបស់ប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាពខ្ពស់។ គោលនយោបាយវិមជ្ឈការឃុំ សង្កាត់ជាមគ្គទេសយ៉ាងចំណានក្នុងការដឹកនាំរដ្ឋបាល ដើម្បីឈានទៅរកវឌ្ឍនភាព និងនិរន្តរភាពនៃការងាររដ្ឋបាលឃុំ សង្កាត់។ តាមរយៈគោលនយោបាយវិមជ្ឈការ បានធ្វើឱ្យរដ្ឋបាលឃុំទឹកល្អក់បម្រើសេវាជូនប្រជាពលរដ្ឋបានយ៉ាងល្អប្រសើរ និងបានលើកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឃុំផ្ទាល់។

តាមលទ្ធផលការងាររបស់រដ្ឋបាលឃុំទឹកល្អក់ ក្នុងអាណត្តិទី៤ ឆ្នាំ២០១៩ បានបង្ហាញថា ការអនុវត្តមុខងារជាអ្នកបម្រើកិច្ចការមូលដ្ឋាន និងប្រជាពលរដ្ឋ រួមទាំងមុខងារជាភ្នាក់ងាររដ្ឋ សុទ្ធសឹងតែមានសកម្មភាពទាំងអស់។ ទន្ទឹមនឹងនេះ រួមមានការងាររដ្ឋបាល ស្ថិតិ ការងារសេដ្ឋកិច្ច សង្គមកិច្ច និងការងារដោះស្រាយបញ្ហាផ្សេងៗទៀត មានដំណើរការល្អអាចទទួលយកបាន តែមានទាន់ល្អប្រសើរនូវឡើយ។ ហេតុនេះហើយ ក្រុមប្រឹក្សាឃុំទឹកល្អក់ ត្រូវខិតខំបំពេញការងារកាន់តែសកម្មបន្ថែមទៀត ទន្ទឹមនឹងការបំពេញការងារសព្វថ្ងៃនេះ។

ក្រុមប្រឹក្សាឃុំ និងបុគ្គលិកមន្ត្រីរបស់ឃុំទឹកល្អក់ បើទោះជាបានអនុវត្តន៍ការងារខ្លួនល្អយ៉ាងណាក្តី ប្រសិនបើខ្វះការចូលរួមពីសំណាក់ដៃគូអភិវឌ្ឍន៍នានា និងប្រជាពលរដ្ឋនៅមូលដ្ឋាននោះទេ ក៏មិនអាចធ្វើឱ្យឃុំទឹកល្អក់មានការអភិវឌ្ឍខ្លាំងដែរ។ ដោយហេតុនេះ ការអនុវត្តគោលនយោបាយវិមជ្ឈការឃុំទឹកល្អក់ ទាមទារមានចលនានៃការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានផ្ទាល់ឱ្យបានមុតមាំ និងកុះករ តាមរយៈការយល់ឃើញច្បាស់លាស់ មានសុភនិច្ឆ័យ ទើបនយោបាយវិមជ្ឈការឃុំទឹកល្អក់ ទួលបានប្រសិទ្ធភាព និងភាពស័ក្កិសិទ្ធិ។

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងសេចក្ដីសន្និដ្ឋានខាងលើ យើងខ្ញុំបាទ សូមចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល និងអាជ្ញាធរដែលមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ពិសេសអាជ្ញាធរឃុំទឹកល្អក់ផ្ទាល់ ក្នុងការថែរក្សា ការពារនូវបូរណភាពទឹកដី ការគ្រប់គ្រងរដ្ឋបាលដែនដី ជាពិសេសដើម្បីពង្រឹងលើការអនុវត្តនូវគោលនយោបាយវិមជ្ឈការនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- អាជ្ញាធរឃុំគួរសាងសង់មណ្ឌលសុខភាពក្នុងឃុំទឹកល្អក់ ដើម្បីឱ្យប្រជាពលរដ្ឋ មានភាពងាយស្រួលក្នុងការព្យាបាលជម្ងឺ ដោយមិនចាំបាច់ទៅព្យាបាលនៅមណ្ឌលសុខភាពដែលស្ថិតក្នុងឃុំផ្សេងៗ។
- អាជ្ញាធរឃុំគួរពង្រឹងសមត្ថភាព និងភាពថ្នៃប្រឌិតក្នុងការងារ ពិសេសពង្រឹងសមត្ថភាពការធ្វើការងារជាក្រុម បច្ចេកទេសកុំព្យូទ័រ ភាសារជាតិ បរទេស និងបណ្ដាញអ៊ីនធ័រណែត។
- អាជ្ញាធរឃុំ គួរបង្កើនការលើកកម្ពស់សោភ័ណភាពតំបន់រមណីយដ្ឋានក្បែរជើងភ្នំ ដែលមាននៅក្នុងឃុំឱ្យមានសក្ដានុពលទេសចរណ៍ ពិសេសតំបន់រមណីយដ្ឋានធម្មជាតិ និងវប្បធម៌។
- ចំពោះផលដំណាំ ម្ហូបអាហារ អាជ្ញាធរឃុំគួរតែមានវិធានការអប់រំប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយ ឬមិនត្រូវប្រើប្រាស់សារធាតុគីមីដែលបណ្ដាលឱ្យប៉ះពាល់ដល់សុខភាព។
- សូមអាជ្ញាធរឃុំ បើកវេទិកាសាធារណៈឱ្យបានញឹកញាប់ ដើម្បីទទួលបាននូវរាល់បញ្ហាប្រឈមនានាដែលកើតមាននៅក្នុងឃុំ រួចរកដំណោះស្រាយជូនប្រជាពលរដ្ឋឱ្យបានសមស្របតាមលទ្ធភាព។
- សូមរាជរដ្ឋាភិបាល អាជ្ញាធរខេត្ត ស្រុក និងឃុំ ជំរុញការងារភូមិមួយ ផលិតផលមួយ ដើម្បីជួយសម្រួលការរកទីផ្សារផលិតផល ចំណីអាហារ គ្រឿងសម្ភារៈ និងរបស់របរប្រើប្រាស់ក្នុងភូមិ ឃុំរបស់ខ្លួនក្នុងការបង្កើនប្រាក់ចំណូលសេដ្ឋកិច្ចគ្រួសារជូនប្រជាពលរដ្ឋ។
- សូមរាជរដ្ឋាភិបាល អាជ្ញាធរខេត្ត ស្រុក និងឃុំ បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានចំពោះបញ្ហាការចោលសំរាម អនាម័យ បរិស្ថាន ជាពិសេសរួមគ្នាប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ឱ្យបានទូលំទូលាយ ដើម្បីសុខភាពរបស់ប្រជាពលរដ្ឋក្នុងការរស់នៅ។
- សូមរាជរដ្ឋាភិបាលបន្តបង្កើនយន្តការល្អៗក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការនៅតាម បណ្ដាឃុំសង្កាត់ទូទាំងប្រទេសកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់បន្តទៀត ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ ព្រមទាំងសមធម៌ឱ្យបានគ្រប់ជ្រុងជ្រោយ។
- សូមរាជរដ្ឋាភិបាល ក៏ដូចជាក្រសួង ស្ថាប័ននានាដែលមានសមត្ថកិច្ច មេត្តារៀបចំបង្កើតឡើងតុលាការរដ្ឋបាល ដើម្បីដោះស្រាយបញ្ហាវិវាទរដ្ឋបាលនៅក្នុងប្រទេសកម្ពុជាផងដែរ។

# គន្ថនិទ្ទេស

## ក.ផ្នែកបទដ្ឋានគតិយុត្ត


១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

២.ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

៣.ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០១

៤.ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៦

៥.អនុក្រឹត្យលេខ ១៦ អនក្រ.បក ស្តីពីមូលនិធិឃុំ សង្កាត់ ឆ្នាំ២០០២

៦.អនុក្រឹត្យលេខ ២២ អនក្រ.បក ស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី ភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ២០០

៧.អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ឆ្នាំ២០០២

៨.អនុក្រឹត្យលេខ ៥១ អនក្រ.បក ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ ឆ្នាំ ២០១៨

៩.អនុក្រឹត្យលេខ ១២១ អនក្រ.បក ស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ឆ្នាំ២០១៩

១០.អនុក្រឹត្យលេខ ៣៤ អនក្រ.បក ស្តីពីការកែប្រែនិងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០២០

១១.ប្រកាសលេខ ១៣២៩ ប្រ.ក ស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់ ឆ្នាំ២០០១

១២.ប្រកាសលេខ ១៤៣៤៤ ប្រ.ក ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៦

១៣.សេចក្តីណែនាំលេខ ០០៤ ស.ណ.ន ស្តីពីបែបបទ នីតិវិធី នៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ ឆ្នាំ ២០០៦

១៤.ផែនការណែនាំលេខ ០២០ ផ.ក ស្តីពីការចាត់តាំងអនុវត្តន៍គោលនយោបាយ "ភូមិ ឃុំមានសុវត្ថិភាព" របស់ក្រសួងមហាផ្ទៃ ឆ្នាំ២០១០

១៥.ក្របខណ្ឌយុទ្ធសាស្ត្រ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឆ្នាំ២០០៥


## ខ.ផ្នែកទ្រឹស្តី


១៦.សៀវភៅប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា របស់ក្រសួងមហាផ្ទៃ ឆ្នាំ២០១៩

១៧.សៀវភៅការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ របស់ក្រសួងមហាផ្ទៃ ឆ្នាំ២០១៧

១៨.សៀវភៅរដ្ឋបាលសាធារណៈ រៀបរៀងដោយ សាស្ត្រាចារ្យ អ៊ឹយ ធឿន ឆ្នាំ២០១៩

១៩.សៀវភៅនីតិរដ្ឋបាលទូទៅ រៀបរៀងដោយ អនុបណ្ឌិត ហៀង សាង ឆ្នាំ២០១៧

២០.សៀវភៅនីតិរដ្ឋបាលទូទៅ រៀបរៀងដោយ បណ្ឌិត សាយ បូរី ឆ្នាំ២០១២

២១.សៀវភៅវិមជ្ឈការ និងវិសហមជ្ឈការ រៀបរៀងដោយ អនុបណ្ឌិត កៅ មុយថង ឆ្នាំ២០០៧

**គ.ឯកសារផ្សេងៗ**

២២.កម្មវិធីវិនិយោគវិនិយោគបីឆ្នាំរំកិល ២០១៩-២០២១ របស់ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

២៣.របាយការណ៍ប្រចាំខែធ្នូ ឆ្នាំ២០១៩ ស្ដីការអនុវត្តការងាររបស់រដ្ឋបាលឃុំទឹកល្អក់

២៤.សៀវភៅផែនការឃុំ ឆ្នាំ២០១៩ របស់ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

២៥.អនុស្សរណៈ ស្ដីពីការរៀបចំគម្រោងថវិកា ឆ្នាំ២០១៩

២៦.បទសម្ភាសជាមួយស្មៀន មេឃុំទឹកល្អក់ មេប៉ុស្ដិ៍នគរបាល និងប្រជាពលរដ្ឋដោយក្រុមនិស្សិតស្រាវជ្រាវ

# សេចក្ដីផ្ដើម

# ជំពូកទី១
# រំលឹកទ្រឹស្តី និងគោលការណ៍សំខាន់ៗ

# ជំពូកទី២
# ដំណើរការគ្រប់គ្រងរដ្ឋបាលរបស់ឃុំទឹកល្អក់

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ

# សេចក្តីសន្និដ្ឋាន

# អនុសាសន៍

# គន្ថនិទ្ទេស

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ១.

## ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១

## ប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

# ឧបសម្ព័ន្ធ ២.
# ផែនទីឃុំទឹកល្អក់

# ឧបសម្ព័ន្ធ ៣.

# ប្រកាសស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាឃុំនៃឃុំទឹកល្អក់

# ឧបសម្ព័ន្ធ ៤.
# សេចក្ដីសម្រេចបង្កើតគណៈកម្មការនិងគណៈកម្មាធិការនានា

**ឧបសម្ព័ន្ធ ៥.**

**របាយការណ៍ប្រចាំខែធ្នូ ឆ្នាំ២០១៩**

**ស្តីពីការអនុវត្តការងាររដ្ឋបាលរបស់ឃុំទឹកល្អក់**

# កម្រងសំណួរ

# ឧបសម្ព័ន្ធ ៦.
# សម្ភាសជាមួយមេឃុំ និងស្មៀនរបស់ឃុំទឹកល្អក់

# ឧបសម្ព័ន្ធ ៧.

# សម្ភាសជាមួយមេប៉ុស្តិ៍នគរបាល រដ្ឋបាលទឹកល្អក់

# ឧបសម្ព័ន្ធ ៨.

# សម្ភាសជាមួយប្រជាពលរដ្ឋ

# ឧបសម្ព័ន្ធ ៩.
# លិខិតបញ្ជាក់របស់រដ្ឋបាលឃុំទឹកល្អក់